សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de droit et des sciences Èconomiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក សា ឌីនី**

**កញ្ញា រ៉ុង មួយហ៊ាង**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **ញ៉ឹក ឧត្តិ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្ដីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទ **សា ឌីនី** និងនាងខ្ញុំ **រ៉ុន មួយហ៊ាង** សូមគោរពអនុញ្ញាតធ្វើការលំឱនកាយវាចាចិត្ត សម្ដែងនូវកិច្ចគោរពដឹងគុណដោយភាពស្មោះអស់ដួងពីចិត្ត និងបង្ហាញនូវភាពកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅដែលពុំអាចកាត់ថ្លៃបានជូនចំពោះ **លោកឪពុក អ្នកម្ដាយ** ដែលបានផ្ដល់កំណើត ក៏ដូចជាប្រឹងប្រែងស្ទើរតែពេញមួយជីវិត ក្នុងការចិញ្ចឹមបីបាច់ ថែរក្សាការពារ កូនទាំងពីរតាំងតែពីតូចរហូតដល់វ័យនេះ និងបានផ្ដល់នូវសេចក្ដីស្រឡាញ់ថ្នាក់ថ្នម អប់រំ ទូន្មាន ប្រៀនប្រដៅដល់កូនប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងបង្រៀនឱ្យកូនមានការអត់ធ្មត់ និងមានសេចក្ដីតស៊ូព្យាយាមក្នុងជីវិត។ លោកបានធ្វើការចំណាយពេលវេលា កំលាំងកាយ កំលាំងចិត្ត និងធនធានយ៉ាងច្រើនដោយមិនគិតពីការនឿយហត់ ពុំដែលពោលពីទុក្ខលំបាកគ្រប់បែបយ៉ាងដើម្បីផ្គត់ផ្គង់ដល់ការសិក្សារបស់កូនឱ្យទទួលបាននូវចំណេះដឹងដ៏ប្រពៃថ្លៃថ្លាសម្រាប់ជាស្ពានចម្លងខ្លួនឯង គ្រួសារ ក៏ដូចជាសង្គមជាតិ។ សេចក្ដីគោរពដឹងគុណចំពោះ **លោកឪពុក** និង **អ្នកម្ដាយ** ទាំងអស់នេះពិតជាធំធេងពុំអាចមានអ្វីមកកាត់ថ្លៃបានឡើយសម្រាប់ជីវិតកូនទាំងពីរនាក់នេះ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ចំពោះ **ឯកឧត្តម សាកលវិទ្យាធិការ សាលកវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រាចារ្យទាំងអស់នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានអនុញ្ញាតឱ្យយើងខ្ញុំទាំងពីររូបបានចូលសិក្សានៅទីនេះ ហើយថែមទាំងយកចិត្តទុកដាក់ ខិតខំអប់រំ និងពង្រឹងវិន័យសាកលវិទ្យាល័យ តាំងពីចូលរៀនថ្នាក់សិក្សាឆ្នាំមូលដ្ឋាន រហូតមកដល់ការសរសេរនូវសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ។ ទីកន្លែងនេះហើយដែលជាថ្នាលបណ្ដុះបណ្ដាលឱ្យយើងខ្ញុំទាំងពីររូបបានសិក្សាស្វែងយល់នូវទិដ្ឋភាពផ្នែកទ្រឹស្ដី និងទិដ្ឋភាពផ្នែកសង្គមហើយធ្វើឱ្យយើងខ្ញុំទទួលបាននូវចំណេះដឹងល្អៗ ដែលនាំឱ្យយើងខ្ញុំអាចបញ្ចប់ការសិក្សាប្រកបដោយភាពជោគជ័យ។

ជាពិសេសយើងខ្ញុំទាំងពីរ សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកសាស្ត្រាចារ្យជំនួយ **ញឹក ឧុត្តី** ដែលបានណែនាំ ក្នុងការសរសេរសារណារបស់យើងខ្ញុំ ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃលះបង់អស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីជួយណែនាំផ្ដល់នូវដំបូន្មាន ក៏ដូចជាផ្ដល់នូវអនុសាសន៍ល្អៗ និងជួយកែលម្អនូវចំណុចខ្វះខាតទាំងឡាយ ដើម្បីធ្វើយ៉ាងណាឱ្យសារណាយើងខ្ញុំទទួលបាននូវសមិទ្ធិផលយ៉ាងល្អជាទីគាប់ប្រសើរ។

ជាកិច្ចបញ្ចប់ យើងខ្ញុំសូមជូនពរដល់អស់ លោក លោកស្រី សាស្ត្រាចារ្យ សិស្ស និស្សិត និងមិត្តអ្នកអានឱ្យជួបប្រទះតែសំណាងល្អ ទទួលបាននូវភាពជោគជ័យក្នុងជីវិត និងមានសុខភាពល្អ ជាពិសេសសូមឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល ០៤ឆ្នាំកន្លងមក យើងខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយទទួលបានចំណេះដឹងជំនាញនីតិសាស្ត្រលើមុខវិជ្ជាជាច្រើនទាំងផ្នែកនីតិឯកជន និងផ្នែកនីតិសាធារណៈ ក្រោមការខិតខំប្រឹងប្រែង ប្រកបដោយយកចិត្តទុកដាក់ អប់រំ ផ្តល់ដំបូន្មាន ណែនាំ បង្ហាត់បង្រៀនពីសំណាក់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យទាំងអស់។

ជាលទ្ធផល ដោយសារតែមានការជួយជ្រោមជ្រែង និងការយកចិត្តទុកដាក់ទាំងអស់នេះហើយ ធ្វើឱ្យយើងខ្ញុំមានឱកាសក្នុងការបង្ហាញស្នាដៃតាមរយៈការសិក្សាស្រាវជ្រាវ និងសរសេរចងក្រងសារណាមួយនេះ លេចចេញជារូបរាងឡើង ដែលជាចំណាងដៃក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្ររបស់យើងខ្ញុំ នៅក្រោមប្រធានបទ ស្តីពី "**នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ**" ក្នុងគោលបំណងអាចជួយពង្រឹងនូវចំណេះដឹងផ្នែកនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ឱ្យកាន់តែមានភាពងាយស្រួលច្បាស់លាស់ និងស៊ីជម្រៅបន្ថែមទៀត។ ហើយសង្ឃឹមថា កម្រងសារណានេះ នឹងចូលរួមជាចំណែកដ៏សំខាន់សម្រាប់ជាឯកសារស្រាវជ្រាវ បែបលក្ខណៈវិទ្យាសាស្ត្រថ្មីមួយ ដើម្បីជាមូលដ្ឋានដល់សិស្ស និស្សិត និងអ្នកស្រាវជ្រាវទាំងឡាយ ដែលកំពុងជួបការលំបាកក្នុងការស្រាវជ្រាវរកឯកសារបំពេញបន្ថែម ក្នុងអំឡុងពេលសិក្សារៀនសូត្រ។

ក្នុងនាមយើងខ្ញុំជានិស្សិតដែលបានធ្វើការស្រាវជ្រាវ រៀបចំ ចងក្រងសារណាមួយនេះឡើង យើងខ្ញុំសូមទទួលស្គាល់ថា ទោះបីជាសារណាមួយនេះត្រូវបានចងក្រងឡើង ដោយការខិតខំ ព្យាយាម ប្រឹងប្រែង យកចិត្តទុកដាក់ និងផ្ទៀងផ្ទាត់ យ៉ាងណាក្តី ក៏អាចនៅតែមានការភ្លេចភ្លាំង ខុសឆ្គងត្រង់ចំណុចណាមួយដោយអចេតនាជាក់ជាមិនខាន។ ដូច្នេះ យើងខ្ញុំសូមធ្វើការអភ័យទោសពីសំណាក់ សិស្សនិស្សិត អ្នកសិក្សាស្រាវជ្រាវ និងមិត្តអ្នកអានទាំងឡាយទុកជាមុននូវរាល់កំហុសខុសឆ្គង នូវចំណុចខ្វះខាតទៅលើឃ្លោងឃ្លាប្រយោគ ឬមានកំហុសអក្ខរាវិរុទ្ធទាំងឡាយដែលកើតមានឡើងដោយអចេតនា និងសូមស្វាគមន៍ជានិច្ចរាល់មតិយោបល់រិះគន់ក្នុងន័យស្ថាបនា ដើម្បីធ្វើការកែលម្អសារណាមួយនេះឱ្យកាន់តែប្រសើរឡើង។

ជាទីបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធិពរជ័យដល់ លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ហើយបានយកចិត្តទុកដាក់ ក្នុងការអានលើប្រធានបទមួយនេះ សូមឱ្យជួបប្រទះតែសំណាងល្អ សុខភាពល្អ និងទទួលបាននូវជោគជ័យគ្រប់ភារកិច្ច។

# <u>មាតិកា</u>

**ទំព័រ**


សេចក្តីផ្តើម ............................................................................................................ ១


## ជំពូកទី១

## សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ


**ផ្នែកទី១ ៖ កំណត់សម្គាល់ទូទៅនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ** ........... ៤

កថាភាគទី១ ៖ អត្ថន័យនៃការអនុវត្តដោយបង្ខំ ............................................................ ៤

១. គោលគំនិតនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ................................................. ៤

២. គោលបំណងនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ............................................... ៤

កថាភាគទី២ ៖ ភាគីនៃការអនុវត្ត និងអ្នកតំណាងដោយអាណត្តិ ........................................ ៥

១. ភាគីនៃការអនុវត្ត ............................................................................................... ៥

២. អ្នកតំណាងដោយអាណត្តិ ..................................................................................... ៦

កថាភាគទី៣៖ ស្ថាប័នអនុវត្ត ........................................................................................ ៧

១. តុលាការអនុវត្ត ................................................................................................... ៧

២. អាជ្ញាសាលា ....................................................................................................... ៨

**ផ្នែកទី២ ៖ សិទ្ធិអំណាច និងករណីយកិច្ចរបស់អាជ្ញាសាលា** ....................................... ៨

កថាភាគទី១៖ សិទ្ធិអំណាចរបស់អាជ្ញាសាលា ................................................................. ៩

១. សិទ្ធិប្រើកងកម្លាំង ឬនគរបាលយុត្តិធម៌ ................................................................... ៩

២. សិទ្ធិឆែកឆេររកចលនវត្ថុដែលអាចរឹបអូសបាន ....................................................... ៩

៣. សិទ្ធិជ្រើសរើសចលនវត្ថុដើម្បីរឹបអូស .................................................................. ១០

៤. ការអនុញ្ញាតឱ្យគ្រប់គ្រង និងប្រើប្រាស់ចលនវត្ថុដែលបានរឹបអូស ................................ ១០

៥. សិទ្ធិលុបចោលការរឹបអូស ................................................................................... ១០

៦. សិទ្ធិបញ្ចូលរឿងក្ដី ............................................................................................................១០
៧. សិទ្ធិជ្រើសតាំងអ្នកវាយតម្លៃ...................................................................................................១១
កថាភាគទី២ ៖ ករណីយកិច្ចរបស់អាជ្ញាសាលា.........................................................................................១១
១. ករណីយកិច្ចស្វែងរកអ្នកសង្កេតការណ៍.....................................................................................១១
២. ករណីយកិច្ចសុំការអនុញ្ញាតចុះអនុវត្តក្នុងថ្ងៃសម្រាក .......................................................................១១
៣. ករណីយកិច្ចត្រូវយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ .......................................................................១១
៤. ករណីយកិច្ចរក្សាសណ្ដាប់ធ្នាប់ក្នុងពេលអនុវត្តការលក់ .....................................................................១១
៥. ករណីយកិច្ចក្នុងការធ្វើកំណត់ហេតុ ............................................................................................ ១២

# ជំពូកទី២

# លក្ខខណ្ឌចម្បង និងលក្ខខណ្ឌចាំបាច់នៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

**ផ្នែកទី១ ៖ លក្ខខណ្ឌចម្បង នៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ**.............. ១៣
កថាភាគទី១ ៖ ពាក្យសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុ....................................................................... ១៣
កថាភាគទី២ ៖ លិខិតអនុវត្ត.................................................................................................... ១៣
កថាភាគទី៣ ៖ រូបមន្តអនុវត្ត.....................................................................................................១៦
កថាភាគទី៤ ៖ ការបង់សោហ៊ុយសម្រាប់ការអនុវត្ត ............................................................................ ១៧
កថាភាគទី៥ ៖ អាជ្ញាយុកាលនៃការអនុវត្ត ......................................................................................១៨
**ផ្នែកទី២ ៖ លក្ខខណ្ឌចាំបាច់ នៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ**.............១៨
កថាភាគទី១ ៖ ការបញ្ជូនលិខិតអនុវត្ត............................................................................................១៨
កថាភាគទី២ ៖ ការបញ្ជូនរូបមន្តអនុវត្ត និងលិខិតបញ្ជាក់ ....................................................................១៩
កថាភាគទី៣ ៖ ការមកដល់នៃពេលដែលត្រូវផ្ដល់តាវកាលិក ..................................................................១៩
កថាភាគទី៤ ៖ ការដាក់លិខិតបញ្ជាក់អំពីការដាក់ប្រាតិភោគ ................................................................. ២០
កថាភាគទី៥ ៖ ការផ្ដល់តាវកាលិកតប............................................................................................ ២០
កថាខណ្ឌទី៦ ៖ ឧបសគ្គចំពោះការអនុវត្ត ....................................................................................... ២១

## ជំពូកទី៣

## លំហូរនីតិវិធីនៃការចាប់ផ្ដើមអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

**ផ្នែកទី១ ៖ ការចាប់ផ្ដើមរៀបចំដាក់ពាក្យសុំលើការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ**.......... ២២

កថាភាគទី១ ៖ ការរៀបចំដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ.......... ២២

១. ការចរចារ ការជ្រើសរើស និងការស្រាវជ្រាវ.......... ២២

២. ការសរសេរពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ .......... ២៣

៣. ការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ.......... ២៤

កថាភាគទី២ ៖ ការពិនិត្យពាក្យសុំដោយអាជ្ញាសាលា .......... ២៤

១. សមត្ថកិច្ចអនុវត្ត .......... ២៥

២. ការសរសេរពាក្យសុំ.......... ២៥

៣. ការផ្ទៀងផ្ទាត់ភាគីនៃការអនុវត្ត .......... ២៦

៤. ឯកសារដែលត្រូវភ្ជាប់មកជាមួយពាក្យសុំ .......... ២៦

៥. លិខិតបញ្ជាក់អំពីការបង់សោហ៊ុយសម្រាប់ការអនុវត្ត .......... ២៧

៦. ឯកសារបញ្ជាក់ការបញ្ជូនលិខិតអនុវត្ត .......... ២៧

៧. ឯកសារបញ្ជាក់ការបញ្ជូលលិខិតអនុវត្តពិសេស .......... ២៧

៨. លិខិតបញ្ជាក់អំពីការផ្ដល់តាវកាលិក.......... ២៨

៩. ការដាក់លិខិតបញ្ជាក់អំពីការដាក់ប្រាតិភោគ .......... ២៨

១០. លិខិតបញ្ជាក់អំពីការផ្ដល់តាវកាលិកតប .......... ២៩

**ផ្នែកទី២ ៖ ដំណាក់កាលនៃការរឹបអូសចលនវត្ថុ** .......... ២៩

កថាភាគទី១ ៖ គោលការណ៍សំខាន់ៗនៃការអនុវត្ត .......... ២៩

១. គោលការណ៍នៃការរឹបអូស.......... ២៩

២. ចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស ..... ៣០
៣. ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស ..... ៣១
៤. ការប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស ..... ៣៣
៥. ការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ ..... ៣៤
៦. ការហាមឃាត់មិនឲ្យរឹបអូសក្នុងករណីដែលប៉ាន់ប្រមាណឃើញថាគ្មានចំនួនសេសសល់ ៣៤
កថាភាគទី២ ៖ ការអនុវត្តការរឹបអូសចលនវត្ថុ ..... ៣៥
១. វិធីរឹបអូសចលនវត្ថុ ..... ៣៥
១.១ ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត ..... ៣៥
១.២ ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយម្ចាស់បំណុល ..... ៣៧
១.៣ ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយតតិយជន ..... ៣៧
២. ការថែរក្សាវត្ថុដែលត្រូវបានរឹបអូស ..... ៣៨
២.១ គោលការណ៍នៃការកាន់កាប់ដោយអាជ្ញាសាលា ..... ៣៨
២.២ ការអនុញ្ញាតឱ្យគ្រប់គ្រងថែរក្សា ឬប្រើប្រាស់ចលនវត្ថុរឹបអូស ..... ៣៨
កថាភាគទី៣ ៖ អានុភាពនៃការរឹបអូសចលនវត្ថុ ..... ៣៩
១. ការហាមឃាត់មិនឲ្យកូនបំណុលធ្វើការចាត់ចែងលើចលនវត្ថុរឹបអូស ..... ៣៩
២.អានុភាពចំពោះផលធម្មជាតិ ..... ៤០
៣. ការរឹបអូសចលនវត្ថុដែលត្រូវបានរឹបអូសពីតតិយជន ..... ៤០
**ផ្នែកទី៣ ៖ ការប្តូរជាប្រាក់ និងការចែកចំណែក** ..... ៤១
កថាភាគទី១ ៖ ការប្តូរជាប្រាក់នូវទ្រព្យសម្បត្តិដែលបានរឹបអូស ..... ៤១
១. វិធីលក់ចលនវត្ថុដោយបង្ខំ ..... ៤១
២. បុគ្គលដែលមិនអនុញ្ញាតឲ្យដាក់សំណើទិញ ..... ៤២
៣. នីតិវិធីនៃការលក់ចលនវត្ថុដោយបង្ខំ ..... ៤៣

៤. ការលក់ចលនវត្ថុរឹបអូសក្នុងពេលដែលការអនុវត្តកំពុងត្រូវបានផ្អាក............................៤៥
៥. ការទទួលខុសត្រូវ និងសិទ្ធិអំណាចរបស់អាជ្ញាសាលាក្នុងពេលលក់............................៤៦
កថាភាគទី២ ៖ ការចែកចំណែក ..........................................................................៤៦
១. ការទាមទារឱ្យចែកចំណែក..........................................................................៤៦
១.១ ម្ចាស់បំណុលដែលមានសិទ្ធិទាមទារឱ្យចែកចំណែក..........................................៤៦
១.២ វិធីទាមទារឱ្យចែកចំណែក.......................................................................៤៧
១.៣ អត្ថិភាពក្នុងការទាមទារឱ្យចែកចំណែក..........................................................៤៨
២. ការអនុវត្តការចែកចំណែក ..........................................................................៤៩
២.១ ករណីដែលមានម្ចាស់បំណុលតែម្នាក់...........................................................៤៩
២.២ ករណីដែលមានម្ចាស់បំណុលច្រើននាក់ ........................................................៤៩
២.៣ វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក .........................................៥០
៣. អានុភាពនៃការចែកចំណែក..........................................................................៥០
៣.១ ការចាត់ទុកថាដល់ពេលកំណត់ត្រូវសង ........................................................៥០
៣.២ ការផ្ញើរប្រាក់ចំណែករបស់ម្ចាស់បំណុលទៅតុលាការ.........................................៥១
**សេចក្តីសន្និដ្ឋាន** ..........................................................................................៥២
**អនុសាសន៍** ...............................................................................................៥៤
**បញ្ជីឯកសារយោង**.........................................................................................៥៦
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

**ក្រមនីតិវិធីរដ្ឋប្បវេណី** ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ហើយក្រមនេះត្រូវយកមកអនុវត្តនៅទូទាំងប្រទេសនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៧ តាមបញ្ញត្តិនៃមាត្រា៥៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងមាត្រា៩៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ-កម្ពុជា។

ក្រមនេះមានមានត្រា ៥៨៨មាត្រា ដោយបែងចែកជា៩គន្លី រួមមាន គន្លីទី១ ស្តីពីបទបញ្ញត្តិទូទៅ (ពីមាត្រា១ ដល់មាត្រា៧៣) គន្លីទី២ ស្តីពីនីតិវិធីនៃការជម្រះក្តីលើកទី១ (ពីមាត្រា៧៤ ដល់មាត្រា២៥៨) គន្លីទី៣ ស្តីពីបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ (ពីមាត្រា២៥៩ ដល់មាត្រា៣០៦) គន្លីទី៤ ស្តីពីការជំនុំជម្រះសាជាថ្មី(ពីមាត្រា៣០៧ ដល់មាត្រា៣១៨) គន្លីទី៥ស្តីពីនីតិវិធីដាស់តឿន (ពីមាត្រា៣១៩ ដល់មាត្រា៣៣៣) គន្លីទី៦ ស្តីពីការអនុវត្តដោយបង្ខំ (ពីមាត្រា៣៣៤ ដល់មាត្រា៥២៩) គន្លីទី៧ ស្តីពីការចាត់ចែងរក្សាការពារ (ពីមាត្រា ៥៣០ ដល់មាត្រា៥៧១) គន្លីទី៨ស្តីពីអន្តរបញ្ញត្តិ(ពីមាត្រា ៥៧២ ដល់មាត្រា៥៨៦) និងគន្លីទី៩ស្តីពីអវសានប្បញ្ញត្តិ (ពីមាត្រា៥៨៧ ដល់មាត្រា៥៨៨)។

ដោយឡែក ចំពោះ **ការអនុវត្តដោយបង្ខំ** ស្ថិតនៅក្នុងគន្លីទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានចែកចេញជា៤ជំពូករួមមាន៖ ជំពូកទី១ស្តីពីបទប្បញ្ញត្តិទូទៅ (ពីមាត្រា៣៣៤ ដល់មាត្រា៣៧៨) ជំពូកទី២ ស្តីពីការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ (ពីមាត្រា៣៧៩ ដល់មាត្រា ៤៩៥) ជំពូកទី៣ ស្តីពីបទប្បញ្ញត្តិពិសេសស្តីពីការអនុវត្តសិទ្ធិប្រាតិភោគ (ពីមាត្រា៤៩៦ ដល់មាត្រា៥២៣) និង ជំពូកទី៤ ស្តីពីការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលគ្មានគោលបំណងឱ្យសងជាប្រាក់ (ពីមាត្រា៥២៤ ដល់មាត្រា៥២៩)។

ពាក់ព័ន្ធនិងប្រធានដែលក្រុមយើងខ្ញុំបានលើកយកមកសិក្សាស្រាវជ្រាវនេះ ដែលនិយាយអំពី "**នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ**" គឺជាប្រភេទមួយនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាម-ទារ ដែលមានគោលបំណងឱ្យសងជាប្រាក់ ហើយការអនុវត្តដោយបង្ខំប្រភេទនេះ ស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់អាជ្ញាសសាលា ដែលមានចែងចាប់ពីមាត្រា៣៨៤ រហូតដល់មាត្រា៤០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ** មានលក្ខណៈពិសេសជាងប្រភេទនៃការអនុវត្តដោយបង្ខំផ្សេងទៀត ដោយហេតុថានីតិវិធីនេះអាចត្រូវចំណាត់ការបានយ៉ាងឆាប់រហ័ស, ចំណាយសោហ៊ុយនៃការចំណាយសោហ៊ុយនៃការអនុវត្តក្នុងកម្រិតតិច ដំណើរការនៃនីតិវិធីមានលក្ខណៈងាយស្រួល ការអនុវត្តគោល-

ការណ៍ស្វ័យភាពខាងឆន្ទៈ ហើយជាពិសេសគឺផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្តអាចត្រូវទទួលបានការការពារក្នុងកម្រិតខ្ពស់ជាអាទិ៍។ ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺជាដំណើរការនៃការសម្រេចសិទ្ធិទាមទារឱ្យសងជាប្រាក់ របស់ម្ចាស់បំណុលនៃការអនុវត្ត ដែលផ្តើមដោយការស្នើសុំមកអាជ្ញាសាលា ឱ្យធ្វើការរឹបអូសនូវចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត ដើម្បីប្តូរជាប្រាក់តាមរយៈការលក់ឡាយឡុង ហើយយកប្រាក់នោះទៅសង (ចែកចំណែក) ឱ្យម្ចាស់បំណុលនៃការអនុវត្ត។

ទន្ទឹមនឹងនេះ បើយើងក្រឡេកមកមើលទិដ្ឋភាពទាំងស្រុង នៅប្រទេសកម្ពុជាយើងវិញ បានសង្កេតឃើញថា ប្រទេសកម្ពុជាបានអនុវត្តគោលនយោបាយស្របតាមសេដ្ឋកិច្ចទីផ្សារសេរី ដែលនៅក្នុងសង្គមបុគ្គលឯកជនម្នាក់ៗ ចូលរួមការអនុវត្តជីវភាពសេដ្ឋកិច្ចផ្ទាល់ខ្លួនតាមរយៈការដោះដូរ ការទិញ លក់ ទំនិញ សេវា ដោយប្រើប្រាស់នូវរូបិយវត្ថុជាចម្បង ឬត្រូវធ្វើឡើងតាមរយៈការសន្យារវាងបុគ្គលម្នាក់ និងបុគ្គលម្នាក់ទៀត ដោយបានសន្យាថានឹងគោរពសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនដោយសុចរិត ដោយបានអនុលោមតាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។ ប៉ុន្តែ បើស្ថិតក្នុងករណីដែលបុគ្គលឯកជន និងបុគ្គលឯកជនមានវិវាទជាមួយគ្នាត្រូវបានកើតឡើង ហើយមិនអាចដោះស្រាយបាន ឬត្រូវបានរំលោភបំពាននូវសិទ្ធិ នោះបុគ្គលឯកជនត្រូវទទួលបានការការពារសិទ្ធិដោយតុលាការ តាមរយៈការទាមទាររបស់បុគ្គលនោះ។ ចំណែកឯការដោះស្រាយវិវាទចំពោះបុគ្គលឯកជន ផ្នែករដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឱ្យបុគ្គលឯកជនណាមួយ ធ្វើការដោះស្រាយដោយប្រើប្រាស់កម្លាំងហិង្សា បង្ខិតបង្ខំ ឬការប្រើប្រាស់អំណាច រំលោភបំពាន គាបសង្កត់ទៅលើបុគ្គលផ្សេងទៀតឡើយ។ ផ្ទុយទៅវិញ បុគ្គលឯកជនត្រូវបានទទួលការការពារ នឹងធានានូវសិទ្ធិពឹងពាក់ដោយតុលាការ ដើម្បីធ្វើការដោះស្រាយក្នុងការសម្រេចសិទ្ធិទាមទាររបស់បុគ្គលនោះ តាមរយៈ "**នីតិវិធីនៃការអនុវត្តដោយបង្ខំ**" ។

"**នីតិវិធីនៃការអនុវត្តដោយបង្ខំ**" គឺជា នីតិវិធីមួយដែលមានសារៈសំខាន់ណាស់ ដើម្បីសម្រេចនូវសិទ្ធិទាមទារ របស់ម្ចាស់បំណុលនៃការអនុវត្តដែលមាននៅក្នុងលិខិតអនុវត្ត តាមរយៈការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ទៅស្ថាប័នអនុវត្ត ដោយម្ចាស់បំណុលនៃការអនុវត្ត។ ជាមួយគ្នានេះដែល ចំពោះការស្រាវជ្រាវ សារណានៃបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ក្រោមប្រធានបទ ស្តីពី "**នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ**" នេះផងដែរ គឺជាប្រភេទនៃការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ហើយការអនុវត្តដោយបង្ខំមួយប្រភេទនេះ គឺត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់អាជ្ញាសាលា នៃស្ថាប័នអនុវត្ត ដែលមានចាប់ពីមាត្រា៣៨៤ រហូតដល់មាត្រា៤០១ នៃក្រមនីតិវិធីរដ្ឋប្បវេណីដូចបានរៀបរាប់ខាងលើ។

**២. ចំណោទបញ្ហា**

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី "**ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ**" គឺផ្តោតទៅលើចំណុចដែលជាបញ្ហាសំខាន់ៗដែលរួមមានដូចជា៖

-តើអ្វីទៅជាការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ?

-តើស្ថាប័នអនុវត្តប្រភេទណា ដែលជាអ្នកទទួលបន្ទុកលើការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ?

-តើលំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុត្រូវចាប់ផ្តើម និងបញ្ចប់ទៅវិញនៅពេលណា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ប្រធានបទស្តីពី "**ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ**" ដែលយើងខ្ញុំបានយកមកសិក្សាស្រាវជ្រាវសរសេរចេញជាសារណានេះ ក្នុងគោលបំណងសិក្សាស្វែងយល់អំពីបែបបទនីតិវិធីមួយដ៏មានសារៈសំខាន់ដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

## ៤. សារៈសំខាន់នៃការជ្រើសរើសប្រធានបទ

អ្វីដែលជាសារៈសំខាន់សម្រាប់ប្រធានបទខាងលើនេះ គឺចង់បង្ហាញឱ្យអ្នកសិក្សាបានយល់ដឹង ដោយផ្អែកលើបញ្ហា និងទិដ្ឋភាពគ្រប់មជ្ឈដ្ឋាន ដើម្បីស្វែងយល់ឱ្យកាន់តែស៊ីជម្រៅអំពី ៖

-អត្ថន័យ ជារួមនៃនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

-គោលគំនិត និងគោលបំណង នៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

-បុគ្គលឯកជន នឹងអ្នកតំណាងដោយអាណត្តិ

-អ្នកតំណាងដោយអាណត្តិ នៃដំណើរការនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុទាំងមូល

-ស្ថាប័នអនុវត្តចំពោះចលនវត្ថុ

-សិទ្ធិអំណាច និងករណីយកិច្ចរបស់អាជ្ញាសាលា

-លក្ខខណ្ឌចម្បងនៃការអនុវត្ត និងលក្ខខណ្ឌចាំបាច់នៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

-លំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុទាំងមូល ។

## ៥. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ប្រធានបទ "**ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ**" នេះត្រូវបានធ្វើការបែងចែកជា៣ជំពូកដូចខាងក្រោម៖

**-ជំពូកទី១** សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

**-ជំពូកទី២** លក្ខខណ្ឌចម្បង និងលក្ខខណ្ឌចាំបាច់ នៃនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

**-ជំពូកទី៣** លំហូរនីតិវិធីនៃការចាប់ផ្តើមអនុវត្តដោយបង្ខំចំពោះចលនវត្ថុ។

# ជំពូកទី១
# សញ្ញាណទូទៅនៃនីតិវិធីអនុវត្តដោយបង្ខំ
# ចំពោះចលនវត្ថុ

# ជំពូកទី១

# សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

## ផ្នែកទី១ ៖ កំណត់សម្គាល់ទូទៅនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

### កថាភាគទី១ ៖ អត្ថន័យនៃការអនុវត្តដោយបង្ខំ

នីតិវិធីនៃការអនុវត្តដោយបង្ខំ គឺជានីតិវិធីមួយដែលឯករាជ្យហើយមានការអនុវត្តដោយអាជ្ញាធររដ្ឋផ្សេងពីអាជ្ញាធរដែលអនុវត្តតាមនីតិវិធីបណ្តឹង។ មានន័យថាការអនុវត្តដោយបង្ខំមិនមែនជានីតិវិធីបន្ទាប់បន្សំ ឬជានីតិវិធីបន្តពីនីតិវិធីបណ្តឹងទេ តែជានីតិវិធីមួយឯករាជ្យដែលត្រូវចាប់ផ្តើមឡើងតាមការដាក់ពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។ ទោះបីជានីតិវិធីនៃការអនុវត្តដោយបង្ខំជានីតិវិធីឯករាជ្យ ឬមិនមែនជានីតិវិធីបន្តពីនីតិវិធីបណ្តឹងយ៉ាងណាក្តី ប៉ុន្តែនីតិវិធីនៃការអនុវត្តដោយបង្ខំ ក៏មានលក្ខណៈស្រដៀងទៅនឹងនីតិវិធីបណ្តឹងខ្លះដែរ ត្រង់ថានៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ ក៏អនុញ្ញាតឱ្យភាគីម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្ត រួមទាំងតតិយជនធ្វើការតទល់គ្នាផងដែរ (មាត្រា៣៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)[1]។

### ១. គោលគំនិតនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

គោលគំនិតនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺជាការដាក់បន្ទុកដល់កូនបំណុលនៃការអនុវត្តដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត។ ដោយឡែកមុនពេលចាប់ផ្តើមនូវការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ម្ចាស់បំណុលនៃការអនុវត្ត តែងតែចង់ឱ្យកូនបំណុលនៃការអនុវត្ត បានអនុវត្តដោយស្ម័គ្រចិត្ត ដែលករណីនេះវាអាចនឹងទទួលបាននូវការចំណេញប្រាក់ និងពេលវេលា។ ប៉ុន្តែបើកូនបំណុលមិនអនុវត្តដោយស្ម័គ្រចិត្តនោះទេ ទើបការអនុវត្តដោយបង្ខំចំពោះចលនវត្ថុត្រូវបានចាប់ផ្តើមឡើង។

### ២. គោលបំណងនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺជាប្រភេទនៃការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ហើយកម្មវត្ថុនៃការអនុវត្តនេះគឺផ្តោតសំខាន់ទៅលើ "**ចលនវត្ថុ**" ។ ការអនុវត្តដោយបង្ខំប្រភេទនេះធ្វើឡើងក្រោមសមត្ថកិច្ចផ្តាច់មុខរបស់អាជ្ញាសាលា តាមវិធីរឹបអូសយកចលនវត្ថុ ដែលជាកម្មវត្ថុរបស់កូនបំណុលនៃការអនុវត្ត ដើម្បីជួយសម្រេចសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់របស់ម្ចាស់បំណុលនៃការអនុវត្ត ដែលសិទ្ធិទាមទារនោះមាននៅក្នុងលិខិតអនុវត្ត (មាត្រា៣៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)[2]។

---

[1] មាត្រា៣៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[2] មាត្រា៣៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

## កថាភាគទី២៖ ភាគីនៃការអនុវត្ត និងអ្នកតំណាងដោយអាណត្តិ

ចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ តួអង្គដែលមាននៅក្នុងនីតិវិធីនេះគឺ ភាគីនៃការអនុវត្ត និងអ្នកតំណាងដោយអាណត្តិ។ ភាគីនៃការអនុវត្តគឺជា បុគ្គលដែលបានដាក់ពាក្យស្នើសុំទៅស្ថាប័នអនុវត្ត ដើម្បីអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទជាមួយនឹងភាគីម្ខាងទៀតដែលទ្រព្យសម្បត្តិរបស់ភាគីម្ខាងទៀតនោះជាកម្មវត្ថុនៃការអនុវត្ត។ អ្នកតំណាងដោយអាណត្តិ គឺជាអ្នកតំណាងដែលកើតចេញពីការជ្រើសតាំងរបស់ភាគី តាមរយៈការប្រគល់សិទ្ធិតំណាងដោយអាណត្តិ។ ជាគោលការណ៍អ្នកតំណាងដោយអាណត្តិ គឺជាមេធាវី។

### ១. ភាគីនៃការអនុវត្ត

បុគ្គលទាំងឡាយណាដែលអាចមានលក្ខណសម្បត្តិជាភាគីបាន លុះត្រាតែបុគ្គលនោះមានសិទ្ធិ និងករណីយកិច្ចតាមផ្លូវច្បាប់។ នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ បុគ្គលដែលជាអ្នកដាក់ពាក្យសុំ ឬភាគីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំសម្រាប់ផលប្រយោជន៍របស់ខ្លួនហៅថា **"ម្ចាស់បំណុលនៃការអនុវត្ត ឬហៅដោយសាមញ្ញថា ម្ចាស់បំណុល"** ហើយភាគីម្ខាងទៀតនៃការអនុវត្តនោះហៅថា **"កូនបំណុលនៃការអនុវត្ត ឬហៅដោយសាមញ្ញថា កូនបំណុល"** (មាត្រា៣៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)[3] ។

ចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំ មិនមែនគ្រប់ភាគីជាដើមចោទនៃរឿងក្តី សុទ្ធតែជាម្ចាស់បំណុលនៃការអនុវត្តនោះទេ ទោះបីជារឿងក្តីអនុវត្តដោយបង្ខំនោះផ្អែកលើ សាលក្រម ឬសាលដីកាស្ថាពរក៏ដោយ។ មានករណីខ្លះដើមចោទនៅក្នុងរឿងក្តី អាចនឹងក្លាយទៅជាកូនបំណុលនៃការអនុវត្តទៅវិញ ម្យ៉ាងវិញទៀត ក៏អាចមានករណីខ្លះដែលបុគ្គលផ្សេងពីភាគីនៃការអនុវត្ត ក្លាយទៅជាម្ចាស់បំណុលនៃការអនុវត្ត ឬក្លាយជាកូនបំណុលនៃការអនុវត្តផងដែរ (មាត្រា៣៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)[4]។

ចំពោះការកំណត់សម្គាល់ថានរណាជាម្ចាស់បំណុលនៃការអនុវត្ត ហើយនរណាជាកូនបំណុលនៃការអនុវត្តនៅក្នុងរឿងក្តីនៃការអនុវត្តដោយបង្ខំនោះ គឺត្រូវកំណត់តាមការរៀបរាប់នៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរ ពោលគឺថាតើនរណាជាអ្នកដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ សម្រាប់ផលប្រយោជន៍របស់ខ្លួន ហើយសុំឱ្យអនុវត្តចំពោះនរណា។ បុគ្គលផ្សេងពីនេះគ្រាន់តែជាតតិយជនតែប៉ុណ្ណោះនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ បើទោះបីជាពួកគេជាម្ចាស់បំណុលនៃការអនុវត្ត ឬជាកូនបំណុលនៃការអនុវត្តពិតប្រាកដនៅក្នុងច្បាប់សារធាតុក៏ដោយ ។

[3] មាត្រា៣៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[4] មាត្រា៣៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ដូច្នេះ នៅពេលធ្វើការអនុវត្តដោយបង្ខំ ស្ថាប័នអនុវត្តត្រូវពិនិត្យមើល និងកំណត់អំពីសញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្តឱ្យបានច្បាស់លាស់ ដោយត្រូវបញ្ជាក់ឱ្យច្បាស់អំពីបុគ្គលដែលជាភាគីអាចទាមទារឱ្យធ្វើការអនុវត្តដោយបង្ខំបាន និងភាគីម្ខាងទៀត នៅក្នុងលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ដែលត្រូវភ្ជាប់មកជាមួយនូវពាក្យសុំឱ្យអនុវត្តដោយបង្ខំដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ ដោយឡែក ចំពោះករណីលិខិតអនុវត្តដែលមិនចាំបាច់ទទួលអំពីការផ្តល់រូបមន្តអនុត្ត គឺមានត្រឹមតែការបញ្ជាក់ពីដើមចោទ និងចុងចម្លើយ ក៏ដូចជាបញ្ជាក់ពី ម្ចាស់បំណុល និងកូនបំណុល នៅក្នុងលិខិតអនុវត្តដែលមានអានុភាពអនុវត្តនោះ ជាការគ្រប់គ្រាន់ហើយ (មាត្រា៣៥៤ កថាខណ្ឌទី១ ចំណុច ក ដល់ គ)។

**២. អ្នកតំណាងដោយអាណត្តិ**

អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ គឺត្រូវតែជាបុគ្គលដែលមានសិទ្ធិស្របច្បាប់ ក្នុងការធ្វើសកម្មភាពនៃកិច្ចនីតិវិធីអនុវត្តដោយបង្ខំ ក្នុងនាមជាភាគីនៃការអនុវត្ត (កូនបំណុលនៃការអនុវត្ត ឬម្ចាស់បំណុលនៃការអនុវត្ត)នៅចំពោះមុខតុលាការអនុវត្ត ហើយរាល់សកម្មភាពរបស់អ្នកតំណាងដោយអាណត្តិត្រូវបានចាត់ទុកថាជាសកម្មភាពរបស់ភាគី។

ជាគោលការណ៍ បុគ្គលដែលមានលក្ខណសម្បត្តិដែលអាចក្លាយជាអ្នកតំណាងដោយអាណត្តិនៅក្នុងនីតិវិធីអនុវត្តដោយបង្ខំបាន គឺមានតែមេធាវីតែប៉ុណ្ណោះ (មេធាវីជាអ្នកវិជ្ជាជីវៈ ដែលមានចំណេះដឹងផ្នែកច្បាប់ក្នុងការការពារផលប្រយោជន៍ស្របច្បាប់របស់ភាគី)។

ជាគោលការណ៍ បទប្បញ្ញត្តិនៃអ្នកតំណាងដោយអាណត្តិដែលច្បាប់បានកំណត់ នៅក្នុងនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំ។ ដោយឡែកចំពោះលក្ខណសម្បត្តិរបស់អ្នកតំណាងដោយអាណត្តិវិញ ក៏មានបញ្ញត្តិពិសេសផងដែរ (មាត្រា៣៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ គោលបំណងនៃបញ្ញត្តិពិសេសនៃអ្នកតំណាងដោយអាណត្តិនេះ គឺដើម្បីជួយសម្រួលដល់ការបំពេញលក្ខណសម្បត្តិរបស់អ្នកតំណាងដោយអាណត្តិ ដោយយល់ឃើញថា នៅក្នុងការអនុវត្តដោយបង្ខំ ជាទូទៅស្ថាប័នអនុវត្ត គឺជាអ្នកធ្វើនូវនីតិវិធីដែលបានចែងទុក ដោយផ្អែកលើសិទ្ធិអំណាចរបស់ខ្លួន ហើយសកម្មភាពរបស់ភាគី ក៏មិនមានលក្ខណៈស្មុគស្មាញនោះទេ។

តួយ៉ាង ដូចជានីតិវិធីបណ្តឹង ឬបណ្តឹងជំទាស់ដែលពាក់ព័ន្ធទៅនឹងនីតិវិធីនៃការអនុវត្តដោយបង្ខំត្រូវអនុលោមទៅតាមបទបញ្ញត្តិនៃ (មាត្រា៥៣ កថាខណ្ឌទី១)[5] និង (មាត្រា៣៤៨ កថាខណ្ឌទី១ ចំណុចក)[6]។ មូលហេតុនៃការចែងបែបនេះព្រោះថានីតិវិធីទាំងនេះគឺជាមូលដ្ឋានដូចទៅនឹងនីតិវិធីបណ្តឹង ឬនីតិវិធីដែលស្រដៀង

[5] មាត្រា៥៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[6] មាត្រា៣៤៨ កថាខណ្ឌទី១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ទៅនឹងនីតិវិធីបណ្តឹង។ ហេតុនេះហើយបានជានៅក្នុងនីតិវិធីទាំងនេះ ជាទូទៅមានតែមេធាវីតែប៉ុណ្ណោះដែលអាចធ្វើជាអ្នកតំណាងដោយអាណត្តិបាន។

**ឧទាហរណ៍៖** ចំពោះពាក្យបណ្តឹងតវ៉ារបស់តតិយជន បើជាការតវ៉ាចំពោះការរឹបអូសដោយតុលាការអនុវត្តត្រូវដាក់ទៅតុលាការអនុវត្តនោះ ប៉ុន្តែបើជាការតវ៉ារបស់អាជ្ញាសាលា ត្រូវដាក់ទៅសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ។ ក្នុងករណី ដូចនៅក្នុងឧទាហរណ៍នេះ ជាគោលការណ៍អ្នកតំណាងដោយអាណត្តិត្រូវតែជាមេធាវី (មាត្រា៣៦៥ កថាខណ្ឌទី២)។

**កថាភាគទី៣ ៖ ស្ថាប័នអនុវត្ត**

ស្ថាប័នអនុវត្ត គឺជាស្ថាប័នដែលទទួលបន្ទុកកាន់អំណាចធ្វើការអនុវត្តដោយបង្ខំដែលជាអំណាចរបស់រដ្ឋ។ មានន័យថា មានតែស្ថាប័នអនុវត្តទេដែលមានសិទ្ធិចាត់ចែងលើនីតិវិធីនាំការអនុវត្តដោយបង្ខំបាន ពោលគឺពុំមានស្ថាប័នណាផ្សេង ដែលអាចអនុវត្តដោយបង្ខំបានឡើយ។

ការអនុវត្តដោយបង្ខំធ្វើឡើងដោយស្ថាប័នអនុវត្ត តាមរយៈការដាក់ពាក្យសុំរបស់ភាគីដែលនៅក្នុងនោះរួមមាន តុលាការអនុវត្ត និងអាជ្ញាសាលា ដែលស្ថាប័នអនុវត្តទាំងពីប្រភេទនេះ គឺជាស្ថាប័នឯករាជ្យនៃអំណាចតុលាការ។ ស្ថាប័នទាំងពីនេះមានចរឹកលក្ខណៈផ្សេងពីគ្នា ហេតុនេះហើយបានជាច្បាប់បានដាក់បន្ទុកការងារផ្សេងពីគ្នាទៅតាមស្ថាប័ននីមួយៗ ដោយអាស្រ័យទៅតាមកម្មវត្ថុនៃការអនុវត្ត និងទៅតាមប្រភេទនៃការអនុវត្តដោយបង្ខំ (មាត្រា៣៣៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)[7]។

តួយ៉ាងដោយសារតែ នីតិវិធីនៃការអនុវត្តដោយបង្ខំ គឺជានីតិវិធីដាច់ដោយឡែក និងឯករាជ្យពីនីតិវិធីបណ្តឹង ដូច្នេះវាមិនចាំបាច់ដែលតុលាការទទួលបន្ទុកពាក្យបណ្តឹង ត្រូវតែជាស្ថាប័នអនុវត្តនោះទេ។ ផ្ទុយទៅវិញការផ្ទុកផ្តាក់ឱ្យស្ថាប័នមួយផ្សេងពីតុលាការអនុវត្តដែលទទួលបន្ទុកក្នុងការអនុវត្តដោយបង្ខំ គឺមានលក្ខណៈសមស្របបំផុតដែលនាំឱ្យមានភាពងាយស្រួល និងឆាប់រហ័សក្នុងការអនុវត្តនីតិវិធី។ ហេតុដូច្នេះ ច្បាប់បានតម្រូវឱ្យតុលាការអនុវត្ត និងអាជ្ញាសាលា គឺជាស្ថាប័នអនុវត្ត។

**១. តុលាការអនុវត្ត**

តុលាការអនុវត្ត គឺជាតុលាការដែលមានភារកិច្ចធ្វើការអនុវត្តដោយបង្ខំ ឬដែលធ្វើការពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ បើផ្អែកតាមនិយមន័យចង្អៀត ហៅថា "**តុលាការអនុវត្ត**" ។ ច្បាប់ពុំបានបង្កើតឱ្យមានតុលាការពិសេសពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំទេ ពោលគឺតុលាការអនុវត្ត គឺជាសាលាដំបូងដែលត្រូវមានសិទ្ធិអនុវត្ត

[7] មាត្រា៣៣៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ដោយបង្ខំ (មាត្រា៣៣៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)[8]។ យោងតាមបញ្ញត្តិនេះ ស្ថាប័នសម្រេចសេចក្តីដែលមានចៅក្រមជាសាលាដំបូងដែលជាអង្គភាពរដ្ឋ គឺជាតុលាការអនុវត្ត។

ចំពោះប្រភេទនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ តុលាការអនុវត្តមិនមែនជាអ្នកទទួលបន្ទុកឯករាជ្យ ក្នុងនាមជាស្ថាប័នអនុវត្តនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុនោះទេ។ ប៉ុន្តែ តុលាការអនុវត្តមានតួនាទីសម្រាប់ផ្តល់កិច្ចសហការ និងមើលការខុសត្រូវលើនីតិវិធីនៃការអនុវត្តដែលស្ថិតនៅក្រោមបន្ទុករបស់អាជ្ញាសាលា តុលាការអនុវត្តមានសិទ្ធិអំណាចក្នុងការអនុញ្ញាតឱ្យអាជ្ញាសាលាអនុវត្តលើថ្ងៃឈប់សម្រាក ឬពេលយប់ (មាត្រា៣៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងការប្តូរទំហំចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូសជាអាទ៍ (មាត្រា៣៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**២. អាជ្ញាសាលា**

អាជ្ញាសាលា គឺជាស្ថាប័នយុត្តាធិការឯករាជ្យមួយ ដែលទទួលបន្ទុកធ្វើការបញ្ជូនឯកសារនានាដែលចេញដោយតុលាការ ហើយអាជ្ញាសាលាក៏មានតួនាទីធ្វើការអនុវត្តដោយបង្ខំមួយចំនួនដែលច្បាប់បានកំណត់។ អាជ្ញាសាលាជាមន្ត្រីរាជការដែលត្រូវតែងតាំងដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ចេញពីក្នុងចំណោមបុគ្គលដែលបានបំពេញគ្រប់លក្ខខណ្ឌទាមទារមួយចំនួន។ ក៏ប៉ុន្តែ អាជ្ញាសាលាខុសពីមន្ត្រីរាជការទូទៅ ដោយអាជ្ញាសាលាមិនត្រូវបានទទួលប្រាក់ខែពីរដ្ឋទេ ផ្ទុយទៅវិញអាជ្ញាសាលាគឺទទួលបានចំណូលពីប្រាក់កម្រៃពីអ្នកដាក់ពាក្យសុំចំពោះការអនុវត្តតាមមុខងាររបស់ខ្លួនទៅវិញ ដែលនេះជាចរិកលក្ខណៈមួយរបស់អាជ្ញាសាលា។

ចំពោះមុខនាទីរបស់អាជ្ញាសាលា ក៏ត្រូវបានកម្រិតទៅតាមមុខតំបន់នៃការបំពេញមុខនាទីរបស់ខ្លួនផងដែរ ដែលមុខនាទីរបស់អាជ្ញាសាលាត្រូវបានកម្រិតនៅតំបន់ដែនសមត្ថកិច្ចរបស់សាលាដំបូង ដែលខ្លួនបំពេញការងារ។ តួយ៉ាង ចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺអាជ្ញាសាលាជាអ្នកទទួលបន្ទុកឯករាជ្យ ក្នុងនាមជាស្ថាប័នអនុវត្ត (មាត្រា៣៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)[9]។

## ផ្នែកទី២ ៖ សិទ្ធិអំណាច និងករណីកិច្ចរបស់អាជ្ញាសាលា

នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ អាជ្ញាសាលាគឺជាភាគីមួយដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការចុះអនុវត្តនីតិវិធីដោយផ្ទាល់ ដើម្បីធ្វើការរឹបអូសនូវទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្តក្នុងការយកចលនវត្ថុនោះមកលក់ឡាយឡុងដើម្បីប្តូរជាប្រាក់ សម្រាប់ការបែងចែកទ្រព្យសម្បត្តិនោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត។

---

[8] មាត្រា៣៣៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[9] មាត្រា៣៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ដោយឡែក ការចុះអនុវត្តរបស់អាជ្ញាសាលាដើម្បីរឹបអូសនូវទ្រព្យសម្បត្តិនោះ គឺពិតជាមានឧបសគ្គយ៉ាងខ្លាំង ដោយហេតុថាករណីខ្លះកូនបំណុលនៃការអនុវត្តមានការប្រឆាំង ឬមានការតវ៉ាចំពោះការរឹបអូសនោះ ហើយអាចនិងកើតមានជាអំពើហិង្សាណាមួយមកលើអាជ្ញាសាលាដែលបានចុះរឹបអូសនូវទ្រព្យសម្បត្តិនោះ ដែលធ្វើឱ្យមានភាពលំបាកក្នុងការអនុវត្ត និងអាចធ្វើឱ្យខាតបង់ផលប្រយោជន៍យ៉ាងធ្ងន់ធ្ងររបស់ម្ចាស់បំណុលនៃការអនុវត្ត ដែលបានឈ្នះក្តីនោះ។

ដើម្បីជៀសវាងនូវឧបសគ្គទាំងឡាយ ដែលអាចកើតមានឡើងនៅពេលចុះអនុវត្តនីតិវិធីរបស់អាជ្ញាសាលានោះ ច្បាប់បានប្រគល់នូវសិទ្ធិអំណាច និងករណីយកិច្ចដល់អាជ្ញាសាលាដើម្បីផ្តល់ភាពងាយស្រួល និងសុវត្ថិភាពដល់ការអនុវត្តនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដែលមានសិទ្ធិអំណាច និងករណីយកិច្ចដូចខាងក្រោម៖

**កថាភាគទី១៖ សិទ្ធិអំណាចរបស់អាជ្ញាសាលា**

**១. សិទ្ធិប្រើកងកម្លាំង ឬនគរបាលយុត្តិធម៌**

អាជ្ញាសាលាអាចធ្វើការចុះអនុវត្តនីតិវិធីដោយឯកឯងបាន ក្នុងករណីដែលពុំមានការរារាំងណាមួយពីសំណាកកូនបំណុលនៃការអនុវត្ត ឬតតិយជនផ្សេងទៀត។ ប៉ុន្តែប្រសិនបើមានឧបសគ្គដែលកើតមានក្នុងអំឡុងពេលអនុវត្តនោះ អាជ្ញាសាលាអាចប្រើប្រាស់កងកម្លាំង ឬនគរបាលដែលមានសមត្ថកិច្ច ដើម្បីជួយសម្រួលដល់ការអនុវត្តនីតិវិធីរបស់ខ្លួន (មាត្រា៣៣៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)[10]។

ដោយឡែកនៅក្នុងការអនុវត្តជាក់ស្តែង នៅមុនពេលដែលអាជ្ញាសាលាធ្វើការចុះអនុវត្ត អាជ្ញាសាលាតែងស្នើសុំជំនួយពីកងកម្លាំង ឬនគរបាលមានសមត្ថកិច្ចជាមុនដើម្បីជៀសវាងបញ្ហាដែលអាចកើតមានឡើងដោយមិនអាចដឹងមុនបាន ហើយបែបបទនៃការស្នើសុំកម្លាំងនគរបាលមានលក្ខណៈផ្សេងគ្នា អាស្រ័យទៅតាមតំបន់រដ្ឋបាលគ្រប់គ្រងដូចជានៅតាមបណ្តាខេត្តខ្លះ ការស្នើសុំកម្លាំងនគរបាលចូលរួមអនុវត្តដោយបង្ខំចាំបាច់ត្រូវមានការឯកភាពពីគណៈបញ្ជាការឯកភាពខេត្ត ពោលគឺចាំបាច់ត្រូវមានយល់ព្រមពីអភិបាលខេត្តតែម្តង ទើបបញ្ជូនទៅមន្ត្រីមូលដ្ឋានជាក្រោយឱ្យចូលរួមអនុវត្ត។ ប៉ុន្តែនៅតំបន់ខ្លះទៀត ការស្នើកម្លាំងនគរបាលបានចូលរួមអនុវត្តគឺត្រូវធ្វើឡើងត្រឹមសាលាខណ្ឌទៅជាការស្រេច។

**២. សិទ្ធិឆែកឆេររកចលនវត្ថុដែលអាចរឹបអូសបាន**

ជាធម្មតា ប្រសិនបើកូនបំណុលបានដឹងមុនថា អាជ្ញាសាលាអាចនិងធ្វើការរឹបអូសចលនវត្ថុរបស់ខ្លួននោះ កូនបំណុលអាចនិងប្រើគ្រប់មធ្យោបាយដើម្បីយកចលនវត្ថុរបស់ខ្លួននោះប្តូរទីតាំងរក្សាទុក ឬយកទៅលាក់ទុកនៅកន្លែងណាមួយដែលធ្វើឱ្យអាជ្ញាសាលាពុំអាចរឹបអូសចលនវត្ថុរបស់ខ្លួនបាន។ ក្នុងករណីនេះអាជ្ញាសាលានៃការអនុវត្តអាចធ្វើការចូលទៅកាន់ទីកន្លែងរបស់កូនបំណុលដើម្បីធ្វើការឆែកឆេររកចលនវត្ថុរបស់កូនបំណុល

[10] មាត្រា៣៣៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ដើម្បីរឹបអូសចលនវត្ថុនោះបាន (មាត្រា៣៨៥ កថាខណ្ឌទី២ វាក្យខណ្ឌទី១ និងវាក្យខណ្ឌទី២)[11]។ ប្រសិនបើមានភាពចាំបាច់ អាជ្ញាសាលាអាចធ្វើការចាត់ចែងចាំបាច់ដើម្បីបើកទ្វារទូដែកដែលបិទ និងប្រអប់ផ្សេងទៀតបាន។

### ៣. សិទ្ធិជ្រើសរើសចលនវត្ថុដើម្បីរឹបអូស

នៅពេលចុះអនុវត្តរឹបអូសចលនវត្ថុ អាជ្ញាសាលាមានសិទ្ធិជ្រើសរើសចលនវត្ថុដើម្បីធ្វើការរឹបអូសបានក្នុងលក្ខខណ្ឌពុំធ្វើឱ្យមានការខូចខាតដល់ផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត[12]។

**ឧទាហរណ៍៖** នៅពេលចុះដល់ទីតាំងដែលត្រូវធ្វើការរឹបអូស អាជ្ញាសាលាសង្កេតឃើញមានចលនវត្ថុជាច្រើនសុទ្ធតែអាចធ្វើការរឹបអូសបាន ហេតុដូច្នេះអាជ្ញាសាលាមានសិទ្ធិគ្រប់គ្រាន់ក្នុងការជ្រើសរើសនូវចលនវត្ថុដើម្បីធ្វើការរឹបអូស។

### ៤. ការអនុញ្ញាតឱ្យគ្រប់គ្រង និងប្រើប្រាស់ចលនវត្ថុដែលបានរឹបអូស

ជាគោលការណ៍ អានុភាពនៃការរឹបអូសត្រូវបានកើតឡើងតាមរយៈការកាន់កាប់ដោយអាជ្ញាសាលា ប៉ុន្តែបើយល់ឃើញថា មានផលលំបាកក្នុងការដឹកជញ្ជូន ឬចំណាយច្រើនក្នុងការរក្សាចលនវត្ថុដែលត្រូវបានរឹបអូសនោះ អាជ្ញាសាលាអាចអនុញ្ញាតឱ្យកូនបំណុលនៃការអនុវត្តរក្សា ឬប្រើប្រាស់ចលនវត្ថុនោះបាន ដោយតម្រូវឱ្យបិតស្លាក ឬដាក់សញ្ញាលើចលនវត្ថុនោះ (មាត្រា៣៨៥ កថាខណ្ឌទី៤ និងកថាខណ្ឌទី៥) [13]។

### ៥. សិទ្ធិលុបចោលការរឹបអូស

អាជ្ញាសាលា យល់ឃើញថាករណីរឹបអូសចលនវត្ថុ មានទំហំហួសប្រមាណ ឬករណីប៉ាន់ប្រមាណថាគ្មានចំនួនសេសសល់ ឬចលនវត្ថុដែលត្រូវបានរឹបអូសមិនអាចប្តូរជាប្រាក់បាន អាជ្ញាសាលា អាចលុបចោលការរឹបអូសទាំងនោះបាន (មាត្រា៣៩១, មាត្រា៣៩២, មាត្រា៣៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)[14] ។

### ៦. សិទ្ធិបញ្ចូលរឿងក្តី

ក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តដោយបង្ខំលើចលនវត្ថុថ្មីមួយទៀតចំពោះកូនបំណុលនៃការអនុវត្ត និងកន្លែងអនុវត្តដដែលនោះ ហើយព្រមទាំងគ្មានចលនវត្ថុណាសម្រាប់រឹបអូសជាថ្មីទេ ឬក៏មានពាក្យសុំឱ្យបញ្ចូលរឿងក្តីនោះ អាជ្ញាសាលាអាចបញ្ចូលរឿងក្តីនេះបាន (មាត្រា៨៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)[15]។

[11] មាត្រា៣៨៥ កថាខណ្ឌទី២ វាក្យខណ្ឌទី១ និងវាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[12] មាត្រា៣៨៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[13] មាត្រា៣៨៥ កថាខណ្ឌទី៤ និងកថាខណ្ឌទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[14] មាត្រា៣៩១, មាត្រា៣៩២, មាត្រា៣៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[15] មាត្រា៨៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

### ៧. សិទ្ធិជ្រើសតាំងអ្នកវាយតម្លៃ

ប្រសិនបើចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ដោយបង្ខំមានតម្លៃខ្ពស់ អាជ្ញាសាលាអាចចាត់តាំងអ្នកវាយតម្លៃ ហើយឱ្យអ្នកវាយតម្លៃនោះធ្វើការវាយតម្លៃលើចលនវត្ថុនោះបាន (មាត្រា៣៩៥ កថាខណ្ឌទី៧)[16]។

## កថាភាគទី២ ៖ករណីយកិច្ចរបស់អាជ្ញាសាលា

### ១. ករណីយកិច្ចស្វែងរកអ្នកសង្កេតការណ៍

នៅពេលដែលអាជ្ញាសាលាបានចូលទៅដល់ទីតាំងដែលខ្លួនត្រូវចុះអនុវត្តនោះ ហើយមិនបានជួបនិងអ្នកចម្បងនៃទីកន្លែងរស់នៅ ឬអ្នកតំណាងរបស់អ្នកនោះ ឬញាតិនៅជាមួយ ឬអ្នកបម្រើ ឬអ្នកផ្សេងពីអ្នកដែលធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យទេ នោះអាជ្ញាសាលាត្រូវឱ្យមានវត្តមានអ្នកសង្កេតការណ៍ដែលរួមមានដូចជាមន្ត្រីឃុំ-សង្កាត់ មន្ត្រីនគរបាល ឬអ្នកផ្សេងទៀតដែលអាចទទួលស្គាល់ថាជាសាក្សីសមរម្យបាន[17]។

### ២. ករណីយកិច្ចសុំការអនុញ្ញាតចុះអនុវត្តក្នុងថ្ងៃសម្រាក

ដើម្បីចូលទៅបំពេញមុខនាទីក្នុងទីកន្លែងរស់នៅ នៅថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកដែលច្បាប់ ឬបទដ្ឋានគតិយុត្តបានកំណត់ ឬពីម៉ោងប្រាំមួយល្ងាច ដល់ម៉ោងប្រាំមួយព្រឹកនៃថ្ងៃបន្ទាប់ អាជ្ញាសាលាត្រូវទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅ[18]។

នៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលា ត្រូវបង្ហាញលិខិតបញ្ជាក់ថាខ្លួនទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅរួចហើយ។

### ៣. ករណីយកិច្ចត្រូវយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ

នៅក្នុងប្រតិបត្តិការក្នុងការបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលាត្រូវយកតាមខ្លួននូវលិខិតបញ្ជាក់អត្តសញ្ញាណ ឬលក្ខណៈសម្បត្តិរបស់ខ្លួន ហើយត្រូវបង្ហាញលិខិតនេះ ចំពោះជនដែលពាក់ព័ន្ធនិងផលប្រយោជន៍បើជននោះទាមទារ[19]។

### ៤. ករណីយកិច្ចក្នុងការក្សោសណ្តាប់ធ្នាប់ក្នុងពេលអនុវត្តការលក់

ក្នុងពេលប្រតិបត្តិការលក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះ ប្រសិនបើមានជនណាដែលធ្វើសកម្មភាពរំខានកុំឱ្យការរំខានការអនុវត្តការលក់ដោយមិនត្រឹមត្រូវ ដូចជាបានធ្វើសកម្មភាពរំខានដល់ជនដទៃក្នុងការធ្វើ

[16] មាត្រា៣៩៥ កថាខណ្ឌទី៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[17] មាត្រា៣៣៩ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋបវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[18] មាត្រា៣៤០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋបវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[19] មាត្រា៣៤១ នៃក្រមនីតិវិធីរដ្ឋបវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

សំណើរទិញ ឬបានឃុបឃិតដើម្បីបញ្ចុះតម្លៃដោយមិនត្រឹមត្រូវជាអាទិ៍ អាជ្ញាសាលាអាចហាមបុគ្គលមួយចំនួនមិនឱ្យចូលទៅកន្លែងលក់ ឬអាចបណ្តេញចេញជននោះពីកន្លែងលក់ ឬអាចមិនឱ្យស្នើសុំទិញបាន[20]។

### **៥. ករណីយកិច្ចក្នុងការធ្វើកំណត់ហេតុ**

កំណត់ហេតុ គឺជាកិច្ចការសំខាន់ដែលអាជ្ញាសាលាមិនអាចរំលងបាន ហើយអាជ្ញាសាលាត្រូវធ្វើកំណត់ហេតុនៅរាល់ពេលបំពេញមុខនាទីរបស់ខ្លួន ដូចជាការរឹបអូសចលនវត្ថុ ការលក់ឡាយឡុងចលនវត្ថុ ការចែកចំណែក ជាអាទិ៍[21] ។

នៅក្នុងកំណត់ហេតុនោះ អាជ្ញាសាលាត្រូវធ្វើការកត់ត្រានូចចំណុចដូចខាងក្រោមនេះ ហើយត្រូវសរសេរឈ្មោះ និងចុះហត្ថលេខា៖

- សញ្ញាណរឿងក្តី
-ពេលវេកា និងទីកន្លែងដែលបំពេញមុខនាទី
-ខ្លឹមសារនៃកិច្ចការដែលបានចាត់ចែង
-និងថ្ងៃខែឆ្នាំដែលបានធ្វើកំណត់ហេតុ។

[20] មាត្រា៣៩៦ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋបវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[21] ប្រការ១២ កថាខណ្ឌទី១ នៃប្រកាសលេខ៣០ អយ.ប្រក, ១៩ កក្កដា ២០០៧

# ជំពូកទី២
# លក្ខខណ្ឌចាំបាច់ និងលក្ខខណ្ឌចម្បង
# នៃនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

# ជំពូកទី២

## លក្ខខណ្ឌចម្បង និងលក្ខខណ្ឌចាំបាច់នៃនិតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

### ផ្នែកទី១ ៖ លក្ខខណ្ឌចម្បងនៃនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

លក្ខខណ្ឌចម្បង គឺជាលក្ខខណ្ឌគ្រឹះនៃការអនុវត្តដោយបង្ខំដែលក្នុងនោះជាគោលការណ៍ ដើម្បីអាចឱ្យស្ថាប័នអនុវត្តអាចអនុវត្តដោយបង្ខំបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្ត បានបំពេញនូវលក្ខខណ្ឌចម្បងនៃការអនុវត្តដោយបង្ខំជាមុនសិន។ លក្ខខណ្ឌចម្បងនៃការអនុវត្តដោយបង្ខំនោះរួមមានដូចក្នុងកថាភាគខាងក្រោម៖

**កថាភាគទី១ ៖ ពាក្យសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុ**

នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ត្រូវធ្វើឡើងដោយស្ថាប័នអនុវត្តតាមរយៈពាក្យសុំរបស់ភាគី ហើយពាក្យសុំនោះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរទៅស្ថាប័នអនុវត្តដែលមានសមត្ថកិច្ច[22]។ ទន្ទឹមនឹងនេះពាក្យសុំជាលាយលក្ខណ៍អក្សរនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ត្រូវធ្វើឡើយដោយផ្អែកតាមលិខិតចម្លងយថាភូតនៃលិខិតអនុវត្ត [23]។

**កថាភាគទី២ ៖ លិខិតអនុវត្ត**

ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកតាមលិខិតអនុវត្ត។ លិខិតអនុវត្ត គឺជាឯកសារដែលបញ្ជាក់ពីសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកជាក់លាក់ណាមួយ ដែលកំណត់នៅក្រោមនីតិឯកជន ហើយដោយផ្អែកលើឯកសារនេះ ច្បាប់ត្រូវផ្តល់ឱ្យនូវសិទ្ធិអំណាចបង្ខំអនុវត្ត ដើម្បីសម្រេចនូវអត្ថន័យនៃសិទ្ធិនោះ តាមរយៈការអនុវត្តដោយបង្ខំ (មាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)[24] ។

ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយផ្អែកតាមលិខិតអនុវត្ត មានន័យថា ស្ថាប័នអនុវត្តពុំអាចចាប់ផ្តើមអនុវត្តបានទេ ប្រសិនបើពុំមានលិខិតអនុវត្តភ្ជាប់ជាមួយនូវពាក្យសុំឱ្យអនុវត្តដោយបង្ខំ លើកលែងតែការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ដែលអាជ្ញាសាលាអាចធ្វើការចាប់ផ្តើមការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុបានដោយពុំចាំបាច់មានលិខិតអនុវត្តឡើយ។ ពោលគឺគ្រាន់តែម្ចាស់បំណុលនៃការអនុវត្ត ប្រគល់ចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគនោះមកឱ្យអាជ្ញាសាលា ឬដាក់លិខិតបញ្ជាក់ថាអ្នកកាន់កាប់ចលនវត្ថុនោះយល់ព្រមប្រគល់ឱ្យអាជ្ញាសាលាជាការស្រេច (មាត្រា៥០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) [25]។

---

[22] មាត្រា៣៣៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[23] មាត្រា៣៤៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[24] មាត្រា៣៥០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[25] មាត្រា៥០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែលត្រូវធ្វើឡើងផ្អែកតាមលិខិតអនុវត្ត ហើយលិខិតអនុវត្តនោះរួមមានដូចខាងក្រោម[26]៖

- **សាលក្រម ឬសាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ៖** ជាគោលការណ៍ មិនគ្រប់សាលក្រម ឬសាលដីកាចុងក្រោយ សុទ្ធតែមានអានុភាពអនុវត្តនោះទេ ពោលគឺមានតែសាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកតែប៉ុណ្ណោះ ទើបអាចមានអានុភាពអនុវត្តដោយបង្ខំបាន។ ចំពោះសាលក្រម ឬសាលដីកាបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃទំនាក់ទំនងគតិយុត្តិវិញដូចជា ការសាលក្រមបញ្ជាក់អំពីអត្ថិភាពនៃបុត្តភាព ជាអាទិ៍ គឺពុំមានអានុភាពអនុវត្តដោយបង្ខំទេ។ ករណីនេះគឺម្ចាស់បំណុលនៃការអនុវត្តត្រូវធ្វើការអនុវត្តដោយខ្លួនឯង ដូចជាការយកសាលក្រមនោះ ទៅចុះឈ្មោះនៅមុខមន្ត្រីអត្រានុកូលដ្ឋានជាដើម ។ល។
- **សាលក្រម ឬសាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន៖** លិខិតអនុវត្តប្រភេទនេះគឺ ស្រដៀងទៅនឹងលិខិតអនុវត្ត ដែលជាប្រភេទនៃសាលក្រម ឬសាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរដែរ ។ ប៉ុន្តែ គ្រាន់តែខុសគ្នាត្រង់ថា នៅក្នុងរឿងក្តីនេះ មិនទាន់បានបញ្ចប់ជាស្ថាពរទេ ពោលគឺស្ថិតនៅជាកម្មវត្ថុនៃឧបាស្រ័យនៅឡើយ ។ លិខិតអនុវត្តប្រភេទនេះ នៅតែមានអានុភាពអនុវត្តដដែល ប្រសិនបើនៅក្នុងសាលក្រម ឬសាលដីកានោះភ្ជាប់ជាមួយនូវការប្រកាសអំពីការអនុវត្តបណ្តោះអាសន្ន ។ ករណីនេះគេអាចរកឃើញនៅមាត្រានៃក្រមនីតិវិធីរដ្ឋប្បវេណីមួយចំនួនដូចជា៖ (មាត្រា១៩៦ "ការប្រកាសអំពីការអនុវត្តបណ្តោះអាសន្ន" , មាត្រា២៧១ "ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នដោយតុលាការនៃបណ្តឹងឧទ្ធរណ៍" , មាត្រា២៧៨ "ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នក្នុងសាលដីកានៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍" , មាត្រា២៩៨ "ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននៅតុលាការកំពូល" ។
- **ដីកាសម្រេចបង្គាប់ឲ្យផ្តល់តាវកាលិក៖** ជាគោលការណ៍ ដីកាសម្រេចត្រូវមានអានុភាពអនុវត្តភ្លាមបន្ទាប់ពីមានការជូនដំណឹង (មាត្រា២១៣ កថាខណ្ឌទី១) ។ ដីកាសម្រេចដែលមានអានុភាពអនុវត្តភ្លាមនោះរួមមានដូចជា ដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្តប្រគល់លិខិតបញ្ជាក់អំពីសិទ្ធិលើបំណុល (មាត្រា៤៩៦ កថាខណ្ឌទី២) , ដីកាសម្រេចដែលបង្គាប់ឱ្យបង់ជាមុននូវសោហ៊ុយចាំបាច់សម្រាប់ការអនុវត្តជំនួស (មាត្រា៥២៧ កថាខណ្ឌទី៤) , ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ដើម្បីធានាកាតព្វកិច្ច នៅក្នុងវិធានបង្ខំដោយប្រយោល (មាត្រា៥២៨ កថាខណ្ឌទី១) ។ល។ ប៉ុន្តែចំពោះដីកា

[26] មាត្រា៣៥០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

សម្រេចដែលមិនត្រូវមានអានុភាពបើមិនទាន់ចូលជាស្ថាពរវិញ មានកម្រិតតែដីកាសម្រេចនោះបានចូលជាស្ថាពរ ដែលក្នុងនោះអាចជា ដីកាសម្រេចបង្គាប់ឱ្យផ្តល់អចលនវត្ថុ (មាត្រា៤៥០ កថាខណ្ឌទី៥) , ដីកាសម្រេចបង្គាប់ឱ្យប្រគល់នាវា (មាត្រា៤៨៣កថាខណ្ឌទី៥) ។ល។

- **ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន៖** ករណីនេះប្រសិនបើកូនបំណុលនៃការអនុវត្តមិនបានដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ឬ ប្រសិនបើដីកាសម្រេចលើកចោលលើ ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនបានចូលជាស្ថាពរ នោះការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ត្រូវភ្ជាប់ជាមួយនឹងដីកាសម្រេចដាស់តឿន ដែលអាចក្លាយជាលិខិតអនុវត្តបាន (មាត្រា៣២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- **ការចាត់ចែងរបស់ក្រឡាបញ្ជីដែលបានកំណត់អំពីចំនួននៃប្រាក់ប្រដាប់ក្តី៖** បន្ទាប់ពីតុលាការបានវិនិច្ឆ័យអំពីភាគ និងប្រាក់ប្រដាប់ក្តីហើយ ចំនួនទឹកប្រាក់លម្អិតត្រូវកំណត់ដោយក្រឡាបញ្ជីនៃសាលាដំបូងតាមពាក្យសុំរបស់ភាគី (មាត្រា៦៦ កថាខណ្ឌទី១)។ ភាគីម្ខាងអាចធ្វើកាតអនុវត្តដោយបង្ខំ ឱ្យភាគីម្ខាងទៀតសងប្រាក់ប្រដាប់ក្តី ដោយការចាត់ចែងរបស់ក្រឡាបញ្ជីនេះដើម្បីធ្វើជាលិខិតអនុវត្ត។
- **លិខិតយថាភូតដែលធ្វើដោយសារការី៖** លិខិតយថាភូតដែលធ្វើដោយសារការី ចំពោះការទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់មានកំណត់។ ប៉ុន្តែមានកម្រិតតែលិខិតដែលបញ្ជាក់សេចក្តីថ្លែងការណ៍ថាកូនបំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ។
- **សាលក្រម ឬ សាលដីការបស់តុលាការបរទេស ដែលមានសាលក្រមអនុវត្តដែលបានចូលជាស្ថាពរ៖** ប្រសិនបើសាលក្រម ឬសាលដីការបស់តុលាការបរទេស បានបំពេញគ្រប់លក្ខខណ្ឌមួយចំនួន សាលក្រម ឬសាលដីកាបរទេសនោះ នឹងត្រូវបានអនុវត្តទទួលស្គាល់អានុភាពដូច សាលក្រម ឬសាដីកាស្ថាពររបស់តុលាការកម្ពុជាដែរ (មាត្រា១១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- **សេចក្តីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្តដែលបានចូលជាស្ថាពរ៖** នីតិវិធីមជ្ឈិត្តកម្ម គឺជានីតិវិធីដោះស្រាយវិវាទជំនួសឱ្យនីតិវិធីបណ្តឹង ហើយសេចក្តីសម្រេចមជ្ឈិត្តករ ដែលជាលទ្ធផលនៃនីតិវិធីនេះ មានអានុភាពចងចំពោះភាគីដូចសាលក្រម ឬសាលដីកាស្ថាពរដែរ។ ប៉ុន្តែដើម្បីធ្វើការអនុវត្តដោយបង្ខំ ដោយផ្អែកលើសេចក្តីសម្រេចមជ្ឈិត្តករ ទោះបីជាសេចក្តីសម្រេចមជ្ឈិត្តករក្នុងប្រទេសក៏ដោយ បរទេសក៏ដោយត្រូវទទួលដីកាសម្រេចអនុវត្ត របស់តុលាការនៅព្រះរាជាណាចក្រកម្ពុជា (មាត្រា ៣៥៣ កថាខណ្ឌទី១) , តាមបញ្ញត្តិនៃមាត្រា ៣៥៣ (ដីកាសម្រេចអនុវត្តសេចក្តីសម្រេច មជ្ឈត្តករ)។

- **កំណត់ហេតុដែលមានអានុភាពដូចសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរ៖** កំណត់ហេតុដែលបានទទួលស្គាល់ការទាមទារ និងកំណត់ហេតុនៃការសះជាតាមផ្លូវតុលាការ (មាត្រា២២២) សុទ្ធតែត្រូវបានរាប់ចូលជាកំណត់ហេតុដែលមានអានុភាពដូចសាលក្រម ឬសាលដីកាស្ថាពរ។

**កថាភាគទី៣ ៖ រូបមន្តអនុវត្ត**

ការអនុវត្តដោយបង្ខំ មិនត្រឹមតែធ្វើឡើងដោយផ្អែកលើឯកសារចម្លងលិខិតយថាភូតនៃលិខិតអនុវត្តតែប៉ុណ្ណោះទេ តែក៏ត្រូវមានការភ្ជាប់មកជាមួយនូវរូបមន្តអនុវត្តជាមួយគ្នាផងដែរ ។ រូបមន្តអនុវត្តគឺជាឯកសារដែលក្រឡាបញ្ជី ឬសារការី សរសេរភ្ជាប់បន្ថែមនូវផ្នែកខាងក្រោម នៃឯកសារចម្លងលិខិតយថាភូតនៃលិខិតអនុវត្តដែលបញ្ជាក់ជាផ្លូវការនូវអត្ថិភាព និងអត្ថន័យនៃអំណាចបង្ខំឱ្យអនុវត្ត នៃលិខិតអនុវត្តនោះ [27]។

ហេតុផលដែលតម្រូវឱ្យភ្ជាប់បន្ថែមនូវរូបមន្តអនុវត្តទៅនឹងលិខិតអនុវត្តមានដូចខាងក្រោម៖

- ដោយសារតែស្ថាប័នអនុវត្តមិនមែនជាតុលាការនៃបណ្តឹងទេហេតុដូច្នេះវាមិនមែនជាការសមស្របទេ បើឱ្យស្ថាប័នអនុវត្តធ្វើការវិនិច្ឆ័យទៅលើអានុភាពនៃលិខិតអនុវត្ត នៅពេលដែលមានពាក្យសុំអនុវត្តដោយបង្ខំម្តងៗ ដែលការណ៍នេះ នឹងនាំឲ្យមានការយឺតយ៉ាវនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ ។
- នៅក្នុងករណីដែលការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយចំពោះបុគ្គលផ្សេងពីអ្នកដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តថាជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត នោះជាភាពចាំបាច់ត្រូវធ្វើការស្រាវជ្រាវថាតើបុគ្គលនោះ ជាបុគ្គលដែលត្រូវទទួលឥទ្ធិពលនៃអានុភាពអនុវត្តនៃលិខិតអនុវត្តឬទេ (តើបុគ្គលនោះ មានលក្ខណៈជាភាគីនៃការអនុវត្តដោយបង្ខំដែរឬទេ?) ហើយប្រសិនបើបុគ្គលនោះ ជាបុគ្គលដែលត្រូវទទួលឥទ្ធិពលនៃអានុភាពអនុវត្តនៃលិខិតអនុវត្តនោះ ត្រូវសរសេរបន្ថែមនៅក្នុងលិខិតអនុវត្ត ដោយរៀបរាប់ចំណុចនោះ ក្រោមទម្រង់ជារូបមន្តអនុវត្ត ។

ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយផ្អែកតាម ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានភ្ជាប់ជាមួយ នឹងរូបមន្តអនុវត្ត លើកលែងតែឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដូចបានរៀបរាប់ខាងក្រោមនេះ[28] ដែលអាចធ្វើការអនុវត្តដោយបង្ខំបាន ដោយមិនចាំបាច់តម្រូវឲ្យមានភ្ជាប់ជាមួយនូវរូបមន្តអនុវត្តសាលក្រមនៃបណ្តឹងរឿងក្តីទឹកប្រាក់តិចដែលបានចូលជាស្ថាពរ , សាលក្រមនៃបណ្តឹងរឿងក្តីទឹកប្រាក់តិចដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន និងដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនូវការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន[29] ។

---

[27] មាត្រា៣៥៤ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[28] មាត្រា៣៥៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[29] មាត្រា៣៥៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ប្រសិនបើមានហេតុការណ៍ដូចខាងក្រោម ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តពិសេស[30] ៖

-សិទ្ធិទាមទារដែលបានកំណត់ក្នុងលិខិតអនុវត្ត មានភ្ជាប់ជាមួយនូវល័ក្ខខ័ណ្ឌបង្អង់។

-សិទ្ធិទាមទារដែលបានកំណត់ក្នុងលិខិតអនុវត្ត មានភ្ជាប់ជាមួយនូវពេលកំណត់មិនពិតប្រាកដ។

-យកបុគ្គលផ្សេងក្រៅពីភាគីដែលបានកំណត់ក្នុងលិខិតអនុវត្ត ធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុត្ត។

### កថាភាគទី៤ ៖ ការបង់សោហ៊ុយសម្រាប់ការអនុវត្ត

ជាទូទៅដើម្បីចាប់ផ្តើមនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុបាន ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់សោហ៊ុយនៃការអនុវត្ត ដែលសោហ៊ុយសម្រាប់ការអនុវត្តនេះ គឺជាផ្នែកដ៏សំខាន់មិនអាចខ្វះបាននៅពេលចាប់ផ្តើមអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដែលជាកម្មវត្ថុនៃសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត។ ដូចនេះស្ថាប័នអនុវត្តត្រូវការចាំបាច់ត្រូវបង់សោហ៊ុយសម្រាប់ការអនុវត្ត ដើម្បីធ្វើការអនុវត្តបាន។

នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ សោហ៊ុយសម្រាប់ការអនុវត្ត សំដៅទៅលើពន្ធដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ, សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ និងសោហ៊ុយភាគី ដែលមានការរៀបរាប់ដូចខាងក្រោម៖

- **ពន្ធដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ (មាត្រា៣៧២) ៖** សំដៅទៅលើម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំនៅស្ថាប័នអនុវត្ត ។ ពន្ធដាក់ពាក្យសុំអាចប្រែប្រួលអាស្រ័យទៅតាម ស្ថាប័នអនុវត្តដែលទទួលពាក្យសុំនោះ ។ ក្នុងករណីដែលពាក្យសុំត្រូវទទួលដោយតុលាការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធដាក់ពាក្យសុំចំនួន ១០,០០០ (មួយម៉ឺន) រៀល ។ ដោយឡែក បើក្នុងករណីដែលពាក្យសុំត្រូវទទួលដោយអាជ្ញាសាលា នោះម្ចាស់បំណុលនៃការអនុវត្ត ត្រូវបង់ពន្ធដាក់ពាក្យសុំចំនួន ៥,០០០ (ប្រាំពាន់) រៀល (ប្រការ១៣ នៃប្រកាសលេខ ៣០ កយប ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌។
- **សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ (មាត្រា៣៧៣)៖** សំដៅលើចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ ជាសោហ៊ុយចាំបាច់សម្រាប់ការបញ្ជូនឯកសារ ឬធ្វើសកម្មភាពផ្សេង ដើម្បីធ្វើនីតិវិធីនៃការអនុវត្តដោយបង្ខំ ។ តាមមាត្រា ៣៥ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា និង ប្រការ ១៥ នៃប្រកាសលេខ ៣០ កយ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០០៧ របស់ក្រសួងយុត្តិធម៌ ។ **ឧទាហរណ៍៖** ការបញ្ជូនលិខិតអនុវត្ត ដែលបានកំណត់ក្នុង (មាត្រា៣៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ជាអាទិ៍។

[30] មាត្រា៣៥៦ កថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

- **សោហ៊ុយភាគី (មាត្រា៣៧៤)៖** សំដៅលើសោហ៊ុយក្រៅបីពន្ធដាក់ពាក្យសុំ ដែលតុលាការទទួលស្គាល់ចាំបាច់ ដើម្បីធ្វើការអនុវត្តដោយបង្ខំ ត្រូវចាត់ទុកជាសោហ៊ុយភាគី។ សោហ៊ុយភាគីនេះក៏សំដៅផងដែរថាជាសោហ៊ុយសម្រាប់ម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្តត្រូវចេញទៅឱ្យអ្នកផ្សេងក្រៅពីតុលាការអនុវត្ត និងអាជ្ញាសាលា ដើម្បីធ្វើការអនុវត្តដោយបង្ខំនោះ។ តាមមាត្រា៣៥ នៃសេចក្ដីព្រាងច្បាប់ស្ដីពីអាជ្ញាសាលា និងប្រការ១៥ នៃប្រកាសលេខ ៣០ កយ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌។

  **ឧទាហរណ៍៖** សោហ៊ុយសម្រាប់ផ្ញើឯកសារដូចជា ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ឬសោហ៊ុយសម្រាប់ធ្វើការចុះបញ្ជីផ្សេងទៀត ជាអាទិ៍ ។ល។

នៅពេលដែលមានការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅកាន់ស្ថាប័នអនុវត្ត អ្នកដាក់ពាក្យសុំត្រូវបង់ជាមុននូវចំនួនទឹកប្រាក់ដែលស្ថាប័នអនុវត្តកំណត់ថា ជាសោហ៊ុយចាំបាច់សម្រាប់ការធ្វើនីតិវិធីនៃការអនុវត្តដោយបង្ខំ។ បើអ្នកដាក់ពាក្យសុំមិនបានបង់សោហ៊ុយជាមុនទេ នោះស្ថាប័នអនុវត្តអាចចេញដីកាសម្រេចលើកចោលនីតិវិធីនៃការអនុវត្តដោយបង្ខំនោះបាន។

### កថាភាគទី៥ ៖ អំឡុងពេលនៃការអនុវត្ត (អាជ្ញាយុកាល)

ចំពោះករណីដែលការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ត្រូវធ្វើឡើងដោយផ្អែកតាមឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលជាសាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្ដល់តាវកាលិកដែលបានចូលជាស្ថាពរ នាំឱ្យពាក្យសុំអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តនេះមិនអាចធ្វើបានឡើយ ប្រសិនបើអំឡុងពេល ០៥ឆ្នាំ បានកន្លងហួសគិតចាប់ពីថ្ងៃនៃសាលក្រម ឬសាលដីកានោះបានចូលជាស្ថាពរ។ ដោយហេតុថា សិទ្ធិលើបំណុលដែលបានកំណត់ក្នុងសាលក្រម ឬសាលដីកាស្ថាពរនឹងត្រូវបានរលត់ដោយអាជ្ញាយុកាល ក្នុងអំឡុងពេល ០៥ឆ្នាំ ដោយគិតចាប់ពីថ្ងៃចូលជាស្ថាពរនៃសាលក្រម ឬសាលដីកានោះ (មាត្រា៤៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)[31]។

## ផ្នែកទី២ ៖ លក្ខខណ្ឌចាំបាច់ នៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

### កថាភាគទី១ ៖ ការបញ្ជូនលិខិតអនុវត្ត

ការបញ្ជូនលិខិតអនុវត្ត នៅក្នុងនីតិវិធីអនុវត្តដោយបង្ខំ អាចធ្វើបានតែក្នុងករណីដែលឯកសារចម្លងយថាភូត ឬឯកសារដែលមានសេចក្ដីចម្លងយថាភូតដែលមានសេចក្ដីបញ្ជាក់ ត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្តជាមុន (មាត្រា៣៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)[32] ។ នៅក្នុងករណីដែលរូបមន្តអនុវត្តត្រូវបានផ្ដល់ តាមប្បញ្ញត្តិនៃមាត្រា៣៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី (រូបមន្តអនុវត្តពិសេស) នៃក្រមនេះ ឯកសារចម្លងដែលមាន

[31] មាត្រា៤៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

[32] មាត្រា៣៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

សេចក្តីបញ្ជាក់នៃរូបមន្តអនុវត្ត និងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃឯកសារដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់ តាមបញ្ញត្តិនៃមាត្រា៣៥៦ នោះ ក៏ត្រូវបញ្ជូនទៅជាមុនផងដែរ។

មូលហេតុដែលតម្រូវឱ្យមានការបញ្ជូនលិខិតអនុវត្តជាអាទិ៍នោះ ព្រោះនៅពេលចាប់ផ្តើមអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គេត្រូវធ្វើការជូនដំណឹងទៅកូនបំណុលនៃការអនុវត្តថានីតិវិធីនៃការអនុវត្តដោយបង្ខំនឹងចាប់ផ្តើមចំពោះសិទ្ធិលើបំណុលណាមួយ ក្នុងគោលបំណងផ្តល់ឱកាសការពារខ្លួនដល់កូនបំណុលនៃការអនុវត្ត។ ប៉ុន្តែក្នុងករណីដែលធ្វើការអនុវត្តដោយបង្ខំដោយយកសាលក្រមស្ថាពរ ឬយកសាលដីកាស្ថាពរធ្វើជាលិខិតអនុវត្ត សាលក្រម ឬសាលដីកានោះ ត្រូវបានបញ្ជូនទៅឱ្យភាគីរួចទៅហើយ ដូច្នេះនៅពេលចាប់ផ្តើមការអនុវត្តដោយបង្ខំពុំចាំបាច់បញ្ជូនសាជាថ្មីទៀតទេ។ ការបញ្ជូននេះចាំបាច់ត្រូវធ្វើ "**ជាមុន**" ប៉ុន្តែ ចំពោះពេលវេលាច្បាស់លាស់ដែលត្រូវបញ្ជូនវិញ គឺខុសគ្នាទៅតាមប្រភេទនៃការអនុវត្ត។ ក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ អាជ្ញាសាលាគ្រាន់តែអាចធ្វើការបញ្ជូននៅពេលជាមួយគ្នានឹងការចាប់ផ្តើមការអនុវត្តនៅទីកន្លែងនោះបាន។

### កថាភាគទី២ ៖ ការបញ្ជូនរូបមន្តអនុវត្ត និងលិខិតបញ្ជាក់

ជាគោលការណ៍ រូបមន្តអនុវត្តមិនចាំបាច់ត្រូវធ្វើការបញ្ជូនដូចលិខិតអនុវត្តទេ។ ប៉ុន្តែក្នុងករណីដែលការអនុវត្តដោយបង្ខំជាប់ពាក់ព័ន្ធជាមួយនឹងលក្ខខណ្ឌបង្អង់ ឬការមកដល់នូវពេលកំណត់មិនពិតប្រាកដ (មាត្រា៣៥៦ កថាខណ្ឌទី១) ឬករណីដែលការអនុវត្តដោយបង្ខំ ដោយយកបុគ្គលផ្សេងពីភាគីដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត មកធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្ត (មាត្រា៣៥៦ កថាខណ្ឌទី២) ដែលទាមទារឱ្យការផ្តល់ "រូបមន្តអនុវត្តពិសេស" នោះការអនុវត្តដោយបង្ខំក៏ត្រូវទាមទារជាពិសេស នូវការបញ្ជូនរូបមន្តអនុវត្តពិសេសនោះដែរ នៅពេលចាប់ផ្តើមការអនុវត្តដោយបង្ខំ (មាត្រា៣៦០ វាក្យខណ្ឌទី២) [33]។

ម្យ៉ាងវិញទៀត ប្រសិនបើរូបមន្តអនុវត្តត្រូវបានផ្តល់ដោយផ្អែកលើឯកសារដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់មក នោះក៏ត្រូវធ្វើការបញ្ជូនឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នោះផងដែរ (មាត្រា៣៦០ វាក្យខណ្ឌទី២)។

### កថាភាគទី៣ ៖ ការមកដល់នៃពេលដែលត្រូវផ្តល់តាវការលិក

ពេលមកដល់នៃពេលដែលត្រូវផ្តល់តាវកាលិក គឺជាដំណាក់កាលដែលត្រូវចាប់ផ្តើមកំណត់អំពីលក្ខខណ្ឌនៃការចាប់ផ្តើមអនុវត្ត។ លក្ខខណ្ឌនៃការចាប់ផ្តើមអនុវត្ត គឺជាលក្ខខណ្ឌសារធាតុចាំបាច់ក្នុងការអនុវត្តដោយបង្ខំ ប៉ុន្តែនៅពេលដែលស្ថាប័នអនុវត្តចាប់ផ្តើមធ្វើនីតិវិធីអនុវត្តដោយបង្ខំបាន ស្ថាប័នអនុវត្តត្រូវស្រាវជ្រាវ និងធ្វើការសម្រេចទៅលើលក្ខខណ្ឌនោះដោយខ្លួនឯង។

---

[33] មាត្រា៣៦០ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ក្នុងករណីសិទ្ធិលើបំណុលដែលបានកំណត់ក្នុងលិខិតអនុវត្ត ភ្ជាប់ជាមួយនឹងពេលកំណត់ពិតប្រាកដ ស្ថាប័នអនុវត្តអាចចាប់ផ្តើមអនុវត្តដោយបង្ខំបាន លុះត្រាតែពេលកំណត់នោះបានមកដល់[34] ។

**ឧទាហរណ៍៖** បង្គាប់ឱ្យចុងចម្លើយសងប្រាក់ ៥០,០០០.០០ USD ទៅឱ្យដើមចោទ ចាប់ពីខែសីហា ឆ្នាំ ២០២៣ តទៅ ។

**កថាភាគទី៤ ៖ ការដាក់លិខិតបញ្ជាក់អំពីការដាក់ប្រាតិភោគ**

ក្នុងករណីដែលការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយផ្អែកលើលិខិតអនុវត្ត ដែលមានដាក់លក្ខខណ្ឌ ត្រូវដាក់ប្រាតិភោគដើម្បីចាប់ផ្តើមការអនុវត្តដោយបង្ខំនោះស្ថាប័នអនុវត្តត្រូវធ្វើការស្រាវជ្រាវអំពីករណីនេះ ដោយឱ្យម្ចាស់បំណុលនៃការអនុវត្ត ដាក់លិខិតបញ្ជាក់ថាខ្លួនបានដាក់ប្រាតិភោគនោះរួចហើយ មុននឹងចាប់ផ្តើមការអនុវត្តដោយបង្ខំ[35] ។

**ឧទាហរណ៍៖** បង្គាប់ឱ្យដើមចោទដាក់ប្រាតិភោគជាទឹកប្រាក់ ៥០,០០០.០០ USD ដើម្បីអនុវត្តសាលក្រមដែលមានភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ។

**កថាភាគទី៥ ៖ ការផ្តល់តាវកាលិកតប**

ក្នុងករណីតាវកាលិករបស់កូនបំណុលនៃការអនុវត្តត្រូវបានផ្តល់ដោយប្តូរនឹងតាវកាលិកតបស្ថាប័នអនុវត្ត អាចចាប់ផ្តើមការអនុវត្តដោយបង្ខំបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបានបញ្ជាក់ថាខ្លួនបានផ្តល់តាវកា-លិកនោះ ឬបានស្នើផ្តល់តាវកាលិកតបនោះ[36]។ ក្នុងករណីនេះត្រូវយកមកអនុវត្ត ចំពោះការអនុវត្តដោយបង្ខំដោយផ្អែកលើសាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិក ដោយប្តូរជាមួយតាវកាលិកតប ជាដើម។ មូលហេតុដែលយកការអនុវត្តផ្តល់តាវកាលិកតប ឬសំណើអនុវត្តតាវកាលិកតប មកធ្វើជាលក្ខខណ្ឌនៃការអនុវត្តនេះ គឺដើម្បីរក្សាទុកនូវទំនាក់ទំនងនៃការអនុវត្តព្រមគ្នាដែលបានចែងក្នុងច្បាប់សារធាតុនៅក្នុងការអនុវត្តដោយបង្ខំ។ បើក្នុងករណីដែលការអនុវត្តដោយបង្ខំ ដោយយកការអនុវត្តតាវកាលិកតប ឬសំណើអនុវត្តតាវកាលិក ជាលក្ខខណ្ឌនៃការផ្តល់រូបមន្តអនុវត្តទៅវិញ នោះនឹងបណ្តាលឱ្យម្ចាស់បំណុលនៃការអនុវត្តនឹងធ្វើការអនុវត្តមុន (មាត្រា៣៦១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)[37]។

**ឧទាហរណ៍៖** បង្គាប់ឱ្យចុងចម្លើយសងប្រាក់ចំនួន ៥០,០០០.០០ USD ទៅឱ្យដើមចោទ ហើយដើមចោទត្រូវប្រគល់ឯកសារច្បាប់ដើមនៃប័ណ្ណកម្មសិទ្ធិទៅចុងចម្លើយវិញ ។

---

[34] មាត្រា៣៦១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[35] មាត្រា៣៦១ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[36] មាត្រា៣៦១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[37] មាត្រា៣៦១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

**កថាភាគទី៦ ៖ ឧបសគ្គចំពោះការអនុវត្ត**

ឧបសគ្គចំពោះការអនុវត្ត សំដៅដល់ហេតុការដែលរារាំងក្នុងការចាប់ផ្ដើម ឬបន្តនីតិវិធីនៃការអនុវត្តដោយបង្ខំ ពោលគឺលក្ខខណ្ឌអវិជ្ជមានសម្រាប់ការអនុវត្ត។ ឧបសគ្គចំពោះការអនុវត្តគឺជាហេតុដែលនឹងក្លាយជាឧបសគ្គសម្រាប់ការអនុវត្តទាំងស្រុង ដែលក្លាយជាឧបសគ្គពិសេសក្នុងការធ្វើសកម្មភាពណាមួយក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ។

**ឧទាហរណ៍៖** ការបើកសំណុំរឿងក្ស័យធន (មាត្រា១៩ នៃច្បាប់ស្តីពីក្ស័យធន) [38]។

សរុបជារួមមក ដើម្បីឱ្យស្ថាប័នអនុវត្តអាចអនុវត្តដោយបង្ខំបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបានបំពេញនូវលក្ខខណ្ឌនៃការអនុវត្តដែលច្បាប់បានតម្រូវជាមុនសិន ពុំដូចនោះទេស្ថាប័នអនុវត្តពុំអាចធ្វើការអនុវត្តដោយបង្ខំបានទេ។

[38] មាត្រា១៩ នៃច្បាប់ស្តីពីក្ស័យធន

# ជំពូកទី៣
# លំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះ
# ចលនវត្ថុ

# ជំពូកទី៣
# លំហូរនីតិវិធីនៃការចាប់ផ្តើមអនុវត្តដោយបង្ខំចំពោះចលនវត្ថុ
## ផ្នែកទី១ ៖ ការចាប់ផ្តើមរៀបចំដាក់ពាក្យសុំលើការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ
### កថាភាគទី១ ៖ ការរៀបចំដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

ជាគោលការណ៍ ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយស្ថាប័នអនុវត្តតាមពាក្យសុំរបស់ភាគី (មាត្រា ៣៦៦ កថាខណ្ឌទី១)[39] ត្រង់ចំណុចនេះមានន័យថា ការអនុវត្តដោយបង្ខំពុំមែនជានីតិវិធីដែលត្រូវចាប់ផ្តើមឡើងដោយស្វ័យប្រវត្តិដោយគ្មានពាក្យសុំនោះទេ ហើយការចាប់ផ្តើមឡើងនៃនីតិវិធីអនុវត្តដោយបង្ខំ គឺបញ្ជាក់ថានីតិវិធីនេះជានីតិវិធីឯករាជ្យពីនីតិវិធីបណ្តឹង។ ដូចដែលបានបកស្រាយរួចហើយថា ការអនុវត្តដោយបង្ខំត្រូវបានបែងចែកជាច្រើនប្រភេទ ដូចនេះហើយពាក្យសុំឱ្យអនុវត្តដោយបង្ខំ ក៏ត្រូវសរសេរផ្សេងពីគ្នាអាស្រ័យទៅតាមប្រភេទនៃការអនុវត្តផងដែរ ។

#### ១. ការចរចារ ការជ្រើសរើស និងការស្រាវជ្រាវ

មុនពេលចាប់ផ្តើមអនុវត្តដោយបង្ខំ ម្ចាស់បំណុលនៃការអនុវត្តតែងតែចង់ឱ្យកូនបំណុលនៃការអនុវត្ត ធ្វើការអនុវត្តដោយស្ម័គ្រចិត្ត ដែលករណីនេះវាអាចនឹងមានការចំណេញនូវពេលវេលា និងថវិកា។ ដោយឡែកបើគ្មានការអនុវត្តដោយស្ម័គ្រចិត្តទេ ទើបឈានដល់ការអនុវត្តដោយបង្ខំ។

នៅក្នុងការអនុវត្តជាក់ស្តែងបច្ចុប្បន្ន គេសង្កេតឃើញមានការជូនដំណឹងអំពីការអនុវត្តដោយស្ម័គ្រចិត្ត បន្ទាប់ពីស្ថាប័នអនុវត្ត បានទទួលពាក្យសុំឱ្យអនុវត្តដោយបង្ខំ។ ការធ្វើសកម្មភាពបែបនេះអាចនិងមានប្រសិទ្ធិភាព ដែលអាចឱ្យម្ចាស់បំណុលនៃការអនុវត្តឆាប់រហ័សក្នុងការទទួលបានសំណង ហើយរឿងក្តីនៃការអនុវត្តនៃក៏ឆាប់បញ្ចប់ផងដែរ។ ប្រសិនបើកូនបំណុលនៃការអនុវត្តបានទទួលការជូនដំណឹងអំពីការអនុវត្តដោយស្ម័គ្រចិត្ត ហើយកូនបំណុលនៃការអនុវត្តមានការភ័យខ្លាច នោះកូនបំណុលនៃការអនុវត្តអាចយកប្រាក់មកសងម្ចាស់បំណុលនៃការអនុវត្ត តាមការបង្គាប់របស់ស្ថាប័នអនុវត្តនេះ។ ប៉ុន្តែផ្ទុយមកវិញ ប្រសិនបើកូនបំណុលនៃការអនុវត្តទទួលបានការជូនដំណឹងនោះរួចមកកូនបំណុលនៃការអនុវត្តក៏អាចមានឱកាសក្នុងការចាត់ចែងចលនវត្ថុ ដែលជាកម្មវត្ថុ នៃការអនុវត្តដោយបង្ខំ ដូចជាការធ្វើអនុប្បទាន ប្រទានកម្ម ការលាក់កំបាំង ជាដើម ។ល។

ករណីនេះ អាចនឹងធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្តខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងរ តាមរយៈការជូនដំណឹងឱ្យអនុវត្តដោយស្ម័គ្រចិត្តនេះ។ ជាពិសេសចំពោះការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ប្រសិនបើអាជ្ញាសាលាដែលទទួលបន្ទុកក្នុងការអនុវត្ត បានជូនដំណឹងឱ្យអនុវត្តដោយស្ម័គ្រចិត្ត គឺកូនបំណុលនៃការអនុវត្តមានឱកាសជាច្រើនក្នុងការធ្វើអនុប្បទាន ឬចាត់ចែងនូវចលនវត្ថុនោះ។

[39] មាត្រា៣៦៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ជាទូទៅនៅពេលដែលកូនបំណុល មិនយល់ព្រមអនុវត្តដោយស្ម័គ្រចិត្តអំពីការសងសិទ្ធិលើបំណុល ដែលមានចែងក្នុងលិខិតអនុវត្តនោះទេ នោះវាជាដំណាក់កាលដែលត្រូវឲ្យម្ចាស់បំណុលនៃការអនុវត្ត ត្រូវប្រើសិទ្ធិដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ខ្លួនតាមរយៈការអនុវត្តដោយបង្ខំ។ ដូចដែលយើងបានដឹងហើយថាការអនុវត្តដោយបង្ខំដែលមានគោលបំណងឲ្យសងជាប្រាក់ មាន ០៤ ប្រភេទ រួមមានៈ

-ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

-ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

-ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលនិងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

-ការអនុវត្តដោយបង្ខំចំពោះនាវា

ជាមួយគ្នានេះដែរម្ចាស់បំណុលនៃការអនុវត្ត ត្រូវធ្វើការថ្លឹងថ្លែង និងជ្រើសរើសនូវនីតិវិធីណាមួយដែលងាយនិងឆាប់សម្រេចនូវសិទ្ធិទាមទាររបស់ខ្លួន។ ជាក់ស្តែងករណីសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ដែលមានចំនួនទឹកប្រាក់តិច ម្ចាស់បំណុលនៃការអនុវត្តគប្បីជ្រើសរើសនូវការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដែលមានលក្ខណៈងាយស្រួលនិងឆាប់រហ័សជាងប្រភេទនៃការអនុវត្តដោយបង្ខំផ្សេងទៀត។

នៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុមិនចាំបាច់ទាមទារឱ្យម្ចាស់បំណុលនៃកាអនុវត្តធ្វើការស្រាវ-ជ្រាវអំពីទ្រព្យសម្បត្តិជាចលនវត្ថុរបស់កូនបំណុលនៃការអនុវត្តនោះទេ ពោលគឺគ្រាន់តែម្ចាស់បំណុលនៃការអនុវត្តធ្វើការបញ្ជាក់ នៅក្នុងពាក្យសុំថាសុំអនុវត្តចំពោះចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត ដោយគ្រាន់តែបញ្ជាក់អំពីទីតាំងដែលចលនវត្ថុនោះស្ថិតនៅតែប៉ុណ្ណោះ។

### ២. ការសរសេរពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

ជាគោលការណ៍ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយស្ថាប័នអនុវត្ត តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត[40] ដែលម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដូចខាងក្រោម[41] ៖

-ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត ឬឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

-ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់កូនបំណុលនៃការអនុវត្ត ឬឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

[40] មាត្រា៣៥៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[41] មាត្រា៣៤៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

-សញ្ញាណនៃលិខិតអនុវត្ត អាចសរសេរបញ្ជាក់អំពីប្រភេទនៃលិខិតអនុវត្ត ប្រភពនៃលិខិតអនុវត្ត រួមទាំងកាលបរិច្ឆេទនៃលិខិតអនុវត្តជាដើម ។

-សេចក្តីស្នើសុំឱ្យអនុវត្ត ត្រូវសរសេរថា ស្នើសុំឱ្យអនុវត្តតាមវិធានបង្ខំដោយផ្ទាល់។

-សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្ត ដែលក្នុងករណីនេះម្ចាស់បំណុលនៃការអនុវត្តមិនចាំបាច់រៀបរាប់លម្អិតអំពីចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តក៏បាន ពោលគឺម្ចាស់បំណុលនៃការអនុវត្តគ្រាន់តែបញ្ជាក់អំពីទីតាំងនៃចលនវត្ថុរបស់កូនបំណុលគឺគ្រប់គ្រាន់ហើយ[42] ។

### ៣. ការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

ម្ចាស់បំណុលនៃការអនុវត្ត ត្រូវយកពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ទៅដាក់នៅការិយាល័យអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ច លើទីកន្លែងដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំស្ថិតនៅ[43]។ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុត្រូវដាក់ទៅសាលាដំបូងដើម្បីបង់ពន្ធ រួចទើបសាលាដំបូងចាត់បញ្ជូនពាក្យសុំនេះមកអាជ្ញាសាលាជាក្រោយ។

**ឧទាហរណ៍៖** បើចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវតស្ថិតនៅរាជធានីភ្នំពេញ ម្ចាស់បំណុលត្រូវដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំនៅអាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ។

### កថាភាគទី២ ៖ ការពិនិត្យពាក្យសុំដោយអាជ្ញាសាលា

តាមរយៈការបកស្រាយខាងលើ ជាគោលការណ៍ ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយស្ថាប័នអនុវត្ត (តុលាការអនុវត្ត និងអាជ្ញាសាលា) តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។ ប៉ុន្តែមិនមែនមានន័យថា ឱ្យតែមានការដាក់ពាក្យសុំអនុវត្តដោយបង្ខំរបស់ម្ចាស់បំណុលនៃការអនុវត្តនោះ សុទ្ធតែតម្រូវឱ្យស្ថាប័នអនុវត្តចាត់វិធានការ ឬចាប់ផ្តើមនិតិវិធីនៃការអនុវត្តដោយបង្ខំនោះទេ ពោលគឺត្រូវធ្វើការទាមទារឱ្យស្ថាប័នអនុវត្តធ្វើការពិនិត្យនូវពាក្យសុំនោះជាមុន ទើបស្ថាប័នអនុវត្តអាចចាប់ផ្តើមនីតិវិធីនៃការអនុវត្តដោយបង្ខំរបស់ខ្លួនបាន។

តាមមាត្រា ៣៣៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលបានអនុញ្ញាតឱ្យយកបញ្ញត្តិនៃមាត្រាមួយចំនួនដែលមានចែងក្នុងនីតិវិធីបណ្តឹងចាប់ពីគន្ថីទី២ ដល់គន្ថីទី៤ លើកលែងតែមានបញ្ញត្តិពិសេសក្នុងគម្ពីទី៦។ នេះមានន័យថា ការពិនិត្យពាក្យបណ្តឹងដែលចែងក្នុងមាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ក៏អាចត្រូវយកមកអនុវត្តនៅក្នុងការពិនិត្យពាក្យសុំ ដោយអាជ្ញាសាលាផងដែរ។

អាជ្ញាសាលា ត្រូវធ្វើការពិនិត្យនូវពាក្យសុំដែលបានធ្វើឡើងដោយម្ចាស់បំណុលនៃការអនុវត្ត នៅមុនការចាប់ផ្តើមនីតិវិធីនៃកាអនុវត្តដោយបង្ខំ នូវចំណុចសំខាន់ៗ ដូចខាងក្រោម៖

[42] មាត្រា៣៨៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[43] មាត្រា៣៨៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

**១. សមត្ថកិច្ចអនុវត្ត**

នៅពេលស្ថាប័នអនុវត្តបានទទួលពាក្យសុំឱ្យអនុវត្តដោយបង្ខំពីម្ចាស់បំណុលនៃការអនុវត្ត ចំណុចដែលត្រូវធ្វើការពិនិត្យជាបឋមនោះគឺ ត្រូវពិនិត្យថា តើខ្លួនមានសមត្ថកិច្ចលើកាអនុវត្តដោយបង្ខំនេះដោយផ្អែកលើពាក្យសុំដែរ ឬទេ ?

ការពិនិត្យអំពីសមត្ថកិច្ចនៃការអនុវត្តដោយបង្ខំអាចត្រូវធ្វើការពិនិត្យលើសមត្ថកិច្ចតាមកម្មវត្ថុនៃការអនុវត្ត ឬពិនិត្យលើដែនដីនៃការអនុវត្ត (សមត្ថកិច្ចដែនដី) ផងដែរ[44] ។

**-សមត្ថកិច្ចតាមកម្មវត្ថុនៃការអនុវត្ត៖** ដោយសារតែស្ថាប័នអនុវត្តមានពីរប្រភេទគឺ (តុលាការអនុវត្ត និង អាជ្ញាសាលា) ហេតុនេះនៅពេលមានការដាក់ពាក្យសុំម្តងៗ ស្ថាប័នអនុវត្តត្រូវពិនិត្យមើលថា តើពាក្យសុំនោះត្រូវបានស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួនដែរ ឬទេ [45]។ **ឧទាហរណ៍៖** នៅក្នុងសាលក្រមមួយបានសម្រេចបង្គាប់ឱ្យឈ្មោះ "ក" សងប្រាក់ដើមចំនួន ៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក មកឱ្យដើមចោទ ។ ពេលនោះឈ្មោះ "ខ" បានដាក់ពាក្យសុំមកតុលាការអនុវត្ត ដើម្បីឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ របស់ឈ្មោះ "ក" ដែលចលនវត្ថុនោះ ជាកម្មវត្ថុនៃការអនុវត្ត។

ផ្អែកតាមឧទាហរណ៍ខាងលើ ដោយអនុលោមតាមបញ្ញត្តិនៃ (មាត្រា៣៣៥ និងមាត្រា១៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ) ចំពោះការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់ ហើយកម្មវត្ថុនៃការអនុវត្ត គឺជាចលនវត្ថុនោះ នាំឱ្យការអនុវត្តដោយបង្ខំនេះត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់អាជ្ញាសាលាមិនមែនក្រោមសមត្ថកិច្ចរបស់តុលាការអនុវត្តនោះទេ។ ហេតុនេះតុលាការអនុវត្តត្រូវផ្ទេរសមត្ថកិច្ចមកឱ្យអាជ្ញាសាលាអនុវត្តវិញ។

**-សមត្ថកិច្ចដែនដី៖** ស្ថាប័នអនុវត្តនីមួយៗ តែងតែមាននៅតាមបណ្តាខេត្ត/រាជធានី ហេតុនេះហើយការពិនិត្យលើដែនដី ក៏ជាកត្តាមួយដើម្បីអាចអនុវត្តដោយបង្ខំបានដែរ។ **ឧទាហរណ៍៖** កម្មវត្ថុនៃការអនុវត្តដែលជាចលនវត្ថុ មានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ នោះស្ថាប័នអនុវត្ត ដែលជាអាជ្ញាសាលាមានសមត្ថកិច្ចលើការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដែលស្ថិតនៅរាជធានីភ្នំពេញ ជាស្ថាប័នមានសមត្ថកិច្ចនៅទីតាំងនោះ។

**២. ការសរសេរពាក្យសុំ**

បន្ទាប់ពីស្ថាប័នអនុវត្តដែលជាអាជ្ញាសាលា បានទទួលពាក្យសុំឱ្យអនុវត្តដោយបង្ខំរបស់ម្ចាស់បំណុលនៃការអនុវត្តរួច អាជ្ញាសាលាត្រូវពិនិត្យមើលលើពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ថាម្ចាស់បំណុលនៃការ

[44] មាត្រា១៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[45] មាត្រា៣៣៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

អនុវត្តដែលបានដាក់ពាក្យសុំនោះ បានសរសេរពាក្យសុំត្រឹមត្រូវ[46] តាម (មាត្រា៣៤៨ និងមាត្រា៣៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដែរ ឬទេ [47]?

ប្រសិនបើអាជ្ញាសាលាពិនិត្យឃើញថាពាក្យសុំមានលក្ខណៈខ្វះខាតនោះ អាជ្ញាសាលាអាចបង្គាប់ឲ្យម្ចាស់បំណុលនៃការអនុវត្តធ្វើការកែតម្រូវ[48]តាមមាត្រា៣៣៥ និងមាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន[49]។ បើម្ចាស់បំណុលនៃការអនុវត្ត ពុំបានធ្វើការកែតម្រូវតាមការបង្គាប់ទេនោះ អាជ្ញាសាលាអាចលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំបាន។ ប្រសិនបើអាជ្ញាសាលាបានធ្វើការពិនិត្យលើពាក្យសុំទៅឃើញថាពាក្យសុំនេះបានសរសេរត្រឹមត្រូវហើយនោះ អាជ្ញាសាលាអាចចាប់ផ្ដើមធ្វើការពិនិត្យលើចំណុចផ្សេងទៀតនៃពាក្យសុំបាន។

### ៣. ការផ្ទៀងផ្ទាត់ភាគីនៃការអនុវត្ត

អាជ្ញាសាលាត្រូវធ្វើការផ្ទៀងផ្ទាត់មើលថា ភាគីនៅក្នុងពាក្យសុំ និងភាគីនៅក្នុងលិខិតអនុវត្តបមន្តអនុវត្តដូចគ្នាដែរទេ? ការពិនិត្យបែបនេះក្នុងគោលបំណងដើម្បីចង់ដឹងថា៖

អ្នកដាក់ពាក្យសុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីក្លាយជាម្ចាស់បំណុលនៃការអនុវត្ត ឬអ្នកមានផលប្រយោជន៍ក្នុងរឿងក្តីអនុវត្តនេះដែរឬទេ? ចំណែកឯកូនបំណុលនៃការអនុវត្តដែលត្រូវប្រឈមជាមួយនឹងការរឹបអូសរបស់អាជ្ញាសាលាដែលជាបុគ្គលតែមួយដូចដែលមានកំណត់ក្នុងលិខិតអនុវត្ត និងពាក្យសុំដែរឬទេ?

### ៤. ឯកសារដែលត្រូវភ្ជាប់មកជាមួយពាក្យសុំ

ក្រៅពីការពិនិត្យពាក្យសុំឱ្យអនុវត្តដោយបង្ខំដោយអាជ្ញាសាលារួចមក ក៏ត្រូវគប្បីធ្វើការពិនិត្យមើលលើឯកសារ ដែលបានភ្ជាប់មកជាមួយពាក្យសុំនោះផងដែរ។ ហើយឯកសារភ្ជាប់នោះគឺជាព័ត៌មានបន្ថែម សម្រាប់ឱ្យអាជ្ញាសាលាធ្វើការពិនិត្យដើម្បីចាត់នីតិវិធីបន្ត។

ឯកសារដែលត្រូវបានភ្ជាប់ជាមួយនឹងពាក្យសុំ ដែលអាជ្ញាសាលាត្រូវធ្វើការពិនិត្យនៅក្នុងសំណុំរឿងដែលបានភ្ជាប់ជាមួយនឹងពាក្យសុំមានដូចខាងក្រោម៖

**-លិខិតអនុវត្ត៖** គឺជាឯកសារមូលដ្ឋានសម្រាប់ការអនុវត្ត ។ ឯកសារនេះត្រូវតែជាឯកសារមានបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ដែលក្នុងក្រមនីតិវិធីហៅថា "**ឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត**" ។

**-សេចក្តីចម្លងការចូលជាស្ថាពរនៃលិខិតអនុវត្ត៖** ក្នុងករណីដែលលិខិតអនុវត្តនោះជាសាលក្រម ឬសាលដីកាសម្រេចដែលនឹងមិនមានអានុភាពទេបើមិនបានចូលជាស្ថាពរ។ លិខិតបញ្ជាក់ការចូលជាស្ថាពរគឺត្រូវបញ្ជាក់ដោយក្រឡាបញ្ជី (មាត្រា២៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

---

[46] មាត្រា៣៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[47] មាត្រា៣៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[48] មាត្រា៣៣៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[49] មាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

**-រូបមន្តអនុវត្តៈ** គឺសំដៅដល់ប្រយោគដែលក្រឡាបញ្ជី ឬសារការី បានបញ្ជាក់អំពីអានុភាពអនុវត្ត របស់លិខិតអនុវត្ត។ ដូច្នេះរូបមន្តអុនវត្តគឺជាឯកសារសំខាន់ ដែលទាមទារឱ្យអាជ្ញាសាលា ធ្វើការពិនិត្យថាតើលិខិតអនុវត្ត និងរូបមន្តអនុវត្តមានភាពស៊ីសង្វាក់គ្នាដែរ ឬទេ ? ឬតើការចេញរូបមន្តអនុវត្ត មានលក្ខណៈត្រឹមត្រូវអាចឱ្យអាជ្ញាសាលាចាប់ផ្តើមការអនុវត្តបានដែរ ឬទេ ?

**-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិៈ** អាជ្ញាសាលាត្រូវពិនិត្យមើលលើលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិផងដែរ បើក្នុងករណីពាក្យសុំនោះត្រូវបានធ្វើឡើងដោយមេធាវី ជាអាទិ៍ ។

### ៥. លិខិតបញ្ជាក់អំពីការបង់សោហ៊ុយសម្រាប់ការអនុវត្ត

អាជ្ញាសាលាត្រូវធ្វើការពិនិត្យមើលថាតើម្ចាស់បំណុលនៃការអនុវត្តបានបង់ពន្ធដាក់ពាក្យសុំរួចរាល់ហើយ ឬនៅ តាមបញ្ញត្តិនៃមាត្រា៣៧២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងប្រការ១៣ នៃប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា។

### ៦. ឯកសារបញ្ជាក់ការបញ្ជូនលិខិតអនុវត្ត

ជាគោលការណ៍លិខិតអនុវត្តគឺជាមូលដ្ឋាននៃការអនុវត្តដោយបង្ខំ ត្រូវបញ្ជូនទៅកូនបំណុលនៃការអនុវត្តនៅមុនពេលចាប់ផ្តើមការអនុវត្ត ឬ យ៉ាងយូរបំផុតស្របពេលជាមួយនឹងការចាប់ផ្តើមការអនុវត្ត (មាត្រា៣៦០ កថាខណ្ឌទី១)។ មូលហេតុដែលមាត្រានេះតម្រូវឱ្យបញ្ជូនលិខិតអនុវត្ត ជាអាទិ៍ នៅពេលចាប់ផ្តើមអនុវត្តដោយបង្ខំ គឺដើម្បីជូនដំណឹងទៅកូនបំណុលនៃការអនុវត្តថា នីតិវិធីនៃការអនុវត្តនឹងចាប់ផ្តើមចំពោះសិទ្ធិលើបំណុលណាមួយ ក្នុងបំណងផ្តល់ឱកាសការពារខ្លួនដល់កូនបំណុលនៃការអនុវត្ត។ ប៉ុន្តែក្នុងករណីដែលត្រូវធ្វើការអនុវត្តដោយបង្ខំដោយសាលក្រម ឬ សាលដីកាស្ថាពរធ្វើជាលិខិតអនុវត្ត សាលក្រម ឬសាលដីកានោះត្រូវបានបញ្ជូនទៅឱ្យភាគីរួចហើយ តាមបញ្ញត្តិ (មាត្រា១៩០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ដូច្នេះអាជ្ញាសាលា គ្រាន់តែពិនិត្យមើលថា លិខិតអនុវត្តបានបញ្ជូលទៅកូនបំណុលនៃការអនុវត្តហើយ ឬនៅ។ បើមិនទាន់បានបញ្ជូនទេ អាជ្ញាសាលាគប្បីធ្វើការបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត នៅមុនពេលចាប់ផ្តើមធ្វើការអនុវត្តរបស់ខ្លួន។

### ៧. ឯកសារបញ្ជាក់ការបញ្ជូលលិខិតអនុវត្តពិសេស

ការបញ្ជូនរូបមន្តអនុវត្តពិសេសនិងលិខិតបញ្ជាក់ ប្រសិនបើការអនុវត្តដោយបង្ខំ ត្រូវបានធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលភ្ជាប់នឹងរូបមន្តអនុវត្តពិសេសនោះ អាជ្ញាសាលាត្រូវពិនិត្យមើលថា តើរូបមន្តអនុវត្តពិសេសនិងលិខិតបញ្ជាក់ផ្សេងទៀតនោះ បានបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្តហើយ ឬនៅ?

ម្យ៉ាងវិញទៀតប្រសិនបើរូបមន្តអនុវត្តពិសេសត្រូវបានផ្តល់ដោយផ្អែកលើឯកសារដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់នោះក៏ត្រូវធ្វើការបញ្ជូនឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នោះផងដែរ (មាត្រា៣៦០ វាក្យ-ខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**៨. លិខិតបញ្ជាក់អំពីការផ្តល់តាវកាលិក**

ក្នុងករណីដែលសិទ្ធិលើបំណុលដែលបានកំណត់ក្នុងលិខិតអនុវត្ត ភ្ជាប់ជាមួយនឹងពេលពិតប្រាកដ អាជ្ញាសាលាអាចចាប់ផ្តើមការអនុវត្តដោយបង្ខំចំពោះចលនវត្ថុបាន លុះត្រាតែពេលកំណត់នោះបានមកដល់ហើយ (មាត្រា៣៦១ កថាខណ្ឌទី១)[50]។ ទោះបីជាសិទ្ធិលើបំណុលដែលមានពេលកំណត់ពិតប្រាកដ គឺជាចំណុចសារជាតុក៏ដោយ ប៉ុន្តែវាក៏មានភាពងាយស្រួលនឹងដឹងថាតើពេលកំណត់មកដល់ ឬនៅដែរ។ ហេតុដូចនេះហើយក្នុងនាមអាជ្ញាសាលាជាស្ថាប័នអនុវត្ត ជាពិសេសចំពោះចលនវត្ថុផងនោះ ត្រូវធ្វើការស្រាវជ្រាវអំពីការមកដល់នៃពេលដែលត្រូវផ្តល់តាវកាលិកមុននឹងចាប់ផ្តើមធ្វើនីតិវិធីនៃការអនុវត្តដោយបង្ខំ។ ផ្ទុយទៅវិញក្នុងករណីដែលសិទ្ធិឱ្យទាមទារដែលកំណត់នៅក្នុងលិខិតអនុវត្តភ្ជាប់ជាមួយនូវពេលកំណត់មិនពិតប្រាកដវិញ នោះម្ចាស់បំណុលនៃការអនុវត្តត្រូវធ្វើការបញ្ជាក់អំពីពេលមក ដល់កំណត់ពិតប្រាកដជាមុនសិន ទើបទទួលការផ្តល់រូបមន្តអនុវត្តពិសេសជាក្រោយ។

ប្រសិនបើអាជ្ញាសាលាបានចាប់ផ្តើមការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ នៅមុនពេលមុនការមកដល់ពេលកំណត់ពិតប្រាកដសកម្មភាពនៃការអនុវត្តនោះគឺជាសកម្មភាពខុសច្បាប់។ ប៉ុន្តែប្រសិនបើពេលកំណត់ពិតប្រាកដមកដល់មុនពេលដែលសកម្មភាពនោះត្រូវបានលុបចោល វិការៈនោះនឹងត្រូវបានស្រោចស្រង់ឡើងវិញ។

**៩. ការដាក់លិខិតបញ្ជាក់អំពីការដាក់ប្រាតិភោគ**

ក្នុងករណីដែលការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយផ្អែកលើលិខិតអនុវត្ត ដែលមានដាក់ល័ក្ខខ័ណ្ឌត្រូវដាក់ប្រាតិភោគដើម្បីអនុវត្តដោយបង្ខំនោះ អាជ្ញាសាលាដែលជាស្ថាប័នអនុវត្តចំពោះចលនវត្ថុនោះត្រូវធ្វើការស្រាវជ្រាវអំពីករណីនេះ ដោយឱ្យម្ចាស់បំណុលនៃការអនុវត្តដាក់លិខិតដែលបញ្ជាក់ថាខ្លួនបានដាក់ប្រាតិភោគនោះរួចហើយ មុននឹងចាប់ផ្តើមការអនុវត្តដោយបង្ខំ។[51]

ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដោយពុំមានការដាក់នូវលិខិតបញ្ជាក់អំពីការដាក់ប្រាតិភោគ គឺជាការអនុវត្តដោយខុសច្បាប់។ ប៉ុន្តែប្រសិនបើលិខិតនោះ ត្រូវបានដាក់នៅពេលក្រោយមក ការអនុវត្តនោះនឹងក្លាយទៅជាស្របច្បាប់វិញ ចាប់ពីពេលដាក់នោះ។

[50] មាត្រា៣៦១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[51] មាត្រា៣៦១ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

### ១០. លិខិតបញ្ជាក់អំពីការផ្តល់តាវកាលិកតប

ក្នុងករណីដែលតាវកាលិករបស់កូនបំណុលនៃការអនុវត្ត ត្រូវផ្តល់ដោយការប្តូរជាមួយនឹងតាវកាលិកតបរបស់ម្ចាស់បំណុលនៃការអនុវត្ត នោះអាជ្ញាសាលាអាចចាប់ផ្តើមការអនុវត្តដោយបង្ខំបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបានភ្ជាប់ឯកសារបញ្ជាក់ថាខ្លួនបានផ្តល់តាវកាលិកតបនោះ ឬបានស្នើសុំថាផ្តល់តាវកាលិកតបនោះរួចហើយ។ [52]

## ផ្នែកទី២ ៖ ដំណាក់កាលនៃការរឹបអូសចលនវត្ថុ

គ្រប់នីតិវិធីទាំងអស់តែងតែងមាននីតិវិធីនៃការចាប់ផ្តើម និងការបញ្ចប់ទៅតាមប្រភេទ ឬលក្ខណៈផ្សេងគ្នាអាស្រ័យទៅតាមនីតិវិធីនីមួយៗ។ ជាក់ស្តែងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺត្រូវចាប់ផ្តើមការអនុវត្តដោយអាជ្ញាសាលាដោយ ***ការរឹបអូសចលនវត្ថុដោយអាជ្ញាសាលា*** ដោយត្រូវផ្អែកលើការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ តាមរយៈម្ចាស់បំណុលនៃការអនុវត្ត។ ជាមួយគ្នានេះដែរ មានមតិមួយចំនួនតែងតែងមានការភាន់ច្រឡំថា ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ នឹងត្រូវចាប់ផ្តើមនៅពេលដែលម្ចាស់បំណុលនៃការអនុវត្ត បានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំមកអាជ្ញាសាលា។ ក្នុងន័យនេះ បើទោះបីជាម្ចាស់បំណុលនៃការអនុវត្តបានដាក់ពាក្យសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុ មកអាជ្ញាសាលាក៏ដោយ ក៏មិនទាន់ចាត់ទុកថា នីតិវិធីនៃការអនុវត្តដោយបង្ខំត្រូវបានចាប់ផ្តើមដែរ លុះត្រាតែមានការរឹបអូសចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត ទើបចាត់ទុកថាជាការអនុវត្តដោយបង្ខំចំពោះចលនវត្ថុបាន។[53] ក្រៅពីនេះក៏មានមតិមួយចំនួនទៀតដែលតែងតែមានការភាន់ច្រឡំថា ការចាប់ផ្តើមការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺចាប់ផ្តើមនៅពេលដែលអាជ្ញាសាលាបានដាស់តឿនឱ្យកូនបំណុលនៃការអនុវត្តធ្វើការអនុវត្តសងសំណងដោយស្ម័គ្រចិត្តនៅចំពោះទីកន្លែងនៃការអនុវត្តនោះ។ ក្នុងន័យនេះ នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ នៅតែចាត់ទុកថាមិនទាន់អាចចាប់ផ្តើមដដែល បើក្នុងករណីអាជ្ញាសាលាបានធ្វើការដាស់តឿនឱ្យកូនបំណុលនៃការអនុវត្ត បានធ្វើការអនុវត្តសងសំណងដោយស្ម័គ្រចិត្ត នៅចំពោះទីកន្លែងនៃការអនុវត្តនោះក៏ដោយ។ លុះត្រាតែ មានការរឹបអូសចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត ទើបចាត់ទុកថាជាការអនុវត្តដោយបង្ខំចំពោះចលនវត្ថុនោះបាន [54](មាត្រា៣៨៤ កថាខណ្ឌទី៥ និងកថាខណ្ឌទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

### កថាភាគទី១ ៖ គោលការណ៍សំខាន់ៗនៃការអនុវត្ត

#### ១. គោលការណ៍នៃការរឹបអូស

---

[52] មាត្រា៣៦១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[53] មាត្រា៣៨៤ កថាខណ្ឌទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[54] មាត្រា៣៦១ កថាខណ្ឌទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ជាគោលការណ៍ ការរឹបអូសអាចធ្វើបានចំពោះទ្រព្យរូបិយ និងទ្រព្យអរូបិយដែលធ្លាក់ទៅលើការកាន់កាប់របស់កូនបំណុលនៃការអនុវត្ត។ មានន័យថារាល់ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិ ឬស្ថិតក្រោមការកាន់កាប់របស់កូនបំណុលនៃការអនុវត្ត នាំឱ្យរាល់ទ្រព្យសម្បត្តិទាំងនោះសុទ្ធតែជាកម្មវត្ថុនៃការរឹបអូសដើម្បីសម្រេចនូវសិទ្ធិក្នុងការទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្តផងដែរ [55]។

ទន្ទឹមគ្នានេះដែរ ចំពោះការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ជាគោលការណ៍គ្រប់ចលនវត្ថុដែលជាកម្មសិទ្ធិ ឬស្ថិតក្រោមការកាន់កាប់របស់កូនបំណុលនៃការអនុវត្តសុទ្ធតែជាកម្មវត្ថុនៃការអនុវត្តទាំងអស់ ដោយពុំចាំបាច់ធ្វើការស្រាវជ្រាវអំពីកម្មសិទ្ធិនៅមុនការរឹបអូសនោះទេ លើកលែងតែមានកំណត់ជាពិសេសក្នុងច្បាប់ (មាត្រា ៣៧៩ នៃក្រមរដ្ឋប្បវេណី) [56]។

**២. ចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស**

- **ចលនវត្ថុ៖** សំដៅដល់វត្ថុទាំងឡាយណាដែលមិនមែនជាអចលនវត្ថុ (មាត្រា១២០ កថាខណ្ឌទី៣នៃក្រមរដ្ឋប្បវេណី)។ ចលនវត្ថុទាំងនោះរួមមាន រថយន្ត ម៉ូតូ ខ្សែក ជាអាទិ៍ សុទ្ធតែអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំបាន។ យោងតាមបញ្ញត្តិនៃមាត្រា១១៩ នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា មានតែវត្ថុដែលមានរូបរាងតែប៉ុណ្ណោះដែលអាចកំណត់ថាជាវត្ថុបាន។ មាត្រា១២០ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តិស្តីពី ***"ចលនវត្ថុត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះទ្រព្យសម្បត្តិដែលគ្មានរូបរាងតែអាចគ្រប់គ្រងបាន"*** ។ ដូចនេះចំពោះវត្ថុដែលគ្មានរូបរាងដែលអាចគ្រប់គ្រងបានក៏ត្រូវអនុវត្តដោយចាត់ទុកដូចជា វត្ថុដែលអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុបានដែរ។
- **ផលធម្មជាតិ៖** ផលធម្មជាតិដែលមិនទាន់បានបំបែកចេញពីដី ហើយអាចទទួលផលយ៉ាងច្បាស់ក្នុងអំឡុងពេល ០១ខែ។ មានន័យថា វត្ថុដែលមិនទាន់បំបែកចេញពីដី គឺជាសមាសភាគនៃដី (មាត្រា១២២ នៃក្រមរដ្ឋប្បវេណី)។ ផលដែលមិនទាន់បំបែកចេញពីដី ក៏នៅតែគេទទួលស្គាល់ថាជាសមាសភាគនៃដីដែរ (មាត្រា១២៣ នៃក្រមរដ្ឋប្បវេណី)។ ការអនុវត្តដោយបង្ខំចំពោះផលធម្មជាតិដែលមិនទាន់បំបែកពីដីអាចជាកម្មវត្ថុនៃការអនុវត្តដោយអាជ្ញាសាលា ប្រសិនបើដឹងច្បាស់ថា ផលនោះនឹងត្រូវបានទទួលក្នុងអំឡុងពេល ០១ខែ ប៉ុន្តែវាក៏អាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយតុលាការអនុវត្តដែរ ប្រសិនបើផលនោះនឹងទទួលផលក្នុងអំឡុងពេលលើសពី ០១ខែ។ **ឧទាហរណ៍៖** ផ្លែក្រូចដែលនៅក្នុងចំការអាចនឹងប្រមូលផលក្នុងអំឡុងពេល ៧ថ្ងៃទៀត ក៏អាចជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែរ។

[55] មាត្រា៣៧៩ កថាខណ្ឌទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[56] មាត្រា៣៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

- **រូបិយវត្ថុ៖** រូបិយវត្ថុដែលជាក្រដាសប្រាក់ ឬប្រាក់កាក់ [57]ដែលមិនចាំបាច់ទាមទារឱ្យមាននីតិវិធីនៃការប្តូរជាប្រាក់ ក៏អាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុបានដែរ។ បើទោះបីជានៅពេលចុះអនុវត្តរឹបអូស រូបិយវត្ថុនោះនៅក្នុងទូដែកក៏ដោយ ក៏អាជ្ញាសាលាអាចចាត់ចែងបើកទូដែកនោះដើម្បីរឹបអូសបានដែរ (មាត្រា៣៨៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) [58]។
- **មូលប្បទានបត្រ៖** ចំពោះមូលប្បទានបត្រ ដែលស្ថិតនៅក្រោមការកាន់កាប់របស់កូនបំណុលនៃការអនុវត្ត គឺមិនអាចអនុវត្តនីតិវិធីនៃការរឹបអូសតាមនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុបានទេ។ ព្រោះមូលប្បទានបត្រគឺជាការបញ្ជាជាលាយលក្ខណ៍អក្សរដោយឥតលក្ខខណ្ឌទៅកាន់ធនាគារិក ហើយការបញ្ជានោះត្រូវមានចុះហត្ថលេខាដោយបុគ្គលដែលចេញបញ្ជា ទើបធនាគារិកអាចផ្តល់ប្រាក់ក្នុងចំនួនកំណត់ណាមួយដល់បុគ្គលណាម្នាក់ ឬដល់អ្នកកាន់មូលប្បទានបត្រនោះ ហើយមូលប្បទានបត្រត្រូវតែអាចទូទាត់បាន និងស្របតាមច្បាប់ស្តីពី ឧបករណ៍ដែលអាចជួញដូរបាន និងប្រតិបត្តិការទូទាត់។ ករណីនេះធនាគារ គឺជាកូនបំណុលទី៣ ហើយម្ចាស់បំណុលនៃការអនុវត្តអាចរឹបអូសប្រាក់ដែលមាននៅក្នុងមូលប្បទានបត្របាន តាមនីតិវិធីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល។

### ៣. ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស

ជាគោលការណ៍ ទ្រព្យសម្បត្តិទាំងអស់របស់កូនបំណុលនៃការអនុវត្តអាចក្លាយជាកម្មវត្ថុនៃការរឹបអូសបាន (មាត្រា៣៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)[59]។ ទន្ទឹមនឹងនេះក៏មានមូលហេតុមួយចំនួនដែលជាមូលហេតុនាំឱ្យទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្តត្រូវបានហាមឃាត់មិនឱ្យរឹបអូស។ មូលហេតុនោះគឺពាក់ព័ន្ធនឹងគោលនយោបាយ ចលនវត្ថុជាទ្រព្យសម្បត្តិមួយចំនួនត្រូវបានហាមឃាត់មិនឲ្យរឹបអូស។ ចលនវត្ថុដែលត្រូវបានហាមឃាត់មិនឲ្យរឹបអូសទាំងនោះរួមមាន[60]៖

- ប្រដាប់ស្លៀកពាក់ ប្រដាប់សម្រាប់ដំណេក តុ ទូ ប្រដាប់ សម្រាប់ ដាំស្ល និងប្រដាប់សម្រាប់បិទឃាំងបន្ទប់ របស់កូនបំណុលនៃការអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ។
- គ្រឿងឧបភោគបរិភោគ និងទហានវត្ថុនៃការអនុវត្ត ដែលត្រូវការចាំបាច់ដើម្បីចិញ្ចឹមជិវិត ក្នុងអំឡុងពេល ២ (ពីរ) ខែ របស់កូនបំណុលនៃការអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ។

---

[57] មាត្រា៣៨៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[58] មាត្រា៣៨៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[59] មាត្រា៣៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[60] មាត្រា៣៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

- របបឧបត្ថម្ភជីវិត របបឧបត្ថម្ភផ្នែកអប់រំ របបឧបត្ថម្ភសុខភាព និង ប្រាក់ឧបត្ថម្ភផ្សេងទៀតដែលផ្តល់ពីរដ្ឋ ឬពីអាជ្ញាធរដែនដី ដើម្បីការពារដល់ជីវភាពរបស់កូនបំណុលនៃការអនុវត្ត។
- ផ្នែកប្រាក់តិចជាង ឬស្មើនឹង ១,០០០,០០០ (មួយលាន) រៀល ក្រៅពីប្រាក់ដែលបានកំណត់ក្នុងចំណុចខាងលើនេះ។
- ឧបករណ៍ ជី សត្វពាហនៈដែលជាចាំបាច់សម្រាប់ការងារកសិកម្មរបស់ខ្លួន និងចំណីសត្វទាំងនោះ ព្រមទាំងគ្រាប់ពូជ ឬកសិផលដែលមានប្រភេទដូចគ្នា ដែលត្រូវការជាចាំបាច់សម្រាប់បន្តការងារកសិកម្មរហូតដល់រដូវ ដែលផលបន្ទាប់របស់កសិករក្នុងការប្រកបការងារកសិកម្ម។
- មង សំណាញ់ ឬ នេសាទុបករណ៍ផ្សេងៗចាំបាច់ ចំណី និង កូនត្រី ឬផលផលប្រភេទដូចគ្នា ដែលត្រូវការចាំបាច់សម្រាប់រកផលផល ឬចិញ្ចឹមផលផលរបស់អ្នកប្រកបរបរនេសាទ។
- ឧបករណ៍ និង វត្ថុផ្សេងទៀតដែលចាំបាច់សម្រាប់អ្នកបច្ចេកទេស សិប្បករ កម្មករ និងអ្នកផ្សេងទៀតដែលប្រកបរបរវិជ្ជាជីវៈ ឬសាជីវកម្ម ដោយបើកម្លាំងប្រាជ្ញា កម្លាំងកាយ។ ប៉ុន្តែបើវត្ថុដែលអ្នកនោះមានក្នុងគោលបំណងសម្រាប់ លក់ ឬជួលវិញ អាចរឹបអូសបាន ។
- ព្រះពុទ្ធរូប ក្បួនវិត័សាសនា និង វត្ថុផ្សេងៗទៀតដែលចាំបាច់សម្រាប់ពិធីក្នុងសាសនា ។
- ពង្សាវលី កំណត់ប្រចាំថ្ងៃ បញ្ជីប្រកបមុខរបរ និងឯកសារប្រភេទដូចគ្នាដែលចាំបាច់របស់កូនបំណុលនៃការអនុវត្ត។
- គ្រឿងឥស្សរិយយស និងប័ណ្ណសរសើរផ្សេងៗទៀតរបស់កូនបំណុលនៃការអនុវត្ត ឬរបស់ញាតិរបស់ជននោះ។
- ឯកសារ និងឧបករណ៍ដែលចាំបាច់ក្នុងការសិក្សានៅសាលា ឬនៅស្ថាប័នអប់រំផ្សេងទៀត របស់កូនបំណុលនៃការអនុវត្ត ឬញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្តហើយមានជីវភាពរួមគ្នា។
- វត្ថុដែលទាក់ទងនឹងតក្កកម្ម ឬស្នាដៃនិពន្ធ ដែលមិនទាន់ផ្សាយជាសាធារណៈ។
- អវយវៈសិប្បនិមិត្ត សរីរាងសិប្បនិមិត្តផ្សេងទៀត និងឧបករណ៍ជំនួយខ្លួនប្រាណផ្សេងទៀត ដែលចាំបាច់សម្រាប់កូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ព្រមទាំងវត្ថុផ្សេងៗសម្រាប់ថែទាំ អ្នកជម្ងឺ ដែលជាកូនបំណុលនៃការអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា។
- ម៉ាស៊ីន ឬ ឧបករណ៍ពន្លត់ភ្លើង ឧបករណ៍ជន្លៀសខ្លួនពេលមានអាសន្ន ឧបករណ៍ផ្សេងទៀតដែលច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងៗ តម្រូវឱ្យមានបរិក្ខារ ដើម្បីបង្ការមហន្តរាយ ឬការពារសន្តិសុខ។

### ៤. ការប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស

ដោយផ្អែកលើស្ថានភាពជីវភាពរស់នៅ ឬស្ថានភាពពិសេសរបស់កូនបំណុលនៃការអនុវត្ត ឬម្ចាស់បំណុលនៃការអនុវត្តនោះ កូនបំណុលនៃការអនុវត្ត ឬម្ចាស់បំណុលនៃការអនុវត្តអាចដាក់ពាក្យសុំទៅសាលាដំបូង ដែលអាជ្ញាសាលាស្ថិតនៅដើម្បីឱ្យតុលាការចេញដីកាសម្រេចអនុញ្ញាតឱ្យរឹបអូស ឬដីកាសម្រេចមិនឱ្យរឹបអូសចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូសបាន[61] ។

ការផ្លាស់ប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូសនោះ គឺអាស្រ័យទៅតាមអ្នកដាក់ពាក្យសុំឱ្យផ្លាស់ប្តូរ ពោលបើម្ចាស់បំណុលនៃការអនុវត្តសុំឱ្យផ្លាស់ប្តូរនោះ គឺចលនវត្ថុដែលបានហាមឃាត់មិនឱ្យរឹបអូសដែលបានកំណត់ក្នុង (មាត្រា៣៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) នោះនឹងត្រូវរឹតត្បិត មានន័យថា ជាគោលការណ៍ចលនវត្ថុមួយដែលជាកម្មវត្ថុនៃការហាមឃាត់។ តែប្រសិនបើមានពាក្យសុំឱ្យផ្លាស់ប្តូរនោះ ចលនវត្ថុនោះនឹងលែងជាកម្មវត្ថុនៃការហាមឃាត់តទៅទៀតហើយ ដូច្នេះ អាជ្ញាសាលាអាចរឹបអូសបាន។ ប៉ុន្តែប្រសិនបើពាក្យសុំធ្វើឡើងដោយកូនបំណុលនការអនុវត្តវិញ នោះមិនត្រឹមតែចលនវត្ថុដែលបានកំណត់ក្នុងមាត្រា ៣៨០ ទេដែលត្រូវបានហាមឃាត់មិនឱ្យរឹបអូសនោះ សូម្បីចលនវត្ថុដែលបានស្នើសុំមិនឱ្យរឹបអូសនោះ ក៏មិនអាចរឹបអូសបានដែរ ប្រសិនបើមានដីកាសម្រេចមិនអនុញ្ញាតឱ្យរឹបអូស។

មូលហេតុដែលកូនបំណុលនៃការអនុវត្ត ឬម្ចាស់បំណុលនៃការអនុវត្ត អាចស្នើសុំទៅសាលាដំបូង ដែលអាជ្ញាសាលាស្ថិតនៅដើម្បីផ្លាស់ប្តូរទំហំនៃចលនវត្ថុ ដែលហាមឃាត់មិនឱ្យរឹបអូសបាននោះ គឺអាស្រ័យលើស្ថានភាពជីវភាព ឬស្ថានភាពផ្សេងទៀតរបស់កូនបំណុលនៃការអនុវត្ត ឬម្ចាស់បំណុលនៃការអនុវត្ត ដែលដាក់ពាក្យសុំនោះ។ ស្ថានភាពទាំងនោះ អាចជាម្ចាស់បំណុលនៃការអនុវត្តមានជីវភាពរស់នៅធ្លាក់ចុះ ហើយទាមទារឱ្យអនុវត្តដោយបង្ខំដើម្បីទទួលបាននូវការគាំទ្រនូវជីវភាពរបស់ខ្លួន, ស្ថានភាពដែលកូនបំណុលនៃកាអនុវត្តគ្មានឆន្ទៈក្នុងការអនុវត្តតាមកិច្ចសន្យាទាល់តែសោះ ជាដើម។

ប្រសិនបើស្ថានភាពមានការផ្លាស់ប្តូរ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅអាចអនុញ្ញាតឱ្យរឹបអូសចលនវត្ថុដែលបានលុបចោលការរឹបអូសមួយផ្នែក ឬទាំងមូលបានតាមពាក្យសុំ[62]។ ដីកាសម្រេចខាងលើអាចប្តឹងជំទាស់បាន [63]។

---

[61] មាត្រា៣៨១ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[62] មាត្រា៣៨១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[63] មាត្រា៣៩១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

### ៥. ការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ

ជាគោលការណ៍ការរឹបអូសចលនវត្ថុ មិនធ្វើឱ្យហួសកម្រិតចាំបាច់សម្រាប់សំណងសិទ្ធិលើបំណុល របស់ម្ចាស់បំណុលនៃការអនុវត្ត និងសោហ៊ុយចាំបាច់សម្រាប់អនុវត្តទេ។ ករណីនេះវាហាក់ដូចជាទាមទារឱ្យ អាជ្ញាសាលាដែលជាស្ថាប័នអនុវត្ត ធ្វើការប៉ានប្រមាណវាយតម្លៃលើចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តភ្លាមៗ ដើម្បី ឈានទៅអាចដឹងបានថា ចលនវត្ថុដែលត្រូវធ្វើការរឹបអូសនោះមានតម្លៃប៉ុន្មាន ហើយមានគ្រប់ចំនួន ជាមួយនឹងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានកំណត់ក្នុងលិខិតអនុវត្តដែរឬទេ?

**ឧទាហរណ៍៖** សាលក្រមមួយមានខ្លឹមសារបង្គាប់ឱ្យចុងចម្លើយសងប្រាក់ ចំនួន ២០.០០០ដុល្លារអាមេរិក មកឱ្យដើមចោទ។ នៅពេលចុះទៅអនុវត្តបើកូនបំណុលនៃការអនុវត្ត មានប្រាក់ក្នុងទូដែកចំនួន ៥០,០០០ ដុល្លារ អាមេរិកនោះ ករណីនេះអាជ្ញាសាលាអាចរឹបអូសប្រាក់នោះ បានត្រឹមតែចំនួនប្រហែល ២២,០០០ ដុល្លារអាមេរិក ឬអាចលើសត្រឹមកម្រិតបន្តិចបន្តួចតែប៉ុណ្ណោះដើម្បីបង្ការទុកសុំឱ្យចែកចំណែក។ តែបើកូនបំណុលនៃការអនុវត្ត មានជាចលនវត្ថុដូចជា រថយន្តទំនើប ០២គ្រឿង វិញ ករណីនេះអាជ្ញាសាលា អាចប៉ាន់ប្រមាណបានថា ត្រឹមរថយន្ត មួយគឺ សមល្មមសម្រាប់ការសងសិទ្ធិលើបំណុល និងសោហ៊ុយអនុវត្តបានហើយ ដូច្នេះអាជ្ញាសាលាគប្បីរឹបអូស រថយន្តតែមួយបានហើយ។

ផ្ទុយមកវិញ ក្នុងករណីដែលចលនវត្ថុនោះ អាជ្ញាសាលាមិនធ្វើការវាយតម្លៃបានភ្លាមៗនៅកន្លែងរឹបអូស ទេនោះ អាជ្ញាសាលាគប្បីរឹបអូសមកសិន។ ក្រោយមកទើបបានដឹងថា ចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស លើសពីកម្រិតចាំបាច់នៃការសងសិទ្ធិលើបំណុល និងសោហ៊ុយសម្រាប់ការអនុវត្តទៅហើយ អាជ្ញាសាលាត្រូវ លុបចោលការរឹបអូសត្រឹមកម្រិតដែលលើសពីភាពចាំបាច់បាន។

### ៦. ការហាមឃាត់មិនឱ្យរឹបអូសក្នុងករណីដែលប៉ាន់ប្រមាណឃើញថាគ្មានចំនួនសេសសល់

អាជ្ញាសាលាមិនត្រូវរឹបអូសឡើយ ប្រសិនបើប៉ាន់ប្រមាណឃើញថាចំនួនទឹកប្រាក់ដែលបានមកពីការ លក់ចលនវត្ថុដែលត្រូវបានរឹបអូសនោះ គ្មានចំនួនសេសសល់ ក្រោយពីបានបង់សោយហ៊ុយសម្រាប់នីតិវិធី ហើយ មានន័យថាអាជ្ញាសាលា ចាំបាច់ត្រូវធ្វើប៉ាន់ប្រមាណជាបឋមនូវតម្លៃនៃចលនវត្ថុដែលជាកម្មវត្ថុនៃការរឹប អូសនៅក្នុងពេលចុះអនុវត្តរឹបអូស ហើយករណីដែលប៉ានប្រមាណថា ទោះបីជាចលនវត្ថុត្រូវបានលក់ក៏ដោយក៏ ប្រាក់ដែលបានមកពីការលក់នោះ នឹងគ្មានចំនួនសេសសល់បន្ទាប់ពីសងសោហ៊ុយនីតិវិធីហើយ[64]។

[64] មាត្រា៣៩២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ករណីបែបនេះ អាជ្ញាសាលាត្រូវលុបចោលការរឹបអូស ប្រសិនបើប៉ាន់ប្រមាណថាចំនួនទឹកប្រាក់ដែលបានមកពីការលក់ចលនវត្ថុដែលត្រូវបានរឹបអូស នោះគ្មានចំនួនសេសសល់ ក្រោយពីសងសិទ្ធិលើបំណុលដែលមានអាទិភាពជាង សិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និងសោហ៊ុយសម្រាប់នីតិវិធីហើយ [65]។

**កថាភាគីទី២ ៖ ការអនុវត្តការរឹបអូសចលនវត្ថុ**

**១. វិធីរឹបអូសចលនវត្ថុ**

វិធីរឹបអូសចលនវត្ថុដោយអាជ្ញាសាលា នឹងត្រូវធ្វើឡើងក្នុងស្ថានភាពផ្សេងគ្នា ដោយផ្អែកតាមការកាន់កាប់ចលនវត្ថុដោយក្នុងនោះរួមមាន ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយម្ចាស់បំណុលនៃការអនុវត្ត និងការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយតតិយជន។

**១.១. ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត**

នៅមុនពេលចាប់ផ្តើមការរឹបអូសចលនវត្ថុ ប្រសិនបើជួបប្រទះកូនបំណុលនៃការអនុវត្តនៅទីកន្លែងដែលត្រូវរឹបអូស អាជ្ញាសាលាត្រូវដាស់តឿនឱ្យកូនបំណុលនៃការអនុវត្តនោះសងបំណុលដោយស្ម័គ្រចិត្ត[66] ករណីនេះប្រសិនបើកូនបំណុល យល់ព្រមប្រគល់ប្រាក់សំណងដោយស្ម័គ្រចិត្ត អាជ្ញាសាលាអាចទទួលយកសំណង និងសោហ៊ុយសម្រាប់ការអនុវត្តបាន[67]។ តែបើកូនបំណុលនៃការអនុវត្តបដិសេធនោះ អាជ្ញាសាលាត្រូវចាប់ផ្តើមការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត ដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត និងសោហ៊ុយសម្រាប់ការអនុវត្ត។

ចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តអាចមានច្រើនបែបយ៉ាង ហេតុដូចនេះ នីតិវិធីរឹបអូស នឹងត្រូវមានចំណាត់ការដូចតទៅ៖

**-ក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសគឺជាប្រាក់៖** ប្រសិនបើកម្មវត្ថុនៃការរឹបអូសគឺជាប្រាក់ អាជ្ញាសាលាអាចដកហូតប្រាក់នោះបាន[68]។ ការអនុវត្តប្រភេទនេះ គឺមានលក្ខណៈងាយស្រួលដែល មិនចាំបាច់ទាមទារ ឱ្យមានអនុវត្តចាត់ចែងប្តូរជាប្រាក់ម្តងទៀតទេ ពោលគឺអាជ្ញាសាលា អាចបន្តអនុវត្តនីតិវិធីដល់ការចែកចំណែកបាន។

**-ក្នុងករណីដែលកម្មវត្ថុនៃការរឹបអូស គឺជាចលនវត្ថុផ្សេងពីប្រាក់៖** ក្នុងករណីរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត អាជ្ញាសាលាអាចរឹបអូសចលនវត្ថុនោះ ដោយគ្រាន់តែផ្អែកទៅលើរូបភាពខាងក្រោយនៃការកាន់កាប់របស់កូនបំណុលប៉ុណ្ណោះ ដោយមិនចាំបាច់ស្រាវជ្រាវអំពីរឿងរ៉ាវ

---

[65] មាត្រា៣៩២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[66] មាត្រា៣៨៤ កថាខណ្ឌទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[67] មាត្រា៣៨៤ កថាខណ្ឌទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[68] មាត្រា៣៨៥ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ពាក់ព័ន្ធជាមួយនឹងកម្មសិទ្ធិអ្វីឡើយ។ មូលហេតុដែលអាជ្ញាសាលា មិនចាំបាច់ធ្វើការស្រាវជ្រាវអំពីកម្មសិទ្ធិនៃចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសនោះមានដូចជា៖

- **ជាទ្រឹស្តីច្បាប់៖** ចលនវត្ថុនៅដៃអ្នកណាអ្នកនោះជាម្ចាស់។ ករណីនេះ ជាគោលការណ៍សន្មត់នៃច្បាប់ ដែលគ្រាន់តែទាមទារឱ្យមានការកាន់កាប់ដោយកូនបំណុលនៃការអនុវត្តតែប៉ុណ្ណោះ ពោលគឺអាជ្ញាសាលា អាចសន្មត់ថាចលនវត្ថុនោះជា កម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្តបានដោយពុំចាំបាច់ធ្វើការស្រាវជ្រាវជាមុនឡើយ។ មានន័យថា ប្រសិនបើអាជ្ញាសាលាប្រទះឃើញចលនវត្ថុដែលកំពុងស្ថិតនៅ ទីកន្លែងដែលត្រូវរឹបអូសនោះ ទោះបីជាចលនវត្ថុនោះជាកម្មសិទ្ធិរបស់តតិយជនក៏ដោយ ក៏អាជ្ញាសាលាអាចរឹបអូសបានដែរ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើមើលពីរូបភាពខាងក្រៅនៃការកាន់កាប់ គេអាចដឹងយ៉ាងច្បាស់ថា ទ្រព្យនោះជារបស់អ្នកដទៃ ការរឹបអូសនោះមិនត្រូវធ្វើឡើងទេ។
  **ឧទាហរណ៍៖** សៀវភៅបិទស្លាក សញ្ញាខ្ចីពីបណ្ណាល័យ, ម៉ូតូមានសញ្ញាអង្គការ ជាអាទិ៍ ករណីបែបនេះ អាជ្ញាសាលា មិនអាចរឹបអូសបានទេ ។
- **ដើម្បីពន្លឿននូវនីតិវិធីអនុវត្តដោយបង្ខំ៖** ដូចដែលយើងបានដឹងរួចមកហើយថា ទោះបីជាមានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់អំពីការអនុវត្តដោយបង្ខំត្រូវបានធ្វើឡើងក៏ដោយ ក៏អានុភាពនៃការផ្អាកការអនុវត្តក៏មិនត្រូវបានកើតឡើង ដោយឯកឯងនោះដែរ[69]។ ដោយហេតុថាច្បាប់បញ្ញត្តិបែបនេះគឺដើម្បីមិនឱ្យមានការរារាំង ឬមានការរាំងស្ទះដល់ដំណើរការនីតិវិធីនៃការអនុវត្តដោយបង្ខំ។ ដូចគ្នានេះដែរ ការស្រាវជ្រាវអំពីកម្មសិទ្ធិលើចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត គឺជានីតិវិធី មួយដែលទាមទារឱ្យមានការប្រើអំឡុងពេលយូរអង្វែង និងឆ្លងកាត់នីតិវិធីដ៏ស្មុគស្មាញ ដែលក្នុងនោះ ប្រសិនបើច្បាប់កំណត់ឱ្យអាជ្ញាសាលាត្រូវស្រាវជ្រាវអំពីកម្មសិទ្ធិលើចលនវត្ថុនៅមុនការរឹបអូសនោះប្រាកដជាមានការពិបាក និងធ្វើឱ្យម្ចាស់បំណុលមិនអាចសម្រេចសិទ្ធិរបស់ខ្លួនបានឡើយ ពោលគឺជាការរាំងស្ទះនូវដំណើរការនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដោយអាជ្ញាសាលា។
- **បើកផ្លូវឱ្យមានបណ្តឹងតវ៉ាដោយតតិយជន[70]៖** ទោះបីជាច្បាប់មិនតម្រូវឱ្យអាជ្ញាសាលាធ្វើការស្រាវជ្រាវអំពីកម្មសិទ្ធិនៅមុនការរឹបអូសក៏ពិតមែន ប៉ុន្តែវានឹងមិនធ្វើឱ្យប៉ះពាល់ដល់តតិយជនដែលមានសិទ្ធិស្របច្បាប់លើចលនវត្ថុដែលបានរឹបអូសនោះទេ ដោយហេតុនៅក្នុងនីតិវិធីនៃ

[69] មាត្រា៣៤៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[70] មាត្រា៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ការអនុវត្តដោយបង្ខំ បានបើកផ្លូវឱ្យតតិយជនដែលមានសិទ្ធិស្របច្បាប់ អាចដាក់ពាក្យបណ្តឹងតវ៉ាដោយតតិយជនបាន ដោយអនុលោមតាមបញ្ញត្តិនៃ(មាត្រា៣៦៥នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត អាជ្ញាសាលាអាចចូលទៅក្នុងទីកន្លែងរស់នៅរបស់កូនបំណុលនៃការអនុវត្ត ឬកន្លែងផ្សេងទៀត ដែលកូនបំណុលនៃការអនុវត្តកាន់កាប់ ហើយអាចឆែកឆេររកចលនវត្ថុដែលអាចរឹបអូសនោះបាន[71]។ មានន័យថាគ្រប់ទីកន្លែងដែលកូនបំណុលនៃការអនុវត្តបានកាន់កាប់ អាជ្ញាសាលាអាចចូលទៅកាន់កាប់ និងឆែកឆេររកគ្រប់ចលនវត្ថុដែលអាចរឹបអូសបានទាំងអស់។ ប្រសិនបើមានភាពចាំបាច់ អាជ្ញាសាលាអាចធ្វើការចាត់ចែងដើម្បីបើកទ្វាដែលបិទជិត ទូដែក និងប្រអប់ផ្សេងៗបាន។ ជាមួយគ្នានេះដែរ នៅពេលចុះអនុវត្តរឹបអូស អាជ្ញាសាលាអាចធ្វើការជ្រើសរើសនូវចលនវត្ថុដើម្បីរឹបអូសបានដោយថ្លឹងថ្លែងអំពីផលប្រយោជន៍របស់កូនបំណុលនៃការអនុវត្ត និងម្ចាស់បំណុលនៃការអនុវត្តបាន [72]។ អានុភាពនៃរឹបអូសនឹងកើតមានឡើងនៅពេលដែល អាជ្ញាសាលាកាន់កាប់ចលនវត្ថុរឹបអូសនោះ។

**-ករណីកម្មវត្ថុនៃការរឹបអូសជា រថយន្ត ជាអាទិ៍ដែលបានចុះបញ្ជី៖** ប្រសិនបើចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសនោះ គឺចលនវត្ថុដែលបានចុះបញ្ជីរួចហើយនោះ រួមមានរថយន្ត ទោចក្រយានយន្ត ជាអាទិ៍ អាជ្ញាសាលាត្រូវធ្វើការផ្ទុកផ្តាក់ទៅស្ថាប័នដែលមានសមត្ថកិច្ចឱ្យចុះបញ្ជីរឹបអូស ដោយស្ថាប័ននោះត្រូវសរសេរអំពីហេតុការណ៍នៃការរឹបអូសចូលទៅក្នុងសៀវភៅចុះបញ្ជីនោះ ទើបធ្វើឱ្យការរឹបអូសមានអានុភាព [73]។

### ១.២. ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយម្ចាស់បំណុល

ក្នុងករណីម្ចាស់បំណុលនៃការអនុវត្ត កាន់កាប់ចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តម្ចាស់បំណុលនៃការអនុវត្តអាចប្រគល់ដោយស្ម័គ្រចិត្តនូវចលនវត្ថុនោះទៅឱ្យដល់អាជ្ញាសាលាដើម្បីធ្វើការរឹបអូសបាន [74]។

**ឧទាហរណ៍៖** ចំពោះស្ថានភាពបែបនេះ ម្ចាស់បំណុលនៃការអនុវត្តកាន់កាប់ចលនវត្ថុរបស់កូនបំណុលក្នុងករណីដែលចលនវត្ថុនោះជាកម្មវត្ថុនៃការបញ្ចាំ ឬជាកម្មវត្ថុនៃសិទ្ធិឃាត់ទុក ជាអាទិ៍។

### ១.៣. ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយតតិយជន

ជាដំបូងអាជ្ញាសាលាត្រូវធ្វើការពិនិត្យជាមុនថា តើតតិយជននេះជាអ្នកណា? តើតតិយជននេះមានទំនាក់ទំនងគតិយុត្តយ៉ាងដូចម្តេចជាមួយនឹងកូនបំណុលនៃការអនុវត្ត? ជាក់ស្តែងប្រសិនបើតតិយជននោះស្ថិតនៅក្រោមវិសាលភាពនៃការអនុវត្តដោយបង្ខំតាមបញ្ញត្តិនៃ (មាត្រា៣៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ហើយបាន

[71] មាត្រា៣៨៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[72] មាត្រា៣៨៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[73] មាត្រា៣៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[74] មាត្រា៣៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

បំពេញល័ក្ខខ័ណ្ឌត្រឹមត្រូវរួចហើយ អាជ្ញាសាលាអាចធ្វើការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយតតិយជននោះបាន។

ក្នុងករណីចលនវត្ថុជាកម្មវត្ថុនៃការអនុវត្តស្ថិតនៅក្រោមការកាន់កាប់របស់តតិយជន អាជ្ញាសាលាអាចរឹបអូសចលនវត្ថុនោះបាន លុះត្រាតែតតិយជននោះមិនបដិសេធអំពីការប្រគល់ចលនវត្ថុនោះ[75] ព្រោះថាអាជ្ញា-សាលា មិនអាចធ្វើការរឹបអូសនូវចលនវត្ថុដែលកាន់កាប់ដោយបុគ្គលផ្សេងពីកូនបំណុលនៃការអនុវត្តដោយផ្អែកលើលិខិតអនុវត្តដែលកំណត់ឈ្មោះរបស់កូនបំណុលនៃការអនុវត្តនោះបានទេ។

ផ្ទុយមកវិញប្រសិនបើតតិយជនបដិសេដមិនព្រមប្រគល់ចលនវត្ថុទនោះ ម្ចាស់បំណុលនៃការអនុវត្តពុំមានជម្រើសអ្វីក្រៅពីធ្វើការរឹបអូសសិទ្ធិទាមទារឱ្យប្រគល់វត្ថុដែលកូនបំណុលមានចំពោះតតិយជននោះតាមរយៈនីតិវីធីអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យប្រគល់វត្ថុនោះទៅឲ្យអាជ្ញាសាលា [76]។

### ២. ការថែរក្សាវត្ថុដែលត្រូវបានរឹបអូស

#### ២.១. គោលការណ៍នៃការកាន់កាប់ដោយអាជ្ញាសាលា

ជាគោលការណ៍ ចលនវត្ថុដែលត្រូវបានរឹបអូសត្រូវស្ថិតក្រោមការកាន់កាប់ដោយអាជ្ញាសាលា[77] មានន័យថាមានតែអាជ្ញាសាលាទេដែលមានសិទ្ធិកាន់កាប់ និងថែរក្សាចលនវត្ថុដែលត្រូវបានរឹបអូស។ ការរឹបអូសចលនវត្ថុនឹងមានអានុភាពតាមការកាន់កាប់ចលនវត្ថុរឹបអូសដោយអាជ្ញាសាលា ប្រសិនបើអាជ្ញាសាលាមិនកាន់កាប់នូវចលនវត្ថុនៃការរឹបអូសទេនោះ កូនបំណុលនៃការអនុវត្តមានឱកាសគ្រប់ពេលក្នុងការចាត់ចែងនូវចលនវត្ថុនោះ ដែលអាចនឹងធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្តជួបបញ្ហាលំបាកក្នុងការសម្រេចនូវសិទ្ធិទាមទារជាប្រាក់របស់ខ្លួន។

#### ២.២. ការអនុញ្ញាតឱ្យគ្រប់គ្រងថែរក្សា ឬប្រើប្រាស់ចលនវត្ថុរឹបអូស

ទោះបីជាការរឹបអូសចំពោះចលនវត្ថុ នឹងមានអានុភាពតាមរយៈការកាន់កាប់ដោយអាជ្ញាសាលាក៏ដោយក៏អាជ្ញាសាលាអនុញ្ញាតឱ្យកូនបំណុលនៃការអនុវត្ត ឬតតិយជនថែរក្សា ប្រើប្រាស់ចលនវត្ថុដែលត្រូវរឹបអូសនោះបានដែរ ប្រសិនបើអាជ្ញាសាលាយល់ថាសមរម្យ។

**-ចំពោះការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត៖** ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត នឹងមានអានុភាពតាមរយៈការកាន់កាប់ដោយអាជ្ញាសាលា ប៉ុន្តែប្រសិនបើយល់ថាសមរម្យដូចជា ការគ្រប់គ្រងថែរក្សាចលនវត្ថុរឹបអូសដោយ អាជ្ញាសាលានឹងត្រូវចំណាយច្រើន មានការលំបាកក្នុងការដឹកជញ្ជូន ការគ្រប់គ្រងដោយកូនបំណុលមានភាពងាយស្រួលជាងនោះ អាជ្ញាសាលាអាច

[75] មាត្រា៣៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[76] មាត្រា៤០២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[77] មាត្រា៣៨៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

អនុញ្ញាតឱ្យកូនបំណុលគ្រប់គ្រងថែរក្សាបាន[78]។ ករណីនេះអានុភាពនៃការរឹបអូសចលនវត្ថុនោះ នឹងកើតមានឡើងតាមរយៈ ***ការបិទស្លាក ឬដាក់សញ្ញារឹបអូសផ្សេងទៀត*** លើចលនវត្ថុដែលត្រូវបានរឹបអូសនោះ។ លើសពីនេះទៅទៀតនោះ បើយល់ថាសមរម្យ អាជ្ញាសាលាអាចអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់ចលនវត្ថុនោះបាន[79]។ តែការអនុញ្ញាតនេះអាជ្ញាសាលាអាចលុបចោលវិញបាន ប្រសិនបើចលនវត្ថុដែលអាជ្ញាសាលាអនុញ្ញាតឱ្យកូនបំណុលគ្រប់គ្រង បែរជាធ្លាក់ទៅដល់ដៃតតិយជននោះ ម្ចាស់បំណុលអាចដាក់ពាក្យសុំទៅសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ ដើម្បីចេញដីកាសម្រេចបង្គាប់ឱ្យប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូស ទៅឱ្យអាជ្ញាសាលាគ្រប់គ្រងបាន ដែលពាក្យសុំនេះអាចត្រូវបានធ្វើឡើងក្នុងអំឡុងពេល ១សប្តាហ៍ គិតចាប់ពីថ្ងៃដែលដឹងថាតតិយជនបានកាប់កាប់ [80]។

**-ចំពោះការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយតតិយជន៖** បើយល់ថាសមរម្យ អាជ្ញាសាលាក៏អាចប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូសនោះទៅឱ្យតតិយជននោះថែរក្សាគ្រប់គ្រងបានដែរ ហើយករណីនេះអាជ្ញាសាលាត្រូវបិទស្លាក ឬដាក់សញ្ញារឹបអូសផ្សេងទៀតលើចលនវត្ថុរឹបអូសនោះ ទើបធ្វើឱ្យការរឹបអូសមានអានុភាព[81]។

### កថាភាគទី៣ ៖ អានុភាពនៃការរឹបអូសចលនវត្ថុ

ជាគោលការណ៍អានុភាពនៃការរឹបអូសចលនវត្ថុនឹងកើតមានតាមរយៈការកាន់កាប់ដោយអាជ្ញាសាលា ។ លើកលែងតែការរឹបអូសចលនវត្ថុដែលមានការចុះបញ្ជីដែលអានុភាពនៃការរឹបអូសនឹងកើតមាននៅពេលចុះបញ្ជីអំពីការរឹបអូសនៅក្នុងសៀវភៅចុះបញ្ជី និងការរឹបអូសចលនវត្ថុដែលអាជ្ញាសាលាអនុញ្ញាតឱ្យកូនបំណុលនៃការអនុវត្ត ឬបុគ្គលផ្សេងពីកូនបំណុលនៃការអនុវត្តថែរក្សា អានុភាពនឹងកើតមាននៅពេលចលនវត្ថុនោះបានបិតស្លាក ឬដាក់សញ្ញាសម្គាល់ថាបានរឹបអូស។ ការរឹបអូសចលនវត្ថុដោយអាជ្ញាសាលា នឹងមានអានុភាពមួយចំនួនដូចជា៖

#### ១. ការហាមឃាត់មិនឱ្យកូនបំណុលធ្វើការចាត់ចែងលើចលនវត្ថុរឹបអូស

ការរឹបអូសចលនវត្ថុដោយអាជ្ញាសាលា នឹងមានអានុភាពហាមឃាត់កូនបំណុលនៃការអនុវត្តមិនឱ្យធ្វើការចាត់ចែងនូវចលនវត្ថុដែលត្រូវបានរឹបអូសនោះទេ។ ជាក់ស្តែង ដូចដែលយើងបានដឹងរួចមកហើយថា ការរឹបអូសចលនវត្ថុ ជាគោលការណ៍ត្រូវធ្វើឡើងតាមរយៈការកាន់កាប់ដោយអាជ្ញាសាលា (មាត្រា៣៨៥ កថាខណ្ឌទី១) ដែលករណីនេះជាល័ក្ខខ័ណ្ឌតតាំងមួយដែលមិនអនុញ្ញាតឱ្យកូនបំណុលនៃការអនុវត្តមានលទ្ធភាពក្នុងការចាត់ចែងចលនវត្ថុនោះបានឡើយ។ ចលនវត្ថុដែលត្រូវបានរឹបអូសស្ថិតនៅក្រោមការគ្រប់គ្រង និងថែរក្សាដោយកូន

---

[78] មាត្រា៣៨៥ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[79] មាត្រា៣៨៥ កថាខណ្ឌទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[80] មាត្រា៣៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[81] មាត្រា៣៨៦, មាត្រា៣៨៤ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

បំណុលនៃការអនុវត្ត តាមបញ្ញត្តិនៃ (មាត្រា៣៨៥ កថាខណ្ឌទី៤) ដែលហាក់ដូចជាការផ្តល់ឱកាសឱ្យកូនបំណុលនៃការអនុវត្តអាចធ្វើការចាត់ចែងនូវចលនវត្ថុនោះក្តី តែតតិយជនដែលទទួលការផ្ទេរការកាន់កាប់ នៅក្រោយពេលការរឹបអូសនោះ មិនអាចតតាំងជាមួយនឹងម្ចាស់បំណុលនៃការអនុវត្តបានទេ ទោះជាបីជាខ្លួនបានបំពេញនូវល័ក្ខខ័ណ្ឌតតាំងតាមក្រមរដ្ឋប្បវេណីក៏ដោយ។

**២.អានុភាពចំពោះផលធម្មជាតិ**

ការរឹបអូសមានអានុភាពទៅលើផលធម្មជាតិ[82] ដែលកើតចេញពីចលនវត្ថុដែលត្រូវបានរឹបអូសនោះផងដែរ។ មានន័យថានៅពេលដែលអាជ្ញាសាលាបានរឹបអូសចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត ដែលជាវត្ថុបង្កើតផល **(វត្ថុដើម)** [83]ហើយបន្ទាប់ពីបានរឹបអូសមកចលនវត្ថុនោះបានបង្កើតផលធម្មជាតិ។ ករណីនេះវិសាលភាពនៃការរឹបអូសត្រូវមានលើផលធម្មជាតិនោះដែរ[84] ដោយម្ចាស់បំណុលពុំចាំបាច់សុំធ្វើការរឹបអូសចលនវត្ថុដែលជាផលធម្មជាតិនោះជាថ្មីទេ។

**ឧទាហរណ៍៖** ការរឹបអូសសត្វគោដើម ដែលអំឡុងពេលនៃការរឹបអូសនោះ មេគោនោះបានកើតកូនគោដូច្នេះ កូនគោនោះក៏ត្រូវស្ថិតនៅក្រោមការរឹបអូសដែរ។ មូលហេតុដែលកំណត់បែបនេះដោយហេតុថា គឺមិនចង់ឱ្យមាននីតិវិធីសុំរឹបអូសជាថ្មីចំពោះផលដែលកើតពីវត្ថុដើម **(ដែលជាចលនវត្ថុត្រូវបានរឹបអូសរួច)**។

ចលនវត្ថុដែលត្រូវបានរឹបអូសស្ថិតនៅក្រោមការគ្រប់គ្រង ឬថែរក្សាដោ កូនបំណុលនៃការអនុវត្ត តាមបញ្ញត្តិនៃ (មាត្រា៣៨៤ កថាខណ្ឌទី៤ និងទី៥) ដែលហាក់បីដូចជាកូនបំណុលនៃការអនុវត្តកំពុងកាន់កាប់ចលនវត្ថុនោះក៏ដោយ ក៏កូនបំណុលនៃការអនុវត្តអាចត្រូវបានគ្រប់គ្រង និងប្រើប្រាស់ផលនោះបាន លុះត្រាតែទទួលការអនុញ្ញាតពីអាជ្ញាសាលា ហើយអានុភាពនៃការរឹបអូសនឹងត្រូវបិទស្លាក ឬដាក់សញ្ញារឹបអូស។

**៣. ការរឹបអូសចលនវត្ថុដែលត្រូវបានរឹបអូសពីតតិយជន**

ប្រសិនបើចលនវត្ថុដែលត្រូវបានរឹបអូស បែរជាធ្លាក់ទៅក្រោមការកាន់កាប់របស់តតិយជនមិនមែនផ្អែកលើការចាត់ចែងរបស់អាជ្ញាសាលា សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចបង្គាប់ឱ្យតតិយជននោះប្រគល់ចលនវត្ថុនោះទៅអាជ្ញាសាលាបាន ដោយដីកាសម្រេចតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត[85]។ ក្នុងស្ថានភាពនេះអាចមានឧទាហរណ៍ថា អាជ្ញាសាលាអនុញ្ញាតឱ្យកូនបំណុលនៃការអនុវត្តគ្រប់គ្រងថែរក្សាចលនវត្ថុដែលត្រូវបានរឹបអូស ហើយកូនបំណុលនៃការអនុវត្ត បានចាត់ចែងផ្ទេរការកាន់កាប់ចលនវត្ថុនោះទៅឱ្យតតិយជន។

[82] ផលធម្មជាតិ សំដៅវត្ថុដែលបានកើតឡើង ហើយត្រូវបានលទ្ធកម្ម តាមវិធីប្រើធម្មតា

[83] មាត្រា៣៨៦, មាត្រា៣៨៤ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[84] មាត្រា១២៧ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[85] មាត្រា៣៩០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ដីកាសម្រេចនេះអាចចេញបាន ទោះបីជាតតិយជនលើកយកសិទ្ធិកាន់កាប់វត្ថុ នោះមកអះអាងក៏ដោយ ព្រោះថាប្រព័ន្ធនេះរៀបចំឡើងដើម្បីធ្វើបដិទានស្ថានភាព ដើម្បីឱ្យបានងាយស្រួល និងឆាប់រហ័ស ដើម្បីអាចលើកយកសិទ្ធិកាន់កាប់មកអះអាងបាន តតិយជនត្រូវដាក់ពាក្យបណ្តឹងតវ៉ាដោយតតិយជន [86]។

ពាក្យសុំឱ្យចេញដីកាសម្រេចបង្គាប់ឱ្យប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូស ត្រូវធ្វើឡើងក្នុងអំឡុងពេល ០១សប្តាហ៍ គិតចាប់ពីថ្ងៃដែលម្ចាស់បំណុលនៃការអនុវត្តបានដឹងថាចលនវត្ថុដែលត្រូវបានរឹបអូសនោះកាន់កាប់ដោយតតិយជន[87]។ បើអំឡុងពេល ០១សប្តាហ៍ នេះកន្លងផុតម្ចាស់បំណុលមិនអាចដាក់ពាក្យសុំនេះបានទេ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថាបើទុករយៈពេលវែងពេកសម្រាក់ការដាក់ពាក្យសុំ នោះនឹងប៉ះពាល់ទៅដល់ស្ថិរភាពនៃទំនាក់ទំនងគតិយុត្ត។

## ផ្នែកទី៣ ៖ ការប្តូរជាប្រាក់ និងការចែកចំណែក

### កថាភាគីទី១ ៖ ការប្តូរជាប្រាក់នូវទ្រព្យសម្បត្តិដែលត្រូវបានរឹបអូស

បន្ទាប់ពីចលនវត្ថុត្រូវបានរឹបអូសរួចរាល់អស់ហើយ អាជ្ញាសាលាត្រូវរៀបចំចាត់ចែងប្តូរជាប្រាក់នូវចលនវត្ថុដែលត្រូវបានរឹបអូសតាមរយៈការលក់ដោយបង្ខំ។ ខាងក្រោមនេះនឹងមានរៀបរាប់អំពីវិធីលក់ចលនវត្ថុដោយបង្ខំ បុគ្គលដែលមិនអាចធ្វើសំណើទិញបាន នីតិវិធីលក់ចលនវត្ថុ និងការលក់ចលនវត្ថុរឹបអូសក្នុងពេលដែលការអនុវត្តកំពុងផ្អាក។

#### ១. វិធីលក់ចលនវត្ថុដោយបង្ខំ

ការលក់ចលនវត្ថុដែលត្រូវបានរឹបអូស គឺត្រូវធ្វើតាមវិធីលក់ឡាយឡុងដោយ ផ្ទាល់មាត់ ឬដោយដាក់លក់ដោយស្រោមសំបុត្រ ឬដាក់លក់តាមវីធីផ្សេងទៀត ដែលអាជ្ញាសាលាយល់ថាសមរម្យដោយទទួលការអនុញ្ញាតពីសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ ដែលក្នុងនោះអ្នកប្រតិបត្តិការលក់គឺអាជ្ញាសាលា [88]។

**-ការលក់ឡាយឡុងដោយផ្ទាល់មាត់៖** ធ្វើឡើងដោយការស្នើចំនួនទឹកប្រាក់ថ្លៃទិញ ហើយអាជ្ញាសាលានឹងប្រកាសអំពីការអនុញ្ញាតឱ្យទិញ ចំពោះអ្នកស្នើដែលហ៊ានឱ្យថ្លៃខ្ពស់ជាងគេ។ ក្នុងចំណោមវិធីលក់ចលនវត្ថុ ការលក់ឡាយឡុងដោយផ្ទាល់មាត់ គឺជាវិធីមួយដែលសមរម្យងាយស្រួលក្នុងការអនុវត្ត។

**-ការលក់ឡាយឡុងដោយស្រោមសំបុត្រ៖** ធ្វើឡើងតាមវិធីដែលអ្នកស្នើសុំទិញ ដាក់ពាក្យសុំទិញជាលាយលក្ខណ៍អក្សរ ហើយអាជ្ញាសាលានឹងបើកស្រោមសំបុត្រភ្លាមបន្ទាប់ពីដេញថ្លៃ រួចប្រកាសឈ្មោះ និងថ្លៃដេញរបស់បុគ្គលដែលហ៊ានឱ្យថ្លៃជាងគេ ព្រមទាំងការអនុញ្ញាតឱ្យបុគ្គលនោះទិញ វិធីលក់ឡាយឡុងដោយស្រោម

[86] មាត្រា៣៦៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[87] មាត្រា៣៩០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[88] មាត្រា៣៩៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

សំបុត្រនេះ គេច្រើនយកមកអនុវត្តនៅក្នុងការលក់ចលនវត្ថុដែលមានតម្លៃខ្ពស់ ហើយដែលអាចកំណត់តម្លៃអប្បបរមា តាមការវាយតម្លៃរបស់អ្នកវាយតម្លៃ។

**-ការលក់តាមវិធីផ្សេងក្រៅពីវិធីលក់ឡាយឡុងដោយផ្ទាល់មាត់ ឬដោយស្រោមសំបុត្រ៖** ប្រសិនបើអាជ្ញាសាលាយល់ថាសមរម្យដោយគិតពិចារណាអំពីប្រភេទ និងចំនួននៃចលនវត្ថុ អាទិ៍ អាជ្ញាសាលា អាចអនុវត្តការលក់ចលនវត្ថុ ដែលត្រូវបានរឹបអូសផ្សេងពីវិធីទាំងពីរខាងលើ ឬឱ្យបុគ្គលផ្សេងពីអាជ្ញាសាលាអនុវត្តការលក់ចលនវត្ថុដែលត្រូវបានរឹបអូស ដោយទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅបាន[89]។ វិធីផ្សេងនោះអាចមានដូចជា៖ ការលក់ចលនវត្ថុនៅក្នុងពិធីតាំងពិពណ៌, ការយកចលនវត្ថុដែលត្រូវបានរឹបអូសទៅលក់នៅកន្លែងដែលងាយលក់ ឬការអនុញ្ញាតឱ្យបុគ្គលដែលមានបទពិសោធន៍ខ្លាំងក្នុងការលក់ចលនវត្ថុដែលមានប្រភេទដូចគ្នានឹងចលនវត្ថុដែលត្រូវបានរឹបអូស។ល។

**ឧទាហរណ៍៖** អាជ្ញាសាលាបានរឹបអូសគ្រឿងម៉ាស៊ីនរថយន្ត ករណីបើយល់ថាសមរម្យ គួរអនុញ្ញាតឱ្យអ្នកលក់គ្រឿងម៉ាស៊ីនជាអ្នកលក់ជំនួសអាជ្ញាសាលា។

### ២. បុគ្គលដែលមិនអនុញ្ញាតឱ្យដាក់សំណើទិញ

នៅពេលដែលអាជ្ញាសាលាអនុវត្តការលក់ចលនវត្ថុដែលត្រូវបានរឹបអូសបុគ្គលដែលមិនត្រូវបានអនុញ្ញាតឱ្យដាក់សំណើទិញចលនវត្ថុនោះ រួមមាន ៖

-កូនបំណុលនៃការអនុវត្ត [90]។

-បុគ្គលដែលត្រូវបានកម្រិតសមត្ថភាព ក្នុងការធ្វើសកម្មភាពដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី ដូចជាអនីតិជន, ជននៅក្រោមអាណាព្យាបាលទូទៅ, ជននៅក្រោមហិតូបត្ថម្ភ [91]និងបុគ្គលដែលខ្វះសមត្ថភាពខាងឆន្ទៈ[92]។

-បុគ្គលដែលច្បាប់កំណត់មិនអាចក្លាយជាអ្នកទិញបានរួមមាន[93]៖

- **អ្នកគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់ តាមផ្លូវតុលាការ ឬតាមកិច្ចសន្យា៖** មិនអាចក្លាយជាអ្នកទិញដោយការលក់ដោយបង្ខំនូវទ្រព្យសម្បត្តិដែលខ្លួនទទួលភារកិច្ចលក់ដោយផ្ទាល់ខ្លួន ឬតាមរយៈអន្តរការីបានឡើយ។
- **មន្ត្រីរាជការដែលទទួលបន្ទុកចាត់ការលក់ដោយបង្ខំទទួលបន្ទុកគ្រប់គ្រងការលក់ដោយបង្ខំ៖** ក៏មិនអាចក្លាយជាអ្នកទិញបានដែរ។

---

[89] មាត្រា៣៩០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[90] មាត្រា៣៩៥ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[91] មាត្រា១៦ ក្រមរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[92] មាត្រា១៤ ក្រមរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[93] មាត្រា៥២៥, មាត្រា៥២៦ ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

- **ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី ឬមន្ត្រីតុលាការផ្សេងទៀត៖** មិនអាចក្លាយជាអ្នកទិញដោយការលក់ដោយបង្ខំ ដោយផ្ទាល់ខ្លួន ឬតាមរយៈអន្តរការីនូវវត្ថុ ឬសិទ្ធិដែលជាកម្មវត្ថុនៃវិវាទដែលកំពុងចាត់ការនៅតុលាការដែលខ្លួនបំពេញភារកិច្ចបានទេ។
- **មេធាវី ឬសារការី៖** មិនអាចក្លាយជាអ្នកទិញ ដោយការលក់ដោយបង្ខំនូវវត្ថុ ឬសិទ្ធិដែលទាក់ទងនឹងរឿងក្តីដែលខ្លួនទទួលបន្ទុក។

-អ្នកទិញដែលមិនបានបង់ថ្លៃទិញចលនវត្ថុក្នុងពេលលក់លើកទី១ មិនអាចដាក់សំណើទិញជាថ្មីនៅក្នុងការលក់ចលនវត្ថុដោយបង្ខំ ម្តងទៀតបានទេ[94] ។

-បុគ្គលដែលអាជ្ញាសាលាមិនអនុញ្ញាតឱ្យដាក់សំណើទិញ ដោយសារបានធ្វើសកម្មភាពរំខានកុំឱ្យការអនុវត្តលក់ធ្វើឡើង ដោយត្រឹមត្រូវដូចជាធ្វើឱ្យរំខានដល់បុគ្គលដទៃក្នុងការធ្វើសំណើទិញ ឬបានឃុបឃិតដើម្បីបញ្ចុះតម្លៃដោយមិនត្រឹមត្រូវ [95]។

### ៣. នីតិវិធីនៃការលក់ចលនវត្ថុដោយបង្ខំ

ការលក់ចលនវត្ថុដែលត្រូវបានរឹបអូស អាចមានលក្ខណៈប្រែប្រួល អាស្រ័យទៅតាមវិធីនៃការលក់ និងប្រភេទនៃចលនវត្ថុដែលនឹងត្រូវលក់។

**-ចំពោះចលនវត្ថុដែលនឹងត្រូវលក់អាចកំណត់តម្លៃដោយអាជ្ញាសាលាបាន៖** ការលក់ចលនវត្ថុដែលអាជ្ញាសាលា អាចវាយតម្លៃបាននោះជាដំបូងអាជ្ញាសាលាត្រូវកំណត់តម្លៃអប្បបរមានៃចលនវត្ថុ, វិធីនៃការលក់ចលនវត្ថុ (ស្រោមសំបុត ឬផ្ទាល់មាត់) កាលបរិច្ឆេទពេលវេលា និងទីកន្លែងនៃការលក់ជាមុនសិន។ បន្ទាប់មកអាជ្ញាសាលាត្រូវជូនដំណឹងជាសាធារណៈ អំពីចលនវត្ថុដែលនឹងត្រូវដាក់លក់ និងវិធីលក់ចលនវត្ថុ ដោយបិទប្រកាសនៅកន្លែងបិទប្រកាសរបស់តុលាការ (មាត្រា៣៩៥ កថាខណ្ឌទី៣)។ នៅកាលបរិច្ឆេទនៃការអនុវត្តការលក់ អាជ្ញាសាលាត្រូវជូនដំណឹងជាសាធារណៈលក់ចលនវត្ថុនោះដោយបញ្ជាក់អំពីតម្លៃអប្បបរមា ហើយចាប់ផ្តើមឱ្យអ្នកស្នើសុំទិញ ដេញថ្លៃតាមវិធីដែលបានជូនដំណឹង។ នៅពេលបញ្ចប់ការដាក់សំណើទិញ អាជ្ញាសាលាត្រូវប្រកាសឈ្មោះអ្នកទិញនិងតម្លៃដែលខ្ពស់ជាងគេ។ បន្ទាប់មកអាជ្ញាសាលាត្រូវប្រកាសអនុញ្ញាតឱ្យទិញ ដែលករណីនេះអ្នកទិញត្រូវបង់ថ្លៃទិញភ្លាមៗ ទើបទទួលបាននូវលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះបាន។ ក្នុងករណីដែលអ្នកទិញមិនបានបង់ថ្លៃទិញទេ អាជ្ញាសាលាត្រូវដាក់លក់ឡាយឡុងម្តងទៀតតាមវិធីដូចខាងដើមនៅពេលនោះអ្នកទិញមុនមិនអាចដាក់សំណើទិញបានទៀតទេ[96] ។

[94] មាត្រា៣៩៥ កថាខណ្ឌទី៦ ក្រមរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[95] មាត្រា៣៩៦ ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[96] មាត្រា៣៩៥ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

**-ចំពោះចលនវត្ថុដែលនឹងត្រូវលក់ទាមទារឱ្យមានការវាយតម្លៃពីអ្នកវាយតម្លៃ៖** ប្រសិនចលនវត្ថុដែលជាកម្មវត្ថុនៃការដាក់លក់ឡាយឡុងនោះបានតម្លៃខ្ពស់ ជាដំបូងអាជ្ញាសាលាត្រូវជ្រើសតាំងអ្នកវាយតម្លៃ ហើយឱ្យអ្នកវាយតម្លៃនោះត្រូវ ធ្វើការវាយតម្លៃលើចលនវត្ថុនោះ។ បន្ទាប់ពីបានទទួលរបាយការណ៍ពីអ្នកវាយតម្លៃរួចហើយ អាជ្ញាសាលាត្រូវកំណត់តម្លៃលក់អប្បបរមានៃចលនវត្ថុនោះ វិធីលក់ឡាយឡុង កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃការលក់ បន្ទាប់មកអាជ្ញាសាលា ត្រូវធ្វើការជូនដំណឹងជាសាធារណៈ អំពីចលនវត្ថុដែលនឹងត្រូវដាក់លក់ និងវិធីលក់ចលនវត្ថុ ដោយបិទប្រកាសនៅកន្លែងបិទប្រកាសរបស់តុលាការ[97] នៅកាលបរិច្ឆេទនៃការលក់ អាជ្ញាសាលាត្រូវប្រកាសលក់ចលនវត្ថុនោះ ដោយបញ្ជាក់អំពីតម្លៃអប្បបរមា ហើយចាប់ផ្ដើមឱ្យអ្នកស្នើសុំទិញដាក់សំណើទិញតាមវិធីដែលបានជូនដំណឹង។ នៅពេលបញ្ចប់ការដាក់សំណើទិញ អាជ្ញាសាលាត្រូវប្រកាសឈ្មោះអ្នកទិញ និងតម្លៃដែលខ្ពង់ជាងគេ បន្ទាប់មកអាជ្ញាសាលាត្រូវប្រកាសអនុញ្ញាតឱ្យទិញដែលករណីនេះអ្នកទិញត្រូវបង់ថ្លៃទិញភ្លាមៗ ទើបទទួលបាននូវលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះបាន។ ក្នុងករណីដែលអ្នកទិញមិនបានបង់ថ្លៃទិញទេ អាជ្ញាសាលាត្រូវដាក់លក់ឡាយឡុងម្តងទៀតតាមវិធីដូចខាងដើម នៅពេលនោះអ្នកទិញមុនមិនអាចដាក់សំណើទិញបានទៀតទេ (មាត្រា ៣៩៥ កថាខណ្ឌទី៦)។

ខាងក្រោមនេះ គឺជាលំហូរនីតិវិធីលក់ឡាយឡុងនូវចលនវត្ថុដែលបានរឹបអូសរួច ត្រូវដកស្រង់ចេញពីការអនុវត្តជាក់ស្តែងក្នុងនាមជាអាជ្ញាសាលាកន្លងមក៖

-បន្ទាប់ពីបានចាត់ចែងនីតិវិធីរឹបអូសចលនវត្ថុរួចហើយ អាជ្ញាសាលាត្រូវរៀបចំចាត់ចែងនីតិវិធីលក់ដោយផ្ដើមដោយជ្រើសតាំងអ្នកវាយតម្លៃលើចលនវត្ថុ។

- អ្នកវាយតម្លៃត្រូវផ្តល់នូវរបាយការណ៍នៃការវាយតម្លៃចលនវត្ថុ នោះមកឱ្យអាជ្ញាសាលា។

- អាជ្ញាសាលាត្រូវកំណត់តម្លៃលក់ចលនវត្ថុអប្បបរមា។

-អាជ្ញាសាលាត្រូវធ្វើការផ្សាយជាសាធារណៈអំពីការលក់ឡាយឡុងចំពោះចលនវត្ថុ ដោយកំណត់អំពីសញ្ញាណនៃចលនវត្ថុ តម្លៃលក់អប្បបរមា វិធីលក់ ទីកន្លែង កាលបរិច្ឆេទ ពេលវេលា និងទឹកប្រាក់ធានាលើសំណើទិញ ជាអាទិ៍ ។ល។

-បុគ្គលដែលមានបំណងចង់ទិញចលនវត្ថុនោះ ត្រូវដាក់ពាក្យសុំចូលរួម ធ្វើសំណើទិញ ឬ ពាក្យសុំចូលរួមដេញថ្លៃ មកកាន់អាជ្ញាសាលា ដោយតម្រូវឱ្យបំពេញនូវល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងការផ្សាយជាសាធារណៈដែលធ្វើឡើយអាជ្ញាសាលា។

[97] មាត្រា៣៩៥ កថាខណ្ឌទី៣ ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

-នៅកាលបរិច្ឆេទ និង ពេលវេលានៃការលក់ អាជ្ញាសាលាត្រូវធ្វើការផ្ទៀតផ្ទាត់នូវអត្តសញ្ញាណ និង ភាពស្របច្បាប់របស់អ្នកចូលរួមធ្វើសំណើទិញ នៅមុនពេលចាប់ឱ្យធ្វើសំណើទិញ។

-ចំពោះវិធីលក់ដោយបង្ខំតាមការលក់ឡាយឡុងដោយស្រោមសំបុត្រ អាជ្ញាសាលាត្រូវប្រគល់នូវស្រោមសំបុត្រ និងលិខិតសំណើទិញទៅឱ្យអ្នកចូលរួមធ្វើសំណើទិញ ដើម្បីបញ្ជាក់អំពីចំនួនទឹកប្រាក់ដែលខ្លួនធ្វើសំណើ រួចដាក់ក្នុងស្រោមសំបុត្របិទជិត ដើម្បីប្រគល់ជូនអាជ្ញាសាលា។

-អាជ្ញាសាលាត្រូវបើកស្រោមសំបុត្របិទជិតនោះ រួចប្រកាសអំពីអ្នកធ្វើសំណើទិញ និងចំនួនទឹកប្រាក់ស្នើទិញ នៅចំពោះមុខអ្នកចូលរួមទាំងអស់។

-អាជ្ញាសាលាត្រូវកំណត់អ្នកស្នើសុំទិញក្នុងតម្លៃលក់អតិបរមា និងប្រកាសអំពីអ្នកដែលដេញថ្លៃបាន។

-អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុស្ដីពីការលក់ឡាយឡុងចំពោះចលនវត្ថុ ដោយតម្រូវឱ្យបញ្ជាក់នូវហេតុការណ៍ដែលបានកើតឡើង និងអ្នកដេញថ្លៃបាន។

-អាជ្ញាសាលាតម្រូវឱ្យអ្នកដេញថ្លៃបានបង់ប្រាក់បង្គ្រប់ថ្លៃលក់ភ្លាមៗ។

-អាជ្ញាសាលាត្រូវចាត់ចែងផ្ទេរកម្មសិទ្ធិ និងប្រគល់ចលនវត្ថុ នោះទៅឱ្យអ្នកទិញផងដែរ។

-ប្រាក់ដែលបានមកពីការលក់ដោយបង្ខំនេះ អាជ្ញាសាលាត្រូវចាត់ចែងរៀបចំនីតិវិធីចែកចំណែក។

### ៤. ការលក់ចលនវត្ថុរឹបអូសក្នុងពេលដែលការអនុវត្តកំពុងត្រូវបានផ្អាក

ជាគោលការណ៍ នៅពេលដែលការអនុវត្តដោយបង្ខំត្រូវបានផ្អាក ស្ថាប័នអនុវត្តមិនអាចចំណាត់ការនីតិវិធីអនុវត្តណាមួយឡើយ។ ដូចគ្នាដែរប្រសិនការអនុវត្តដោយបង្ខំចំពោះចលនវត្ថុត្រូវបានផ្អាក នោះអាជ្ញាសាលាដែលជាស្ថាប័នអនុវត្ត ក៏មិនអាចធ្វើចំណាត់ការបន្តនីតិវិធីទៀតឡើយ។

ប្រសិនបើការអនុវត្តដោយបង្ខំចំពោះចលនវត្ថុត្រូវបានផ្អាក ដោយសារការដាក់ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ ឬឯកសារដែលសរសេរថាម្ចាស់បំណុលទទួលសំណង បានយល់ព្រមពន្យាពេលដែលត្រូវសងនៅក្រោយពេលលិខិតអនុវត្តត្រូវបានបង្កើត ហើយប្រសិនមានការបារម្ភថា តម្លៃចលនវត្ថុដែលត្រូវបានរឹបអូសនឹងចុះថោកខ្លាំង សោហ៊ុយចំណាយសម្រាប់រក្សាទុកចលនវត្ថុដែលត្រូវបានរឹបអូសនឹងមានចំនួនច្រើនមិនសមរម្យ អាជ្ញាសាលាអាចលក់ចលនវត្ថុដែលត្រូវរឹបអូសនោះតាមវិធីលក់ចលនវត្ថុបាន[៩៨]។ មានន័យថា អាជ្ញាសាលាអាចលក់ចលនវត្ថុដែលត្រូវបានរឹបអូស នៅក្នុងអំឡុងពេលផ្អាកការអនុវត្តបាន លុះត្រាតែ៖

-ការផ្អាកការអនុវត្តនោះកើតឡើង ដោយសារតែមានការដាក់ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ ឬឯកសារដែលសរសេរថាម្ចាស់បំណុលទទួល

[៩៨] មាត្រា៣៩៧ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

សំណាង ឬបានយល់ព្រមពន្យាពេលដែលត្រូវសង នៅក្រោយពេលលិខិតអនុវត្តត្រូវបានបង្កើត។ ពោលគឺមិនមែនគ្រប់ការផ្អាកការអនុវត្តទាំងអស់សុទ្ធតែអាចឱ្យអាជ្ញាសាលាលក់ចលនវត្ថុដែលត្រូវបានរឹបអូសបានទេ។ មូលដ្ឋានដែលកំណត់បែបនេះដោយសារតែការផ្អាកអនុវត្តទាំងពីរខាងលើនេះ គឺមានអានុភាពផ្អាកតែមួយរយៈ និង មិនបង្ហាញអំពីលទ្ធភាពនៃការលុបចោលការអនុវត្តផងដែរ។

-មានការបារម្ភថាតម្លៃចលនវត្ថុដែលត្រូវរឹបអូសនោះនឹងធ្លាក់តម្លៃ ឬមានការចំណាយសោហ៊ុយគ្រប់គ្រងចលនវត្ថុដែលត្រូវរឹបអូសច្រើនមិនសមរម្យ។

នៅពេលអាជ្ញាសាលាលក់បានប្រាក់មកពីការលក់ហើយនោះ អាជ្ញាសាលាត្រូវផ្ញើប្រាក់នោះទុកនៅសាលាដំបូងដែលខ្លួនស្ថិតនៅ [99]។

### ៥. ការទទួលខុសត្រូវ និងសិទ្ធិអំណាចរបស់អាជ្ញាសាលាក្នុងពេលលក់

អាជ្ញាសាលាត្រូវទទួលខុសត្រូវនៅក្នុងការរៀបចំ និងការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់ធ្វើយ៉ាងណាឱ្យការលក់ឡាយឡុងចលនវត្ថុអាចប្រព្រឹត្តទៅបានត្រឹមត្រូវតាមនីតិវិធីច្បាប់។ ដើម្បីបញ្ចៀសនូវការរំខានផ្សេងៗ ដូចជា ការធ្វើឱ្យរំខានដល់អ្នកដទៃទៀតក្នុងពេលធ្វើសំណើទិញ បានឃុបឃិតដើម្បីបញ្ចុះតម្លៃលក់ដោយមិនត្រឹមត្រូវ ឬចំពោះជនដែលប្រើឱ្យធ្វើសកម្មភាពនោះ អាជ្ញាសាលាអាចកម្រិតមិនឱ្យជននោះចូលកន្លែងលក់ ឬអាចដេញជននោះចេញពីកន្លែងលក់ ឬអាចមិនឱ្យស្នើសុំទិញបាន [100]។

ក្នុងករណីដែលការលក់មិនអាចធ្វើទៅបាន បើទោះបីជាបានអនុវត្តការលក់ តាមវិធីសមរម្យក៏ដោយ ហើយប៉ាន់ប្រមាណឃើញថា ចលនវត្ថុដែលត្រូវបានរឹបអូសមិនអាចលក់បាននាពេលអនាគត អាជ្ញាសាលាអាចលុបចោលការរឹបអូសចលនវត្ថុនោះបាន[101] ។

## កថាភាគទី២ ៖ ការចែកចំណែក

ការចែកចំណែក គឺជាផ្នែកមួយនៅក្នុងនីតិវិធីមួយនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែលក្នុងនោះអាជ្ញាសាលាត្រូវយកប្រាក់ដែលបានពីការលក់ចលនវត្ថុ ឬប្រាក់ដែលបានមកពីការរឹបអូសក្នុងករណីរឹបអូសប្រាក់នោះសងទៅឱ្យម្ចាស់បំណុលដែលមានសិទ្ធិលើបំណុល ចំពោះកូនបំណុលនៃការអនុវត្ត។

### ១. ការទាមទារឱ្យចែកចំណែក

#### ១.១. ម្ចាស់បំណុលដែលមានសិទ្ធិទាមទារឱ្យចែកចំណែក

ម្ចាស់បំណុល ដែលមានសិទ្ធិទាមទារឲ្យអាជ្ញាសាលាចែកចំណែក នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុបាន រួមមាន៖

[99] មាត្រា៣៩៧ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[100] មាត្រា៣៩៦ ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[101] មាត្រា៣៩៣ ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

- **ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក តាមរយៈការរួមបញ្ចូលរឿងក្តី៖** ជាទូទៅមិនមែនគ្រប់ម្ចាស់បំណុលដែលមានសិទ្ធិលើបំណុល លើកូនបំណុលនៃការអនុវត្ត សុទ្ធតែអាចសុំរួមបញ្ចូលរឿងក្តីជាមួយនឹងម្ចាស់បំណុលនៃការអនុវត្ត ដើម្បីទទួលបានចំណែកនោះទេ។ ម្ចាស់បំណុលដែលអាចសុំរួមបញ្ចូលរឿងក្តីបាននោះ គឺមានតែម្ចាស់បំណុលដែលមានលិខិតអនុវត្តតាម (មាត្រា៣៥០ កថាខណ្ឌទី២) ហើយបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុលើកូនបំណុលនៃការអនុវត្តនៅកន្លែងដដែល ឬម្ចាស់បំណុលដែលអនុវត្តការរឹបអូសជាបណ្តោះអាសន្នរួចហើយតែប៉ុណ្ណោះ។ មានន័យថាទោះបីជាម្ចាស់បំណុលដែលមានលិខិតអនុវត្តហើយមិនទាន់បានអនុវត្តការរឹបអូសជាបណ្តោះអាសន្ននៅឡើយទេនោះ មិនអាចទាមទារឱ្យអាជ្ញាសាលាចែកចំណែកឱ្យមកខ្លួនបានទេ [102]។
- **ម្ចាស់បំណុលដែលមានឯកសិទ្ធិ ឬសិទ្ធិលើការបញ្ចាំ៖** អាចទាមទារឱ្យអាជ្ញាសាលាធ្វើការចែកចំណែកឱ្យមកខ្លួនបានដែរ។

**១.២. វិធីទាមទារឱ្យចែកចំណែក**

ការទាមទាមឱ្យចែកចំណែកមានភាពខុសប្លែកគ្នាអាស្រ័យទៅតាមប្រភេទ នៃម្ចាស់បំណុលដែលមានសិទ្ធិទាមទារឱ្យចែកចំណែកដែលក្នុងនោះរួមមាន៖

- **ចំពោះម្ចាស់បំណុលដែលទាមទារឱ្យចែកចំណែកតាមរយៈការរួមបញ្ចូលរឿងក្តី៖** ដើម្បីអាចក្លាយជាម្ចាស់បំណុលដែលមានសិទ្ធិទទួលចំណែកបាន ម្ចាស់បំណុលប្រភេទនេះ មិនអាចដាក់ពាក្យសុំទាមទារឱ្យចែកចំណែកបានទេ គឺមានតែវិធីដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំលើចលនវត្ថុ ឬដាក់ពាក្យសុំឱ្យអនុវត្តរឹបអូសជាបណ្តោះអាសន្ន ដោយសំអាងលើលិខិតអនុវត្តរបស់ខ្លួន។ ករណីនេះនៅពេលដែលអាជ្ញាសាលាបានទទួលពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ឬពាក្យសុំឱ្យអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ លើកូនបំណុលនៅទីតាំងដដែល ហើយនោះជាដំបូងអាជ្ញាសាលាត្រូវរឹបអូសចលនវត្ថុរបស់កូនបំណុលដែលនៅសេសសល់ជាមុនសិន តែបើគ្មានសេសសល់ទេ អាជ្ញាសាលាត្រូវបញ្ជាក់អំពីហេតុការណ៍នេះ ហើយត្រូវរួមបញ្ចូលរឿងក្តីអនុវត្តចំពោះចលនវត្ថុថ្មី ការរឹបអូសចលនវត្ថុថ្មីជាមួយនឹងរឿងក្តីអនុវត្តដោយបង្ខំចំពោះចលនវត្ថុមុន ដែលមានអានុភាពជាការចែកចំណែក[103] ការរួមបញ្ចូលរឿងក្តី ក៏អាចត្រូវធ្វើឡើងតាមរយៈពាក្យសុំរបស់ម្ចាស់បំណុលនៅក្នុងសំណុំរឿងក្តីអនុវត្តថ្មី ក៏អានុភាពនៃការចែកចំណែកកើតមានដែរ [104]។

[102] មាត្រា៣៨៨, មាត្រា៣៩៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
[103] មាត្រា៣៨៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
[104] មាត្រា៣៨៨ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

- **ចំពោះម្ចាស់បំណុលដែលមានឯកសិទ្ធិ ឬសិទ្ធិលើការបញ្ចាំ៖** ដើម្បីអាចក្លាយខ្លួនជាម្ចាស់បំណុលដែលមានសិទ្ធិទទួលចំណែក ដែលបានមកពីការលក់ចលនវត្ថុបាន ម្ចាស់បំណុលដែលមានឯកសិទ្ធិ ឬសិទ្ធិលើការបញ្ចាំត្រូវដាក់ពាក្យសុំទាមទារឱ្យចែកចំណែក (មិនដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទេ) ប៉ុន្តែម្ចាស់បំណុលត្រូវភ្ជាប់មកជាមួយឯកសារដែលមានបញ្ជាក់អំពីឯកសិទ្ធិ ឬសិទ្ធិលើការបញ្ចាំនោះ [105]។

**១.៣. អន្តិភាពក្នុងការទាមទារឱ្យចែកចំណែក**

ទោះបីជាខ្លួនជាម្ចាស់បំណុល ដែលមានសិទ្ធិទាមទារឱ្យចែកចំណែកក៏ពិតមែន ប៉ុន្តែប្រសិនបើម្ចាស់បំណុលមិនបានសុំទាមទារឱ្យចែកចំណែកក្នុងអំឡុង ពេលដែលច្បាប់បានកំណត់ទេ នោះក៏ម្ចាស់បំណុលនោះនៅតែមិនអាចក្លាយជាម្ចាស់បំណុលដែលមានសិទ្ធិទទួលចំណែកបានដដែល។

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីពុំបានចែងអំពីអំឡុងពេលនៃការទាមទារចែកចំណែកឱ្យបានច្បាស់លាស់នោះទេ ហើយក៏ពុំកំណត់ឱ្យអាជ្ញាសាលាកំណត់កាលបរិច្ឆេទចុងក្រោយដែរ។ ប៉ុន្តែបើយើងពិនិត្យមើលមាត្រា ៣៩៨ នោះវិញ យើងអាចសង្កេតបានថា អំឡុងពេលសម្រាប់ទាមទារឱ្យចែកចំណែក គឺកំណត់ត្រឹមពេលដែលបានទទួលការប្រគល់ប្រាក់ចំពោះប្រាក់ដែលបានមកពីការលក់ ឬពេលដែល បានរឹបអូសប្រាក់ចំពោះប្រាក់ដែលត្រូវបានរឹបអូសតែប៉ុណ្ណោះ។ មានន័យថា ម្ចាស់បំណុលអាចទាមទារឱ្យចែកចំណែកបាន គឺគិតចាប់ពីការចាប់ផ្តើមការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ រហូតដល់ពេលដែលអាជ្ញាសាលាបានទទួលប្រាក់។

ប៉ុន្តែអាជ្ញាសាលាអាចចែកចំណែកឱ្យម្ចាស់បំណុលដែលបានសុំឱ្យចែកចំណែក នៅក្រោយពេលអ្នកទិញបានបង់ថ្លៃលក់ហើយ បានតែក្នុងករណីដែលមានឯកសារដូចខាងក្រោមត្រូវបានដាក់[106]៖

-ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថាលុបចោលលិខិតអនុវត្ត ក្រៅពីលិខិតយថាភូតដែលកំណត់ក្នុង (ចំណុច(ច) កថាខណ្ឌទី២ នៃមាត្រា៣៥០) ឬឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថា លុបចោលការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។

-ឯកសារចម្លងថាយថាភូតនៃសេចក្តីសម្រេចដែលបានកំណតថា មិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ។

-អនុសារសាលក្រមស្ថាពរ ឬអនុសារសាដីកាស្ថាពរដែលប្រកាសថាការផ្សះផ្សារ ឬការទទួលស្គាល់ដែលទាក់ទងនឹងលិខិតអនុវត្តគ្មានអានុភាព។

-ឯកសារចម្លងយថាភូតនៃកំណត់ហេតុ ឬឯកសារផ្សេងទៀត ដែលក្រឡាបញ្ជីបានធ្វើដែលបញ្ជាក់ថាលិខិតអនុវត្តដែលបានកំណត់ពី (ចំណុច(ខ) រហូតដល់ចំណុច(ង) កថាខណ្ឌទី២ នៃមាត្រា៣៥០) បាត់បង់អានុភាពដោយសារការដកពាក្យបណ្តឹង មូលហេតុផ្សេងទៀត។

[105] មាត្រា៣៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[106] មាត្រា៣៩៩ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

-ឯកសារចម្លងយថាភូតនៃកំណត់អំពីការផ្សះផ្សាតាមនីតិវិធី នៃការសម្រេចសេចក្ដីដែលបានកំណត់ថាមិនអនុវត្តដោយបង្ខំ ឬដកពាក្យសុំឱ្យអនុវត្តដោយបង្ខំនោះវិញ។

-ឯកសារដែលបញ្ជាក់អំពីការដាក់ប្រាតិភោគ ដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំ។

-ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចដែលកំណត់បង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំ និងការលុបចោលការចាត់ចែងការអនុវត្ត។

-ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ។

-ឯកសារដែលសរសេរថា ម្ចាស់បំណុលទទួលសំណង បានយល់ព្រមពន្យាពេលដែលត្រូវសងនៅក្រោយពេលលិខិតអនុវត្តត្រូវបានបង្កើត។

**២. ការអនុវត្តការចែកចំណែក**

**២.១. ករណីដែលមានម្ចាស់បំណុលតែម្នាក់**

អាជ្ញាសាលាត្រូវយកប្រាក់ដែលបានមកពីការលក់ចលនវត្ថុរឹបអូស ឬប្រាក់ដែលបានមកពីការរឹបអូសប្រគល់ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ព្រមទាំងសោហ៊ុយសម្រាប់ការអនុវត្ត ហើយបើនៅមានប្រាក់នៅសល់អាជ្ញាសាលាត្រូវប្រគល់ទៅឱ្យកូនបំណុលនៃការអនុវត្តវិញ[107]។

**២.២. ករណីដែលមានម្ចាស់បំណុលច្រើននាក់**

**-ករណីដែលប្រាក់ដែលបានមកពីលក់ ឬ ប្រាក់ដែលបានមកពីការរឹបអូសអាចសងបំណុលរបស់ម្ចាស់បំណុលនីមួយៗ និងសោហ៊ុយសម្រាប់ការអនុវត្តបានទាំងអស់៖** អាជ្ញាសាលាត្រូវចែកចំណែកចំពោះម្ចាស់បំណុល ហើយត្រូវប្រគល់ប្រាក់ដែលនៅសល់ទៅឱ្យកូនបំណុលនៃការអនុវត្តវិញ[108]។

**-ករណីប្រាក់មិនគ្រប់ចំនួនសម្រាប់ចែកចំណែក ឬផ្សេងទៀត៖** អាជ្ញាសាលាមិនអាចចែកចំណែកឱ្យទៅម្ចាស់បំណុលទាំងអស់បានភ្លាមៗទេ ដែលករណីនេះអាជ្ញាសាលាត្រូវកំណត់ថ្ងៃក្នុងអំឡុងពេល ០២សប្ដាហ៍ ជាថ្ងៃត្រូវពិភាក្សាគ្នា អំពីការចែកចំណែកនៃប្រាក់ដែលបានមកពីការលក់ ឬប្រាក់ដែលបានមកពីការរឹបអូស ហើយត្រូវជូនដំណឹងពីពេលវេលា និង ទីកន្លែងទៅម្ចាស់បំណុលនីមួយៗ[109]។ បើម្ចាស់បំណុលនីមួយៗបានពិភាក្សាគ្នាដាច់ស្រេចហើយនោះ អាជ្ញាសាលាត្រូវចែកចំណែកតាមការពិភាក្សាគ្នារវាងម្ចាស់បំណុលទាំងនោះ[110]។ ផ្ទុយទៅ

[107] មាត្រា៣៩៩ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[108] មាត្រា៣៩៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[109] មាត្រា៣៩៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[110] មាត្រា៣៩៩ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

វិញបើម្ចាស់បំណុលមិនបានពិភាក្សាគ្នាឱ្យដាច់ស្រេចទេនោះ អាជ្ញាសាលាត្រូវរាយការណ៍អំពីហេតុការណ៍នេះទៅសាលាដំបូងដែលខ្លួនស្ថិតនៅ ដើម្បីធ្វើជាអ្នកចែកចំណែកបន្ត[111]។

**២.៣. វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក**[112]

ម្ចាស់បំណុលដែលត្រូវទទួលចំណែក គឺជាបុគ្គលដែលបានកំណត់ក្នុងចំណុចនីមួយៗដូចខាងក្រោម៖

**-ម្ចាស់បំណុលនៃការអនុវត្ត៖** សំដៅដល់ម្ចាស់បំណុលដែលបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ។

**-ម្ចាស់បំណុលដែលទាមទារឱ្យចែកចំណែក រហូតដល់ពេលដែលអាជ្ញាសាលាបានទទួលការប្រគល់ប្រាក់ចំពោះប្រាក់ដែលបានមកពីការលក់៖** សំដៅដល់ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែកតាមរយៈការរួមបញ្ចូលរឿងក្តី និងទាមទារឱ្យចែកចំណែករបស់ម្ចាស់បំណុលដែលមានឯកសិទ្ធិ ឬសិទ្ធិលើការបញ្ចាំ។

**-ម្ចាស់បំណុលដែលទាមទារឱ្យចែកចំណែករហូតដល់ពេលដែលរឹបអូសប្រាក់ ចំពោះប្រាក់ដែលបានរឹបអូស៖** សំដៅដល់ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក តាមរយៈការរួមបញ្ចូលរឿង និងទាមទារឱ្យចែកចំណែករបស់ម្ចាស់បំណុលដែលមានឯកសិទ្ធិ ឬសិទ្ធិលើការបញ្ចាំ។

**៣. អានុភាពនៃការចែកចំណែក**

នីតិវិធីនៃការចែកចំណែកបានកើតឡើង នឹងមានអានុភាពមួយចំនួនដូចខាងក្រោម៖

**៣.១. ការចាត់ទុកថាដល់ពេលកំណត់ត្រូវសង**

ចំពោះសិទ្ធិលើបំណុលដែលកំណត់ពេលពិតប្រាកដពុំទាន់មកដល់ ត្រូវចាត់ទុកថាកំណត់សងនោះបានចូលមកដល់ហើយ[113]។ មានន័យថាទោះបីជាម្ចាស់បំណុលបានទាមទារឱ្យចែកចំណែកដោយផ្អែកលើសិទ្ធិលើបំណុលដែលមិនទាន់ដល់ពេលកំណត់ត្រូវសងក៏ដោយ ក៏អានុភាពនៃការចែកចំណែក នាំឱ្យទទួលស្គាល់ថាសិទ្ធិលើបំណុលនោះបានដល់ពេលកំណត់ត្រូវសងហើយ។ ករណីនេះម្ចាស់បំណុល អាចទទួលយកចំណែកបានហើយ។

**ឧទាហរណ៍៖** ម្ចាស់បំណុលដែលមានសិទ្ធិលើការបញ្ចាំលើចលនវត្ថុ និងមានសិទ្ធិលើបំណុលចំនួន ១.៥០០ (មួយពាន់ប្រាំរយដុល្លារអាមេរិក) ចំពោះកូនបំណុលនៃការអនុវត្ត ហើយពេលកំណត់ដែលត្រូវសងនៅឆ្នាំ២០១៥ បានទាមទារឱ្យអាជ្ញាសាលាចែកចំណែកដែលនឹងត្រូវចែកចំណែកនៅខែមិថុនា ឆ្នាំ២០១៤។ ពេលដែលចូលមកដល់នីតិវិធីចែកចំណែក ពេលកំណត់ដែលត្រូវសងនៅឆ្នាំ២០១៥ ត្រូវសន្មត់ថាបានមកហើយ។ ដូច្នេះអាជ្ញាសាលាអាចចែកចំណែកឱ្យម្ចាស់បំណុល ដែលមានសិទ្ធិលើការបញ្ចាំនោះបាន។

[111] មាត្រា៤០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[112] មាត្រា៣៩៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[113] មាត្រា៣៩៩ កថាខណ្ឌទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

### ៣.២. ការផ្ញើប្រាក់ចំណែករបស់ម្ចាស់បំណុលនៅតុលាការ

បន្ទាប់ពីការចែកចំណែកបានបញ្ចប់ហើយ ប្រសិនបើមានហេតុការណ៍ដូចខាងក្រោម អាជ្ញាសាលាត្រូវផ្ញើប្រាក់ដែលស្មើនឹងចំណែករបស់ម្ចាស់បំណុលដែលត្រូវទទួល ទៅសាលាដំបូងដែលខ្លួនស្ថិតនៅ ហើយត្រូវរាយការណ៍ទៅសាលាដំបូង អំពីហេតុការណ៍នោះ[114]៖

-បើសិទ្ធិលើបំណុលនោះ មានភ្ជាប់នូវល័ក្ខខ័ណ្ឌបង្អង់ ឬកំណត់ពេលមិនពិតប្រាកដ។

-បើសិទ្ធិលើបំណុលនោះជាសិទ្ធិលើបំណុលនៃការរឹបអូសជាបណ្ដោះអាសន្ន។

-បើមានការដាក់ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេច ដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ។

-បើមានការដាក់ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេច ដែលហាមឃាត់ការអនុវត្តមួយរយៈនៃឯកសិទ្ធិ ឬសិទ្ធិលើការបញ្ចាំ ដែលទាក់ទងនឹងសិទ្ធិលើបំណុលនោះ។

-បើម្ចាស់បំណុលមិនបានបង្ហាញខ្លួនដើម្បីទទួលចំណែកនៅសាលាដំបូងដែលខ្លួនស្ថិតនៅកាលបរិច្ឆេទនៃការចែកចំណែក។

[114] មាត្រា៤០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវ លើទ្រឹស្តីគតិយុត្តនូវប្រធានបទ ស្តីពី "**នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ**" យើងអាចសន្និដ្ឋានបានថា នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺពិតជាមានសារៈសំខាន់ណាស់ចំពោះភាគីដែលជាម្ចាស់បំណុលនៃការអនុវត្ត ក្នុងការសម្រេចនូវសិទ្ធិទាមទារដែលកំណត់នៅក្នុងលិខិតអនុវត្ត ដោយការទាមទារនេះត្រូវការប្រើប្រាស់កម្លាំងអំណាចរបស់រដ្ឋតាមរយៈតុលាការអនុវត្ត និងអាជ្ញាសាលា ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចក៏ដូចជាកងកម្លាំងផ្សេងទៀតផងដែរ ។ តាមរយៈប្រធានបទនេះ យើងអាចស្រម៉ៃបានថា ប្រសិនបើគ្មាននីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុទេនោះ កូនបំណុលនៃការអនុវត្តអាចនឹងចាត់ចែងអនុវត្តទៅលើចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយខ្លួនឯងតាមវិធីណាមួយ ដែលសកម្មភាពនេះអាចនឹងមានការទទួលរងនូវផលប៉ះពាល់អំពីសិទ្ធិ ក៏ដូចជាផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្តយ៉ាងធ្ងន់ធ្ងរថែមទៀតផង។ ចំពោះកត្តានេះទៀតសោត ក៏អាចជះឥទ្ធិពលមិនល្អដែលឈានដល់ការបង្កនូវភាពចលាចល អសន្តិសុខក្នុងសង្គមផងដែរ។ នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុគឺត្រូវកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ផ្សេងៗទៀតដែលបានណែនាំដោយក្រសួងយុត្តិធម៌, ក្រសួងសាធារណការ និងដឹកជញ្ជូនដើម្បីជាមូលដ្ឋានក្នុងការអនុវត្តលំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុនេះទាំងមូល។

នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ មិនមែនជានីតិវិធីដែលបន្តពីតុលាការនៃបណ្តឹងអង្គសេចក្តីនោះទេ ដោយហេតុថា តុលាការនៃបណ្តឹងអង្គសេចក្តីគ្រាន់តែជាតុលាការដែលសម្រេចនូវអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិទាមទារតែប៉ុណ្ណោះ។ ផ្ទុយមកវិញនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺជានីតិវិធីឯករាជ្យមួយដែលបង្កើតឡើងដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្តដូចមានកំណត់នៅក្នុងលិខិតអនុវត្ត តាមរយៈម្ចាស់បំណុលនៃការអនុវត្តបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដោយផ្អែកតាមលិខិតអនុវត្តដែលបានបញ្ជាក់ជាស្ថាពរដែលមានអានុភាពអនុវត្តក្នុងគោលបំណងរឹបអូសនូវចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត ដើម្បីមកធ្វើការលក់ និងចែកចំណែក ក្នុងការសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត ។

ជារួមមកវិញ យើងអាចនិយាយបានថា នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺជានីតិវិធីមួយបែប ដែលមានលក្ខណៈងាយស្រួល ដោយហេតុថានីតិវិធីនេះ អាចត្រូវបានធ្វើចំណាត់ការបានយ៉ាងឆាប់រហ័ស និងចំណាយសោហ៊ុយនៃការអនុវត្តក្នុងកម្រិតតិច ដំណើរការនៃនីតិវិធីនេះ ត្រូវអនុវត្តតាមគោលការណ៍ស្វ័យភាពខាងឆន្ទៈ ហើយជាពិសេសទៀតនោះ ផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្តត្រូវបានការពារក្នុងកម្រិតខ្ពស់ផងដែរ ជាក់ស្តែងទោះបីជា នីតិវិធីនៃការអនុវត្តដោយបង្ខំមានលក្ខណៈងាយស្រួល និងឆាប់រហ័សក្នុងទិដ្ឋភាពច្បាប់ក៏ពិតមែន ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែងនៃនីតិវិធីនេះក៏ជួបប្រទះនូវការលំបាក និងមានភាពស្មុគស្មាញមួយចំនួនផងដែរ ដូចជាការកេណ្ឌកងកម្លាំងនគរ-បាលចូលរួមនីតិវិធីក្នុងការរឹបអូសចលនវត្ថុ ការស្នើសុំជំនួយពីអ្នកវាយតម្លៃ ការថែរក្សាចលនវត្ថុដែលត្រូវបានរឹបអូស ការផ្ទេរកម្មសិទ្ធិលើចលនវត្ថុ ជាអាទ៍។ ក្នុងករណីទាំងអស់នេះ គឺតម្រូវឱ្យមានការទាមទារពីអាជ្ញាសាលាដែលទទួលបន្ទុកក្នុងសំណុំរឿងត្រូវមានភាពបត់បែន និងមានគោលការណ៍ច្បាស់លាស់អំពីគោលគំនិតនៃការអនុវត្តលើនីតិវិធីនសការអនុវត្តដោយបង្ខំចំពោះចលនវត្ថុនេះ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការបកស្រាយ និងសិក្សាស្រាវជ្រាវយ៉ាងលម្អិតចំពោះ "**នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ**" រួចមក ក្រុមរបស់យើងខ្ញុំបានយល់ឃើញថា ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដែលធ្វើឡើងដោយស្ថាប័នអនុវត្ត ពិតជាមានសារៈប្រយោជន៍យ៉ាងខ្លាំង ដែលជាមធ្យោបាយសម្រាប់ឱ្យម្ចាស់បំណុលនៃការអនុវត្ត អាចសម្រេចនូវសិទ្ធិរបស់ខ្លួនតាមរយៈសិទ្ធិនៃការពឹងពាក់អាជ្ញាសាលាដែលជាស្ថាប័នអនុវត្ត។ ទន្ទឹមនឹងនេះបើទោះបីជាម្ចាស់បំណុលនៃការអនុវត្ត អាចសម្រេចនូវសិទ្ធិទាមទាររបស់ខ្លួន តាមរយៈនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុក៏ដោយ ក៏ស្ថាប័នអនុវត្តនៅតែអនុវត្តនីតិវិធីនៃការអនុវត្តដោយបង្ខំដោយមានភាពហ្មត់ចត់ និងត្រឹមត្រូវស្របតាមគោលការណ៍យុត្តិធម៌ និងឆាប់រហ័ស។ ដូច្នេះ ដើម្បីឆ្លើយតបជាមួយនឹងបញ្ហាដែលកើតមានជុំវិញនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ អាចប្រព្រឹត្តិទៅបានយ៉ាងរលូន នឹងឆាប់រហ័ស ទើបក្រុមយើងខ្ញុំសូមលើកយកនូវមតិ គំនិតយោបល់ និងដំណោះស្រាយមួយចំនួន ដូចខាងក្រោម៖

**១. ឆ្លើយតបនឹងការស្រាវជ្រាវ និងណែនាំកូនបំណុលនៃការអនុវត្ត ឱ្យអនុវត្តដោយស្ម័គ្រចិត្ត**

- ចំពោះនីតិវិធិនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ក៏មានដំណាក់កាលនៃការណែនាំកូនបំណុលនៃការអនុវត្ត បានអនុវត្តដោយស្ម័គ្រចិត្តដែរ។ ក្នុងករណីនេះ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្តមានបំណងចរចាដោយស្ម័គ្រចិត្ត ស្ថាប័នអនុវត្តត្រូវអនុញ្ញាតឱ្យអនុវត្តដោយស្ម័គ្រចិត្ត ព្រោះវានាំឱ្យចំណេញពេលវេលា និងថវិកា។
- យោងតាមប្រសាសន៍របស់ **ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** បានថ្លែងសុន្ទរកថានៅក្នុងពិធីសម្ពោធសាលាឧទ្ធរណ៍ក្រុងព្រះសីហនុ និងពិធីប្រកាសចូលកាន់តំណែងប្រធានសាលាឧទ្ធរណ៍ក្រុងព្រះសីហនុ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក្រុងព្រះសីហនុ និងជាអគ្គលេខាធិការ នៃសាលាឧទ្ធរណ៍ខេត្តព្រះសីហនុ នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២០ បានមានប្រសាសន៍ថា "***ការសម្របសម្រួលដ៏អាក្រក់មួយ ក៏ប្រសើរជាងដំណើរការរឿងក្តីមួយដ៏ល្អដែរ***"។ ដោយសារឱ្យតែឆ្លងកាត់ការកាត់ក្តីមួយ គឺតែងតែមានអ្នកឈ្នះ និងអ្នកចាញ់ បើមានអ្នកឈ្នះ និងអ្នកចាញ់ ភាគីទាំងពីរតែងតែជាសត្រូវនឹងគ្នា ប៉ុន្តែផ្ទុយទៅវិញ បើមានការខិតខំសម្របសម្រួលរកដំណោះស្រាយ "***ឈ្នះឈ្នះ***" ទាំងអស់គ្នា បើមិនបានទុកជាមិត្តភក្តិចិត្តដិត ក៏បានទុកមុខញញឹមដាក់គ្នាខ្លះដែរ ចឹងហើយបានជាសង្គមមួយដែលធានាបានសុខុដុមរមនា ធានាបាន ស្ថិរភាពក្នុងសង្គមដែលគ្មានទំនាស់ជាបៀបសត្រូវស៊ីពូជនោះ គឺគេចង់លើកកម្ពស់នៅការដោះស្រាយវិធីនេះ។

**២. ឆ្លើយតបនឹងបញ្ហាអានុភាពនៃការរឹបអូស**

- ចំពោះអានុភាពនៃការរឹបអូសនឹងកើតឡើង នៅពេលដែលមានការចាប់ផ្តើមការអនុវត្តដោយអាជ្ញាសាលាចំពោះ ***ការរឹបអូសចលនវត្ថុដោយអាជ្ញាសាលា*** ត្រូវផ្អែកលើការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ តាមរយៈម្ចាស់បំណុលនៃការអនុវត្ត។ ជាមួយគ្នានេះដែរ មានមតិមួយចំនួនតែងតែងមានការភាន់ច្រឡំថា ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ នឹងត្រូវចាប់ផ្តើមនៅពេលដែលម្ចាស់បំណុលនៃការអនុវត្ត បានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំមកអាជ្ញាសាលា។ ក្នុងន័យនេះ បើទោះបីជាម្ចាស់បំណុលនៃការអនុវត្តបានដាក់ពាក្យសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុ មកអាជ្ញាសាលាក៏ដោយក៏មិនទាន់ចាត់ទុកថា នីតិវិធីនៃការអនុវត្តដោយបង្ខំត្រូវបានចាប់ផ្តើមដែរ លុះត្រាតែមានការរឹបអូសចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត ទើបចាត់ទុកថាជាការអនុវត្តដោយបង្ខំចំពោះចលនវត្ថុបាន។

**៤. ឆ្លើយតបនឹងបញ្ហាការជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឱ្យវាយតម្លៃ ដោយអាជ្ញាសាលាអនុវត្ត**

កូនបំណុលនៃការអនុវត្តតែងតែមិនទទួលយកការជ្រើសតាំងអ្នកវាយតម្លៃ និងតម្លៃចលនវត្ថុ ដែលបានវាយតម្លៃ ដោយលើកយកមូលហេតុការវាយតម្លៃមានតម្លៃទាបពេក ហើយមិនមានការវាយតម្លៃពីអ្នកជំនាញត្រឹមត្រូវ ដោយសារច្បាប់មិនបានកំណត់លក្ខណៈសម្បត្តិអ្នកវាយតម្លៃនោះទេ។ នៅក្នុងនីតិវិធីលក់ឡាយឡុងចលនវត្ថុ ដែលត្រូវបានរឹបអូស គ្រាន់តែកំណត់ថាប្រសិនបើចលនវត្ថុមានតម្លៃខ្ពស់ អាជ្ញាសាលាត្រូវជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឱ្យវាយតម្លៃលើចលនវត្ថុនោះ ប៉ុន្តែនៅក្នុងបញ្ញត្តិនេះក៏មិនមានកំណត់ថា តើចលនវត្ថុនេះមានតម្លៃប៉ុន្មាននោះទេ ដែលចាំបាច់ត្រូវការអ្នកវាយតម្លៃ ។ ក្នុងករណីនេះ តុលាការ ឬក្រសួងយុត្តិធម៌ គប្បីរៀបចំឱ្យមានបញ្ជីឈ្មោះអ្នកវាយតម្លៃជាអ្នកជំនាញ ដែលមាននីតិសម្បទាគ្រប់គ្រាន់ដែលទទួល ស្គាល់ដោយរាជរដ្ឋា ភិបាលជាមុន ហើយជ្រើសតាំងអ្នកវាយតម្លៃពីបញ្ជីឈ្មោះទាំងនោះ ពីព្រោះ វាមានភាពងាយស្រួលហើយចំណាយពេលតិចសម្រាប់តុលាការ។

# បញ្ជីឯកសារយោង

# បញ្ជីឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

-ព្រះរាជក្រមលេខៈ នស/រកម០៧០៦/០២១, ក្រមនីតិវិធីរដ្ឋប្បវេណី, ប្រកាសឱ្យប្រើ៖ ០៦ កក្កដា ២០០៦ និងអនុវត្តទូទាំងប្រទេស៖ ២៧ កក្កដា ២០០៧ ។

-ព្រះរាជក្រមលេខៈ នស/រកម/១២០៧/០៣០, ក្រមរដ្ឋប្បវេណី, ប្រកាសឱ្យប្រើ៖ ០៨ ធ្នូ ២០០៧ និងអនុវត្តទូទាំងប្រទេស៖ ២១ ធ្នូ ២០១១ ។

-អនុក្រឹត្យលេខ៖ ៧៧ អនក្រ.បក, ២៨ វិច្ឆិកា ២០០៣, ស្តីពីការចេញផ្លាកលេខសម្គាល់យានជំនិះ ។

-ប្រកាសលេខ៖ ៣០ កយ.ប្រក របស់ក្រសួងយុត្តធម៌, ១៩ កក្កដា ២០០៧, ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ។

-ប្រកាសលេខៈ ០៦២ កយ.ប្រក របស់ក្រសួងយុត្តធម៌, ៣០ មករា ២០១៩, ស្តីពីបែបបទនៃការបំពេញមុខនាទីរបស់អាជ្ញាសាលានៃក្រសួងយុត្តិធម៌ ។

-សារាចរលេខៈ ០០១ សក.សរ, ១៤ មករា ២០០៤, ក្រសួងសារធារណការ និងដឹកជញ្ជូន, ស្តីពី ការអនុវត្តន៍អនុក្រឹត្យលេខ៖ ៧៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជា ។

## ២. ឯកសារយោងផ្សេងៗទៀត

-សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៧, រៀបចំដោយក្រុមការងារជប៉ុន ទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មាការទទួលបន្ទុកការពារសេចក្តីព្រាង ក្រមនីតិវិធីរដ្ឋ-ប្បវេណី, ក្រសួងយុត្តធម៌ ។

-សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ២៖ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ ២០០៩, រៀបចំ ដោយក្រុមការងារជប៉ុន ទទួល បន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មាការទទួលបន្ទុក ការពារសេចក្តីព្រាង ក្រមនីតិវិធីរដ្ឋប្បវេណី, ក្រសួងយុត្តធម៌ ។

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី០១

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងរដ្ឋប្បវេណីលេខ៖ ១០២
ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៨
សាលក្រមលេខ៖ ៩៧ “ក”
ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០១៥ លើសំណុំរឿងរដ្ឋប្បវេណីលេខ ១០២ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដោយមានសមាសភាពដូចតទៅ៖

ចៅក្រមជំនុំជម្រះ

លោកស្រី **មាស និមល** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

លោកស្រី **នី សោភា** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ លើសំណុំរឿងរដ្ឋប្បវេណីរវាង៖

-ដើមចោទ ឈ្មោះ **ចាន់ រក្សា** ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មានលំនៅឋានផ្ទះលេខ ២០ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

-ចុងចម្លើយ ឈ្មោះ **ពុំ មេសា** ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មានលំនៅឋានផ្ទះលេខ ២១ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**អង្គហេតុ និង ចំណុចវិវាទ**

**១.- ការទាមទាររបស់ដើមចោទ៖**

ដើមចោទឈ្មោះ **ចាន់ រក្សា** ប្ដឹងសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម៖

- បង្គាប់ឲ្យចុងចម្លើយឈ្មោះ ពុំ មេសា សងប្រាក់ដើមចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក មកឲ្យដើមចោទឈ្មោះ ចាន់ រក្សា។
- បង្គាប់ឲ្យចុងចម្លើយឈ្មោះ ពុំ មេសា សងសំណងការខូចខាតចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក មកឲ្យដើមចោទឈ្មោះ ចាន់ រក្សា។

**២.- ការពន្យល់ត្រួសៗនៃរឿងក្តី៖**

កាលពីថ្ងៃ០១ ខែមីនា ឆ្នាំ២០១៤ ដើមចោទឈ្មោះ **ចាន់ រក្សា** បានឲ្យប្រាក់ទៅចុងចម្លើយឈ្មោះ **ពុំ មេសា** ខ្ចីចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក ដោយមិនគិតអំពីការប្រាក់អ្វីឡើយ ហើយចុងចម្លើយសន្យាថានឹងសងប្រាក់ទៅឲ្យដើមចោទគ្រប់ចំនួន នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៤ ប៉ុន្តែលុះដល់កាលកំណត់ដែលត្រូវសង ចុងចម្លើយមិនបានសងប្រាក់ទៅដើមចោទអ្វីឡើយ។

**៣.- ចំណុចវិវាទ**

តើចុងចម្លើយបានអនុវត្តកាតព្វកិច្ចសងប្រាក់ទៅឲ្យដើមចោទដែរឬទេ?

- បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៨ របស់ឈ្មោះ **ចាន់ រក្សា។**
- បានឃើញ កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០១ខែមីនា ឆ្នាំ២០១៤ រវាងឈ្មោះ **ចាន់ រក្សា និងឈ្មោះ ពុំ មេសា។**
- បានឃើញ លិខិតប្រគល់ទទួលប្រាក់ ចុះថ្ងៃទី ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៤ រវាងឈ្មោះ **ចាន់ រក្សា និងឈ្មោះ ពុំ មេសា។**
- បានឃើញ លិខិតជូនដំណឹង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៤ របស់ឈ្មោះ **ចាន់ រក្សា។**
- បានឃើញ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៧ របស់ឈ្មោះ ចាន់ រក្សា។
- បានឃើញ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៧ របស់ឈ្មោះ **ពុំ មេសា។**
- បានឃើញ កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុ នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨

**អំពីការអះអាងរបស់គូភាគី**

ដើមចោទឈ្មោះ **ចាន់ រក្សា** បានធ្វើសេចក្តីថ្លែងការណ៍ថា មូលហេតុដែលខ្លួនបានប្តឹងឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារថា (១) បង្គាប់ឲ្យចុងចម្លើយឈ្មោះ ពុំ មេសា សង

ប្រាក់ដើមចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក មកឲ្យដើមចោទឈ្មោះ ចាន់ រក្សា និង (២) បង្គាប់ឲ្យចុងចម្លើយឈ្មោះ ពុំ មេសា សងសំណងការខូចខាតចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក មកឲ្យដើមចោទឈ្មោះ ចាន់ រក្សា។ ដោយហេតុថា កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៤ ខ្លួនបានឲ្យចុងចម្លើយឈ្មោះ **ពុំ មេសា** ខ្ចីប្រាក់ចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក ដោយមិនគិតការប្រាក់អ្វីឡើយ ហើយចុងចម្លើយឈ្មោះ **ពុំ មេសា** សន្យាថាខ្លួននឹងសងប្រាក់មកឲ្យខ្លួនគ្រប់ចំនួន នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៤ ដូចមានបញ្ជាក់នៅក្នុងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៤ និងលិខិតប្រគល់ទទួលប្រាក់ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៤។ ប៉ុន្តែលុះដល់ថ្ងៃកំណត់ដែលត្រូវបានកន្លងផុត ចុងចម្លើយឈ្មោះ **ពុំ មេសា** មិនបានសងប្រាក់មកឲ្យខ្លួនវិញតាមការសន្យានោះឡើយ ទោះបីជាខ្លួនបានជូនដំណឹង និងដាស់តឿនឲ្យសងប្រាក់មកវិញយ៉ាងណាក៏ដោយ (លិខិតជូនដំណឹង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨)។ ដោយសារតែចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចសងប្រាក់មកឲ្យខ្លួនគ្រប់ចំនួនតាមការសន្យានោះ គឺបណ្តាលខ្លួនត្រូវទទួលការខូចខាតយ៉ាងធ្ងន់ ដូចជា ខ្លួនមិនអាចទទួលបានការប្រាក់អ្វីឡើយពីប្រាក់ដើមចំនួន ៤០.០០០ ដុល្លារអាមេរិកនេះ ហើយថែមទាំងបានចំណាយពេលវេលា និង សោហ៊ុយដែលមិនចាំបាច់ដែលកើតចេញពីការអនុវត្តកាតព្វកិច្ចរបស់ចុងចម្លើយនេះ ទើបខ្លួនទាមទារឲ្យចុងចម្លើយសងសំណងការខូចខាតចំនួន ៥.០០០ ដុល្លារអាមរិក។

ចុងចម្លើយឈ្មោះ **ពុំ មេសា** បានធ្វើសេចក្តីថ្លែងការណ៍តបវិញថា ខ្លួនទទួលស្គាល់ថាខ្លួនពិតជាបានខ្ចីប្រាក់ពីដើមចោទឈ្មោះ **ចាន់ រក្សា** ចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក ប្រាកដមែន ប៉ុន្តែខ្លួនសូមធ្វើការបដិសេធត្រង់ចំណុចដែលដើមចោទបានធ្វើការលើកឡើងថា ខ្លួនមិនទាន់បានសងប្រាក់ទៅឲ្យដើមចោទវិញនោះ គឺមិនពិតទេ ពីព្រោះថា បន្ទាប់ពីខ្លួនបានទទួលការជូនដំណឹងឲ្យសងប្រាក់ពីដើមចោទ កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៤ មក គឺខ្លួនបានយកប្រាក់ទៅសងឲ្យដើមចោទគ្រប់ចំនួននៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រាក់ដែលខ្លួនយកទៅសងនោះ គឺជាប្រាក់សុទ្ធ ដែលមានក្រដាក់ប្រាក់ ១០០$ ចំនួន២០០សន្លឹក។ ទន្ទឹងជាមួយគ្នានេះដែរ ខ្លួនក៏សូមបដិសេធនូវការប្តឹងទាមទារឲ្យខ្លួនសងសំណងការខូចខាតចំនួន ៥.០០០ ដុល្លារអាមេរិក នេះ ដោយហេតុថា ខ្លួនបានសងប្រាក់ទៅឲ្យដើមចោទគ្រប់ចំនួនហើយ។

ដើមចោទឈ្មោះ **ចាន់ រក្សា** បានធ្វើសេចក្តីថ្លែងការណ៍តបទៅវិញថា ខ្លួនមិនបានទទួលការសងប្រាក់ពីចុងចម្លើយឈ្មោះ **ពុំ មេសា** ដូចដែលចុងចម្លើយបានលើកឡើងនោះទេ ហើយ

ម្យ៉ាងវិញទៀតប្រសិនបើ ចុងចម្លើយបានយកប្រាក់មកសងខ្លួននូវចំនួនទឹកប្រាក់ចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក ប្រាកដមែននោះ ចុះហេតុអ្វីបានជាចុងចម្លើយមិនបានដាក់លិខិតអំពីការទទួលការសង?

ចុងចម្លើយឈ្មោះ **ពុំ មេសា** បានបញ្ជាក់ថា នៅពេលដែលខ្លួនបានយកប្រាក់ទៅឱ្យដើមចោទនោះ គឺខ្លួនមិនបានធ្វើលិខិត ឬ ឯកសារអ្វីឡើយ ហើយក៏គ្មានសាក្សីណាដឹងលឺដែរ ព្រោះពេលសងប្រាក់នោះគឺ ខ្លួនយកប្រាក់ទៅសងនៅផ្ទះរបស់ដើមចោទ តែម្តង ដោយហេតុយើងទាំងពីរនាក់គឺជាអ្នកជិតខាងនឹងគ្នា។

## សំអាងហេតុ

**សាលាដំបូងរាជធានីភ្នំពេញ** យល់ឃើញថា៖

១.-ពាក្យបណ្តឹង ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៨ របស់ដើមចោទឈ្មោះ **ចាន់ រក្សា** គឺមានលក្ខណៈត្រឹមត្រូវស្របតាមបញ្ញត្តិនៃមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២.-តាមសេចក្តីថ្លែងការណ៍របស់ដើមចោទនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុ កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨, សេចក្តីថ្លែងការណ៍របស់ដើមចោទនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ , កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៤ និងលិខិតប្រគល់ទទួលប្រាក់ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៤ រវាងដើមចោទឈ្មោះ **ចាន់ រក្សា** និងចុងចម្លើយឈ្មោះ **ពុំ មេសា** គឺបញ្ជាក់បានបានថា ដើមចោទឈ្មោះ ចាន់ រក្សា ពិតជាមានសិទ្ធិលើបំណុលចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក លើចុងចម្លើយឈ្មោះ ពុំ មេសា ប្រាកដមែន ហើយទន្ទឹមនឹងនោះ ចុងចម្លើយឈ្មោះ ពុំ មេសា ក៏បានទទួលស្គាល់ថាខ្លួនពិតជាជំពាក់ប្រាក់ដើមចោទចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក ផងដែរ។

២.- ចុងចម្លើយឈ្មោះ ពុំ មេសា បានអះអាងថាបន្ទាប់ពីខ្លួនបានទទួលលិខិតជូនដំណឹងឱ្យសងប្រាក់ កាលពី១០ ខែកក្កដា ឆ្នាំ២០១៤ ពីដើមចោទភ្លាម ខ្លួនបានយកប្រាក់សុទ្ធចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក ដែលក្នុងនោះមានក្រដាស់ប្រាក់ ១០០ ដុល្លារអាមេរិក ចំនួន ២០០ សន្លឹក ទៅសងដើមចោទ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៤ ដោយមិនបានធ្វើជាលិខិតសងប្រាក់ ឬ សាក្សីដឹងលឺអ្វីឡើយ ។ ករណីនេះ តុលាការមិនអាចជឿជាក់បានឡើយ។

៣.- ដើមចោទឈ្មោះ ចាន់ រក្សា បានប្តឹងទាមទារឱ្យចុងចម្លើយសងសំណងការខូចខាតចំនួន ៥.០០០ ដុល្លារអាមេរិក មកឱ្យខ្លួនដោយអះអាងថា ចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ច

សងប្រាក់មកឱ្យខ្លួនគ្រប់ចំនួនតាមការសន្យានោះ គឺបណ្តាលខ្លួនត្រូវទទួលការខូតខាតយ៉ាងធ្ងន់ ដូចជា ខ្លួនមិនអាចទទួលបានការប្រាក់អ្វីឡើយពីប្រាក់ដើមចំនួន ៤០.០០០ ដុល្លារអាមេរិកនេះ ហើយថែមទាំងបានចំណាយពេលវេលា និងសោហ៊ុយដែលមិនចាំបាច់ដែលកើតចេញពីការអនុវត្តកាតព្វកិច្ចរបស់ចុងចម្លើយនេះ។ ករណីតុលាការយល់ឃើញថា ទឹកប្រាក់ចំនួន ៥.០០០ ដុល្លារអាមេរិក គឺមានចំនួនច្រើនជាងអ្វីដែលដើមចោទខូចខាតជាក់ស្តែង ដែលហេតុតុលាការគប្បីបន្ថយនូវសំណងការខូចខាតនេះ។

**សេចក្តីសម្រេចបញ្ចប់**

១.- បង្គាប់ឱ្យចុងចម្លើយឈ្មោះ ពុំ មេសា សងប្រាក់ដើមចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក មកឱ្យដើមចោទឈ្មោះ ចាន់ រក្សា។

២.- បង្គាប់ឱ្យចុងចម្លើយឈ្មោះ ពុំ មេសា សងសំណងការខូចខាតចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល មកឱ្យដើមចោទឈ្មោះ ចាន់ រក្សា។

៣.- ចុងចម្លើយឈ្មោះ ពុំ មេសា ត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

សាលក្រមនេះត្រូវប្រកាសជាសាធារណៈ នៅចំពោះមុខដើមចោទ និងចុងចម្លើយ និងទុកសិទ្ធិឱ្យភាគីប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

ហត្ថលេខា និងឈ្មោះចៅក្រម

**មាស និមល**

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៣រោច ខែចែត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨

**ក្រឡាបញ្ជី**

**សី សោភា**

**បានឃើញ**

ថ្ងៃអង្គារ ៣រោច ខែចែត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨

**ចៅក្រម**

**មាស និមល**

ឧបសម្ព័ន្ធទី០២

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

# លិខិតបញ្ជាក់ការចូលស្ថាពរនៃសាលក្រម

លេខ៖ ៩៨ “ក” វវ

យើង **នី សោភា** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ មាត្រា២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។
- បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ១០២ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៨។
- បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ៩៧ “ក” ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ ពាក្យសុំឱ្យបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រម ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨ របស់ឈ្មោះ ចាន់ រក្សា។
- បានឃើញ របាយការណ៍ស្ដីពីការបញ្ជូន ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៨ របស់មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនឈ្មោះ ឡុង ពេជ្រ ដែលបញ្ជាក់ថាបានបញ្ជូនដោយប្រគល់នូវសាលក្រមរដ្ឋប្បវេណីលេខ ៩៧ “ក” ដល់ឈ្មោះ **ពុំ មេសា** នាថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៨។
- បានឃើញ សេចក្ដីអនុញ្ញាត ចុះថ្ងៃទី០៤ខែមេសា ឆ្នាំ២០១៨របស់លោកស្រីចៅក្រម មាសនិមល។

**សូមបញ្ជាក់ថា**

១.- សាលក្រមរដ្ឋប្បវេណីលេខ ៩៧ “ក” ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ បានចូលជាស្ថាពរចាប់តាំងពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ រួចហើយ។

២.-លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមរដ្ឋប្បវេណីនេះ ចេញឱ្យសាមីខ្លួនដើម្បីយកទៅប្រើប្រាស់តាមច្បាប់។

ថ្ងៃពុធ ១០រោច ខែពិសាខ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៨

**ក្រឡាបញ្ជី**

**នី សោភា**

ឧបសម្ព័ន្ធទី០៣

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ៖ ៩៩ "ក" វវ

## រូបមន្តអនុវត្ត

យើង **នី សោភា** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ មាត្រា៣៥៤ មាត្រា៣៥៥ និងមាត្រា៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។
- បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ១០២ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៨។
- បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ៩៧ "ក" ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត ចុះថ្ងៃទី០៧ខែ០៥ឆ្នាំ២០១៨របស់ឈ្មោះចាន់ រក្សា។
- បានឃើញសេចក្តីអនុញ្ញាតចុះថ្ងៃទី០៤ខែ០៤ឆ្នាំ២០១៨របស់លោកស្រីចៅក្រម **មាសនិមល**។

**សូមបញ្ជាក់អំពីខ្លឹមសារនៃការអនុវត្ត មានដូចខាងក្រោមនេះ៖**

ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ **ចាន់ រក្សា** ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មានលំនៅឋានផ្ទះលេខ ២០ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

អាចអនុវត្តដោយបង្ខំដោយផ្អែកតាមលិខិតអនុវត្តជាសាលក្រមរដ្ឋប្បវេណីលេខ ៩៧ "ក" ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ចំពោះកូនបំណុលនៃការអនុវត្តឈ្មោះ **ពុំ មេសា** ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មានលំនៅឋានផ្ទះលេខ ២១ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ បាន។

*សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់ឱ្យស្ថាប័នអនុវត្តឱ្យអនុវត្តដោយបង្ខំតាមសាលក្រមស្ថាពរនេះ និងឱ្យអាជ្ញាធរសាធារណៈជួយអនុវត្តសាលក្រមនេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។*

ថ្ងៃពុធ ១០រោច ខែពិសាខ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៨

**ក្រឡាបញ្ជី**

**នី សោភា**

ឧបសម្ព័ន្ធទី០៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ
ចូល
សំណុំរឿងអនុវត្តលេខ៖ ៥៤
ថ្ងៃខែឆ្នាំ៖ ០៩ ឧសភា ២០១៨
ម៉ោង៖ ០៩ : ៣០ នាទីព្រឹក

**ពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ**

**ម្ចាស់បំណុលនៃការអនុវត្ត៖** ឈ្មោះ **ចាន់ រក្សា** ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មានលំនៅឋានផ្ទះលេខ ២០ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**កូនបំណុលនៃការអនុវត្ត៖** ឈ្មោះ **ពុំ មេសា** ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មានលំនៅឋានផ្ទះលេខ ២១ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**សូមគោរពជូន**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ សុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុដោយផ្អែកតាមសាលក្រមរដ្ឋប្បវេណីលេខ ៩៧ "ក" ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង** ៖
- មាត្រា៣៨៤ មាត្រា៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។
- សាលក្រមរដ្ឋប្បវេណីលេខ ៩៧ "ក" ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។
- លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមរដ្ឋប្បវេណី លេខ ៩៨ "ក" វវ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។
- រូបមន្តអនុវត្ត លេខ ៩៩ "ក" វវ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ ។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទសូមគោរពនិងជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបនូវចំណុចសំខាន់ៗដែលជាមូលដ្ឋាននៃការអនុវត្តដូចខាងក្រោម៖

**១.- សញ្ញាណនៃលិខិតអនុវត្ត**

ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត គឺ សាលក្រមរដ្ឋប្បវេណីលេខ ៩៧ "ក" ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារ៖ បង្គាប់ឲ្យចុងចម្លើយឈ្មោះ ពុំ មេសា សងប្រាក់ដើមចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារ

អាមេរិក មកឱ្យដើមចោទឈ្មោះ ចាន់ រក្សា និង បង្គាប់ឱ្យចុងចម្លើយឈ្មោះ ពុំ មេសា សង សំណងការខូចខាតចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល មកឱ្យដើមចោទឈ្មោះ ចាន់ រក្សា។

សាលក្រមនេះបានចូលជាស្ថាពរនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ ដូចមានបញ្ជាក់ក្នុង លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រម លេខ ៩៨ "ក" វវ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ហើយសាលក្រមនេះមានអានុភាពអនុវត្តដោយបង្ខំតាម ច្បាប់ ដូចមានបញ្ជាក់នៅក្នុងរូបមន្តអនុវត្តលេខ ៩៩ "ក" វវ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

**២.- សេចក្តីស្នើសុំឱ្យអនុវត្ត**

សំណើសុំឱ្យអាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ អនុវត្តតាមវិធានបង្ខំដោយផ្ទាល់ ដោយលក់ដោយបង្ខំនូវចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្តឈ្មោះ **ពុំ មេសា** ដើម្បីយកប្រាក់មកសងខ្ញុំបាទតាមសាលក្រមរដ្ឋប្បវេណីលេខ ៩៧ "ក" ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

**៣.- សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ**

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តបង្ខំ គឺជា ចលនវត្ថុទាំងអស់ដែលកាន់កាប់ដោយ កូនបំណុលនៃការអនុវត្ត ស្ថិតនៅផ្ទះលេខ ២១ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួល គោក រាជធានីភ្នំពេញដែលជាលំនៅឋានរបស់កូនបំណុលនៃការអនុវត្តឈ្មោះ **ពុំ មេសា** ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យនិងសម្រេចបញ្ជូន សំណុំរឿងអនុវត្តនេះ ទៅអាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចំណាត់ការនីតិវិធី ជាសមត្ថកិច្ចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពអំពីខ្ញុំបាទ។

ថ្ងៃពុធ ១០រោច ខែពិសាខ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨

**ម្ចាស់បំណុលនៃការអនុវត្ត**

**ចាន់ រក្សា**

**<u>សូមជូនភ្ជាប់មកជាមួយនូវ</u>៖**

| | |
|---|---|
| -សាលក្រមរដ្ឋប្បវេណី | ០១ច្បាប់ |
| -លិខិតបញ្ជាក់ការចូលជាស្ថាពរ | ០១ច្បាប់ |
| -រូបមន្តអនុវត្ត | ០១ច្បាប់ |

ឧបសម្ព័ន្ធទី០៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ៖ ......១០៥...... លខ

**សូមជម្រាបជូន**

**លោកអភិបាលនៃគណៈអភិបាលខណ្ឌទួលគោក**

**កម្មវត្ថុ** ៖ សំណើសុំកម្លាំងចូលរួមសហការអនុវត្ត សាលក្រមរដ្ឋប្បវេណីលេខ ៩៧ “ក” ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃ អង្គារ ០៨កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០១៨ វេលាម៉ោង ៨ និង ៣០ នាទីព្រឹក។

**យោង** ៖ -មាត្រា ៣៣៨ និងមាត្រា៣៣៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកអភិបាល** ឲ្យបានជ្រាបថា ៖ សាលក្រមរដ្ឋប្បវេណីលេខ ៩៧ “ក” ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញបានចូលជាស្ថាពរ និងមានអានុភាពអនុវត្តតាមនីតិវិធីច្បាប់រួចហើយ។

ដើម្បីធានាសុវត្ថិភាព និង បំបាត់នូវការប្រឆាំងដែលអាចនឹងកើតមានឡើងនៅកាលបរិច្ឆេទនៃការអនុវត្ត សូម លោកអភិបាល ចាត់សមាសភាពរួមមាន៖ មន្ត្រីសាលាខណ្ឌ, តំណាងសង្កាត់ , មន្ត្រីនគរបាល, និង មន្ត្រីដែលពាក់ព័ន្ធ ដើម្បីចូលរួមអនុវត្តសាលក្រមខាងលើដែលនឹងប្រព្រឹត្តទៅ ថ្ងៃ អង្គារ ០៨កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០១៨ វេលាម៉ោង ៨ និង ៣០ នាទីព្រឹក ហើយ សមាភាពទាំងអស់នឹងត្រូវជួបជុំគ្នានៅទីតាំងអនុវត្តដែលស្ថិតនៅផ្ទះលេខ ២១ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

*សូម **លោកអភិបាល** មេត្តាទទួលនូវការគោរពរាបអានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។*

**សូមជូនភ្ជាប់មកជាមួយនូវ៖**

| | |
|---|---|
| -សាលក្រមរដ្ឋប្បវេណី | ០១ច្បាប់ |
| -លិខិតបញ្ជាក់ការចូលជាស្ថាពរ | ០១ច្បាប់ |
| -រូបមន្តអនុវត្ត | ០១ច្បាប់ |

ថ្ងៃច័ន្ទ ១៥រោច ខែពិសាខ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៨

**អាជ្ញាសាលា**

**ជ័យ តេជៈ**

ឧបសម្ព័ន្ធទី០៦

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

## កំណត់ហេតុស្តីពីការរឹបអូសចលនវត្ថុ

យើង **ជ័យ តេជៈ** អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ

ដោយមានលោក **សុខ ទបុល** ជាអ្នកធ្វើកំណត់ហេតុ

បាននឹកនាំគណៈកម្មការចំរុះ ចុះអនុវត្តរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្តឈ្មោះ **ពុំ មេសា** ស្ថិតនៅផ្ទះលេខ ២១ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ តាមសាលក្រមរដ្ឋប្បវេណីលេខ ៩៧ “ក” ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានដំណើរការដូចខាងក្រោម៖

**ក.- សញ្ញាណនៃរឿងក្តី**

សំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ ដែលមានម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ចាន់ រក្សា និង កូនបំណុលនៃការអនុវត្តឈ្មោះ ពុំ មេសា ដែលមានកម្មវត្ថុ៖ លក់ដោយបង្ខំនូវចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត។

**ខ.- កាលបរិច្ឆេទ ពេលវេលា ទីកន្លែង និងសមាសភាពចូលរួម**

- កាលបរិច្ឆេទ ៖ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨
- ម៉ោង ៖ ០៨ និង៣០ នាទីព្រឹក។
- ទីតាំងអនុវត្ត ៖ ផ្ទះរបស់កូនបំណុលនៃការអនុវត្តស្ថិតនៅផ្ទះលេខ ២១ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ
- សមាសភាពចូលរួម ៖

| | | | |
|---|---|---|---|
| ......................... | ១. | លោក ទេព វាសនា | តំណាងសាលាខណ្ឌ |
| ......................... | ២. | លោក ហាស់ បូរ៉ា | តំណាងសាលាសង្កាត់បឹងសាឡាង |
| ......................... | ៣. | លោក គា រតនា | នគរបាលរដ្ឋបាលសង្កាត់ |

......................... ៤. លោក ហែម វិជ្ជា នគរបាលរដ្ឋបាលសង្កាត់

......................... ៥. លោក ទី មង្គល មេភូមិ

**គ.- ខ្លឹមសារនៃសកម្មភាពដែលបានចាត់ចែង**

នៅពេលដែលចុះដល់ទីតាំងអនុវត្តខាងលើ យើងបានជួបកូនបំណុលនៃការអនុវត្តឈ្មោះ **ពុំ មេសា** ហើយយើងបានអានខ្លឹមសារនៃសាលក្រមខាងលើឱ្យអ្នកចូលរួមទាំងអស់បានស្តាប់។

បន្ទាប់មកយើងបានដាស់តឿនឲ្យកូនបំណុលនៃការអនុវត្តឈ្មោះ **ពុំ មេសា** សងបំណុលទៅឲ្យម្ចាស់បំណុលនៃការអនុវត្តឈ្មោះ **ចាន់ វាសនា** ដោយស្ម័គ្រចិត្ត តាមបញ្ញត្តិនៃមាត្រា ៣៨៤ កថាខណ្ឌទី ៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប៉ុន្តែកូនបំណុលនៃការអនុវត្តបានបដិសេធមិនសងបំណុលតាមការដាស់តឿននេះឡើយ។

បន្ទាប់មកទៀតយើងចាប់ផ្តើមនីតិវិធីរឹបអូសចលនវត្ថុ ដោយជាដំបូងយើងធ្វើការពិនិត្យឃើញថាទ្រព្យសម្បត្តិជាចលនវត្ថុដែលស្ថិតនៅក្នុងទីតាំងនេះរួមមាន៖ រថយន្តម៉ាក Lexus RX 350 មានផ្លាកលេខ 2XX-2244 ចំនួន ០១ គ្រឿង, រថយន្តម៉ាក Lexus RX 300 មានផ្លាកលេខ 2XX-2213 ចំនួន ០១ គ្រឿង, ទូដែកចំនួន ០១, ខ្សែក(លោហៈធាតុព័ណ៌មាស) ចំនួន ០១ ខ្សែ, នាឡិកាដៃម៉ាក Rolex ចំនួន ០១ ខ្សែ និង សាឡុងឈើឈុតធំ ចំនួន ០១ ឈុត។ ជាមួយគ្នានេះដែរ យើងបានចាត់ចែងឲ្យជាងធ្វើការបើកទូដែក តាមបញ្ញត្តិនៃមាត្រា ៣៨៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងប្រការ ២ កថាខណ្ឌទី២ នៃប្រកាសលេខ ៣០ កយ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌ ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ហើយយើងពិនិត្យឃើញថានៅក្នុងទូដែកនេះមានប្រាក់សុទ្ធចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ។

ហេតុដូច្នេះ យើងសម្រេចរឹបអូសប្រាក់សុទ្ធដែលមាននៅក្នុងទូដែកចំនួន ១០.០០០(មួយម៉ឺន) ដុល្លារអាមេរិក និងរឹបអូសចលនវត្ថុដែលស្ថិតនៅទីតាំងអនុវត្ត រួមមាន រថយន្តម៉ាក Lexus RX 350 ដែលមានផ្លាកលេខ 2XX-2244 ចំនួន ០១ គ្រឿង, រថយន្តម៉ាក Lexus RX 300 ដែលមានផ្លាកលេខ 2XX-2213 ចំនួន ០១ គ្រឿង, ទូដែកចំនួន ០១, ខ្សែក(លោហៈធាតុព័ណ៌មាស) ចំនួន ០១ ខ្សែ, នាឡិកាដៃម៉ាក Rolex ចំនួន ០១ ខ្សែ មករក្សាទុកនៅឃ្លាំងសាលាដំបូងរាជធានីភ្នំពេញ។

**ឃ.- កាលបរិច្ឆេទនៃការធ្វើ និង ការចាត់ចែងកំណត់ហេតុ**

កំណត់ហេតុនេះត្រូវបានធ្វើឡើងនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨ វេលាម៉ោង ៨ និង៣០ នាទីព្រឹក និងបញ្ចប់ នៅវេលាម៉ោង ៩ និង ៣០ នាទី នាថ្ងៃខែឆ្នាំដដែល ហើយយើងបានអាន កំណត់ហេតុនេះឱ្យអ្នកចូលរួមបានស្តាប់។

**អាជ្ញាសាលា** **អ្នកធ្វើកំណត់ហេតុ**

**សុខ ឧបុល**

**ជ័យ តេជ:**

**អ្នកចូលរួមអនុវត្ត**

| | | | |
|---|---|---|---|
| ១. | តំណាងសាលាខណ្ឌ | ...................... | ទេព វាសនា |
| ២. | តំណាងសាលាសង្កាត់បឹងសាឡាង | ...................... | ហាស់ បូរ៉ា |
| ៣. | នគរបាលរដ្ឋបាលសង្កាត់ | ...................... | គា រតនា |
| ៤. | នគរបាលរដ្ឋបាលសង្កាត់ | ...................... | ហែម វិជ្ជា |
| ៥. | មេភូមិ | ...................... | ទី មង្គល |
| ៦. | ម្ចាស់បំណុលនៃការអនុវត្ត | ...................... | ចាន់ រក្សា |
| ៧. | កូនបំណុលនៃការអនុវត្ត | ...................... កូនបំណុលនៃការអនុវត្តចូលរួមអនុវត្ត តែមិនព្រមផ្តិតមេដៃលើកំណត់ហេតុ | ពុំ មេសា |
| ៨. | ជាងសោរ | ...................... | វិត សីហា |

**ឧបសម្ព័ន្ធទី០៧**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ៖.........១០៦.....លខ

## លិខិតផ្តុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូសរថយន្ត

**សូមជម្រាបជូន**

**លោកប្រធានមន្ទីរសាធារណការ និង ដឹកជញ្ជូនរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ ស្តីពីការផ្តុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូសថយន្តម៉ាក Lexus RX 350 មានផ្លាកលេខ 2XX-2244 និង រថយន្តម៉ាក Lexus RX 300 មានផ្លាកលេខ 2XX-2213។

**យោង** ៖ -មាត្រា ៣៨៧ និងមាត្រាពាក់ព័ន្ធផ្សេងទៀតនៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកអភិបាល** ឲ្យបានជ្រាបថា ៖ កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨ អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញបានដឹកនាំគណៈកម្មការចំរុះចុះរឹបអូសរថយន្តម៉ាក Lexus RX 350 មានផ្លាកលេខ 2XX-2244 និង រថយន្តម៉ាក Lexus RX 300 មានផ្លាកលេខ 2XX-2213 ដើម្បីប្តូរជាប្រាក់យកមកសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ **ចាន់ វក្សា** តាមសាលក្រមរដ្ឋប្បវេណីលេខ ៩៧ “ក” ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។ ដើម្បីបង្កើតអានុភាពនៃការរឹបអូសរថយន្តទាំងពីរគ្រឿងខាងបាន តម្រូវឲ្យមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីភ្នំពេញ ធ្វើការសរសេរចូលនូវហេតុការណ៍នៃការរឹបអូសរថយន្តនេះចូលក្នុងសៀវភៅចុះបញ្ជី តាមបញ្ញត្តិនៃមាត្រា ៣៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

អាស្រ័យហេតុដូចនេះ សូម **លោកប្រធានមន្ទីរ** ពិនិត្យ និងចាត់ចែងចុះបញ្ជីរឹបអូសរថយន្តខាងលើតាមនីតិវិធីច្បាប់។

*សូម **លោកប្រធានមន្ទីរ** មេត្តាទទួលនូវការគោរពរាបអានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។*

ថ្ងៃសុក្រ ១៣កើត ខែបឋមាសាធ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨

**អាជ្ញាសាលា**

**<u>សូមជូនភ្ជាប់មកជាមួយនូវ</u>**៖

| | |
|---|---|
| -កំណត់ហេតុស្តីពីការរឹបអូសចលនវត្ថុ | ០១ច្បាប់ |
| -សាលក្រមរដ្ឋប្បវេណី | ០១ច្បាប់ |
| -លិខិតបញ្ជាក់ការចូលជាស្ថាពរ | ០១ច្បាប់ |
| -របមនអនវត | ០១ចកប់ |

ឧបសម្ព័ន្ធទី០៨

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
ចូល
លេខ៖ ០២៩
ថ្ងៃខែឆ្នាំ៖ ២២ ឧសភា ២០១៨
ម៉ោង៖ ១០:៣០ នាទីព្រឹក

**ពាក្យសុំជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឲ្យវាយតម្លៃចលនវត្ថុ**

ខ្ញុំឈ្មោះ **ចាន់ រក្សា** ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មានលំនៅឋានផ្ទះលេខ ២០ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាម្ចាស់បំណុលនៃការអនុវត្តនៅក្នុងសំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

**សូមគោរពជូន**

**លោក ជ័យ តេជៈ អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ សុំឲ្យចេញសេចក្តីជ្រើសតាំងអ្នកវាយតម្លៃដើម្បីធ្វើការវាយតម្លៃចលនវត្ថុដែលបានរឹបអូស ដូចបញ្ជាក់នៅក្នុងកំណត់ហេតុស្តីពីការរឹបអូសចលនវត្ថុ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១៨ របស់អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ។

**យោង** ៖
- មាត្រា ៣៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី
- សំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨
- កំណត់ហេតុស្តីពីការរឹបអូសចលនវត្ថុ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨ របស់អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ
- ប័ណ្ណប៉ាតង់លេខ ០០៧៨ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីអនុញ្ញាតឲ្យលោក **រស់ សុភ័ក្រ** ប្រកបអាជីវកម្មយានដ្ឋាន
- ប័ណ្ណប៉ាតង់លេខ ០០៧៩ ចុះថ្ងៃទី១០ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីអនុញ្ញាតឲ្យលោក **លី បូរី** ប្រកបអាជីវកម្មលក់គ្រឿងសង្ហារឹម
- ប័ណ្ណប៉ាតង់លេខ ០០៣ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីអនុញ្ញាតឲ្យលោក **មាស ពន្លឺ** ប្រកបអាជីវកម្មលក់គ្រឿងអលង្ការ។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទសូមគោរព និង ជម្រាបជូន **លោកអគ្គាសាលា** ដើម្បីជ្រើសតាំងអ្នកវាយតម្លៃលើចលនវត្ថុដែលត្រូវបានរឹបអូស ដូចខាងក្រោម៖

១.- លោក ***រស់ សុភក្រ*** ភេទប្រុស អាយុ ៣៤ឆ្នាំ ជនជាតិខ្មែរ មានមុខរបរជាម្ចាស់យានដ្ឋាន មានអាស័យដ្ឋានផ្ទះលេខ ៣៣៣ ផ្លូវលេខ ២២២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ធ្វើជាអ្នកវាយតម្លៃលើរថយន្តម៉ាក Lexus RX 350 ដែលមានផ្លាកលេខ 2XX-2244 និង រថយន្តម៉ាក Lexus RX 300 ដែលមានផ្លាកលេខ 2XX-2213 ។

២.- លោក **លី បូរី** ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ មានមុខរបរជាអ្នកគ្រឿងសង្ហារឹម មានអាស័យដ្ឋានផ្ទះលេខ ៤៤៤ ផ្លូវលេខ ៣៣៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ធ្វើជាអ្នកវាយតម្លៃលើសាឡុងឈើឈុតធំ ចំនួន ០១ ឈុត។

៣.- លោក **មាស ពន្លឺ** ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ មានមុខរបរជាអ្នកលក់គ្រឿងអលង្ការ មានអាស័យដ្ឋានផ្ទះលេខ ៥៥៥ ផ្លូវលេខ ៤៤៤ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ធ្វើជាអ្នកវាយតម្លៃលើ ខ្សែក(លោហៈធាតុព័ណ៌មាស) ចំនួន ០១ ខ្សែ និងនាឡិកាដៃម៉ាក Rolex ចំនួន ០១ ខ្សែ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកអគ្គាសាលា** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម **លោកអគ្គាសាលា** មេត្តាទទួលនូវការគោរពអំពីខ្ញុំបាទ។

ថ្ងៃសុក្រ ១៣កើត ខែបឋមាសាធ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨

**ម្ចាស់បំណុលនៃការអនុវត្ត**

**ចាន់ រក្សា**

ឧបសម្ព័ន្ធទី០៩

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ៖....១១១...សមអ

**សេចក្តីសម្រេចស្តីពី**
**ការជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឲ្យវាយតម្លៃចលនវត្ថុ**

យើង **ជ័យ តេជះ** អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ មាត្រា៣៩៥ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញ សំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨
- បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ៩៧ “ក” ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ
- បានឃើញ លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមរដ្ឋប្បវេណី លេខ ៩៨ “ក” វវ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ
- បានឃើញ រូបមន្តអនុវត្ត លេខ ៩៩ “ក” វវ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ
- បានឃើញ កំណត់ហេតុស្តីពីការរឹបអូសចលនវត្ថុ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨
- បានឃើញ ពាក្យសុំជ្រើសតាំងអ្នកវាយតម្លៃនិងបង្គាប់ឲ្យវាយតម្លៃចលនវត្ថុ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ របស់ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ចាន់ រក្សា
- បានឃើញ ប័ណ្ណប៉ាតង់លេខ ០០៧៨ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីអនុញ្ញាតឲ្យលោក **រស់ សុភ័ក្រ** ប្រកបអាជីវកម្មយានដ្ឋាន

- បានឃើញ ប័ណ្ណប៉ាតង់លេខ ០០៧៩ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីអនុញ្ញាតឱ្យលោក **លី បូរី** ប្រកបអាជីវកម្មលក់គ្រឿងសង្ហារឹម
- បានឃើញ ប័ណ្ណប៉ាតង់លេខ ០០៣ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីអនុញ្ញាតឱ្យលោក **មាស ពន្លឺ** ប្រកបអាជីវកម្មលក់គ្រឿងអលង្ការ

**សំអាងហេតុ**

១.- រថយន្តម៉ាក Lexus RX 350 ដែលមានផ្លាកលេខ 2XX-2244 ចំនួន ០១ គ្រឿង, រថយន្តម៉ាក Lexus RX 300 ដែលមានផ្លាកលេខ 2XX-2213 ចំនួន ០១ គ្រឿង, ទូដែកចំនួន ០១, ខ្សែក(លោហៈធាតុព័ណ៌មាស) ចំនួន ០១ ខ្សែ, នាឡិកាដៃម៉ាក Rolex ចំនួន ០១ ខ្សែ ត្រូវរឹបអូសដើម្បីប្តូរជាប្រាក់មកសិទ្ធិលើបំណុលចំនួន ២០,000USD តាមអំណាចសាលក្រមរដ្ឋប្បវេណីលេខ ៩៧ “ក” ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ គឺមានតម្លៃថ្លៃ ហើយអាជ្ញាសាលាមិនអាចធ្វើការវាយតម្លៃដោយខ្លួនឯងបាន គប្បីជ្រើសតាំងអ្នកជំនាញដើម្បីឱ្យវាយតម្លៃលើចលនវត្ថុនេះ តាមបញ្ញត្តិនៃមាត្រា៣៩៥ កថាខណ្ឌទី៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២.-តាមពាក្យសុំជ្រើសតាំងអ្នកវាយតម្លៃនិងបង្គាប់ឱ្យវាយតម្លៃចលនវត្ថុ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ របស់ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ចាន់ រក្សា ដែលបានស្នើសុំឱ្យលោក **រស់ សុភក្រ** ភេទប្រុស អាយុ ៣៤ឆ្នាំ ជនជាតិខ្មែរ មានមុខរបរជាម្ចាស់យានដ្ឋាន មានអាស័យដ្ឋានផ្ទះលេខ ៣៣៣ ផ្លូវលេខ ២២២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ធ្វើជាអ្នកវាយតម្លៃលើរថយន្តម៉ាក Lexus RX 350 ដែលមានផ្លាកលេខ 2XX-2244 និង រថយន្តម៉ាក Lexus RX 300 ដែលមានផ្លាកលេខ 2XX-2213, លោក **លី បូរី** ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ មានមុខរបរជាអ្នកគ្រឿង សង្ហារឹម មានអាស័យដ្ឋានផ្ទះលេខ ៤៤៤ ផ្លូវលេខ ៣៣៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ធ្វើជាអ្នកវាយតម្លៃលើសាឡុងឈើឈុតធំ ចំនួន ០១ ឈុត និងលោក **មាស ពន្លឺ** ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ មានមុខរបរជាអ្នកលក់គ្រឿងអលង្ការ មានអាស័យដ្ឋានផ្ទះលេខ ៥៥៥ ផ្លូវលេខ ៤៤៤ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ធ្វើជាអ្នកវាយតម្លៃលើ ខ្សែក(លោហៈធាតុព័ណ៌មាស) ចំនួន ០១ ខ្សែ និងនាឡិកាដៃម៉ាក Rolex ចំនួន ០១ ខ្សែ ដោយភ្ជាប់មកជាមួយនូវប័ណ្ណប៉ាតង់លេខ ០០៧៨ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីអនុញ្ញាតឱ្យលោក **រស់ សុភ័ក្រ**

ប្រកបអាជីវកម្មយានដ្ឋាន, ប័ណ្ណប៉ាតង់លេខ ០០៧៩ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីអនុញ្ញាតឱ្យលោក **លី បូរី** ប្រកបអាជីវកម្មលក់គ្រឿងសង្ហារឹម និងប័ណ្ណប៉ាតង់លេខ ០០៣ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីអនុញ្ញាតឱ្យលោក **មាស ពន្លឺ** ប្រកបអាជីវកម្មលក់គ្រឿងអលង្ការ ដែលបញ្ជាក់បានថាឈ្មោះ **រស់ សុភក្រ, ឈ្មោះ លី បូរី និងឈ្មោះ មាស ពន្លឺ** ពិតជាមានជំនាញ និងអាចវាយតម្លៃអំពីចលនវត្ថុដែលត្រូវបានរឹបអូសបាន។

**សេចក្តីសម្រេចបញ្ចប់**

១.- ជ្រើសតាំង និងបង្គាប់ឲ្យ លោក **រស់ សុភក្រ** ភេទប្រុស អាយុ ៣៤ឆ្នាំ ជនជាតិខ្មែរ មានមុខរបរជាម្ចាស់យានដ្ឋាន មានអាស័យដ្ឋានផ្ទះលេខ ៣៣៣ ផ្លូវលេខ ២២២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ធ្វើជាអ្នកវាយតម្លៃលើរថយន្តម៉ាក Lexus RX 350 ផ្លាកលេខ 2XX-2244 ចំនួន ០១ គ្រឿង និង រថយន្តម៉ាក Lexus RX 300 ផ្លាកលេខ 2XX-2213 ចំនួន ០១គ្រឿង។

២.- ជ្រើសតាំង និងបង្គាប់ឲ្យលោក **លី បូរី** ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ មានមុខរបរជាអ្នកគ្រឿងសង្ហារឹម មានអាស័យដ្ឋានផ្ទះលេខ ៤៤៤ ផ្លូវលេខ ៣៣៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ធ្វើជាអ្នកវាយតម្លៃលើសាឡុងឈើឈុតធំ ចំនួន ០១ ឈុត។

៣.- ជ្រើសតាំង និងបង្គាប់ឲ្យលោក **មាស ពន្លឺ** ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ មានមុខរបរជាអ្នកលក់គ្រឿងអលង្ការ មានអាស័យដ្ឋានផ្ទះលេខ ៥៥៥ ផ្លូវលេខ ៤៤៤ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ធ្វើជាអ្នកវាយតម្លៃលើ ខ្សែក(លោហៈធាតុព័ណ៌មាស) ចំនួន ០១ ខ្សែ និងនាឡិកាដៃម៉ាក Rolex ចំនួន ០១ ខ្សែ។

ថ្ងៃសុក្រ ១៣កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨

**អាជ្ញាសាលា**

**ជំនុំ ចៅក្រម:**

ឧបសម្ព័ន្ធទី១០

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

ចូល | លេខ៖ ០២៩ | ថ្ងៃខែឆ្នាំ៖ ២៥ ឧសភា ២០១៨ | ម៉ោង៖ ៨ : ៣០ នាទីព្រឹក

## របាយការណ៍ស្ដីពីលទ្ធផលនៃការវាយតម្លៃរថយន្ត

ខ្ញុំបាទឈ្មោះ **រស់ សុភក្រ** ភេទប្រុស អាយុ ៣៤ឆ្នាំ ជនជាតិខ្មែរ មានមុខរបរជាម្ចាស់យានដ្ឋាន មានអាស័យដ្ឋានផ្ទះលេខ ៣៣៣ ផ្លូវលេខ ២២២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**សូមគោរពជូន**

**លោក ជ័យ តេជៈ អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ សំណើសុំរាយការណ៍អំពីលទ្ធផលនៃការវាយតម្លៃលើរថយន្តម៉ាក Lexus RX 350 ដែលមានផ្លាកលេខ 2XX-2244 និង រថយន្តម៉ាក Lexus RX 300 ដែលមានផ្លាកលេខ 2XX-2213 ។

**យោង** ៖ -សំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨

-សេចក្ដីសម្រេចស្ដីពីការជ្រើសតាំងអ្នកវាយតម្លៃនិងបង្គាប់ឲ្យវាយតម្លៃចលនវត្ថុលេខ ១១១ សមអ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ របស់អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **លោកអាជ្ញាសាលា** ដើម្បីផ្ដល់ជូននូវលទ្ធផលនៃការវាយតម្លៃលើរថយន្តម៉ាក Lexus RX 350 ដែលមានផ្លាកលេខ 2XX-2244 និង រថយន្តម៉ាក Lexus RX 300 ដែលមានផ្លាកលេខ 2XX-2213 តាមសេចក្ដីសម្រេចស្ដីពីការជ្រើសតាំងអ្នកវាយតម្លៃនិងបង្គាប់ឲ្យវាយតម្លៃចលនវត្ថុលេខ ១១១ សមអ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ របស់អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ ដូចខាងក្រោម៖

**១.- រថយន្តម៉ាក Lexus RX 350 មានផ្លាកលេខ 2XX-2244 ផលិតនៅឆ្នាំ ២០១០**

- **ស្ថានភាពខាងក្រៅនៃរថយន្ត**៖ ព៌ណឡានទាំងមូលស្ថិតនៅក្នុងសភាពល្អ ប៉ុន្តែកាងខាងមុខរថយន្តតម្រូវឲ្យមានការបាញ់ថ្នាំជាថ្មី, សំបកកង់រថយន្តនៅអាចប្រើបានជាធម្មតា

, ចំណែកឯគ្រឿងខាងក្នុងរថយន្តដូចជា ម៉ាញ៉េរថយន្ត, ពូកឡាន ជាអាទិ៍ ស្ថិតនៅក្នុងសភាពល្អអាចប្រើប្រាស់បានដោយពុំបាច់កែច្នៃអ្វីឡើយ ។ ជារួមរថយន្តនេះស្ថិតនៅក្នុងសភាពល្អ ដែលប្រើប្រាស់បានជាធម្មតា។

- **ស្ថានភាពគ្រឿងម៉ាស៊ីននៃរថយន្ត**៖ គ្រឿងម៉ាស៊ីនរថយន្តនេះមិនមានខូចខាត ឬត្រូវជួសជុលអ្វីឡើយ ពោលគឺស្ថិតនៅក្នុងសភាពល្អ។
- **ឯកសារពាក់ព័ន្ធនឹងរថយន្ត**៖ រថយន្តនេះមិនមានឯកសារច្បាប់ដើមនៃប័ណ្ណសំគាល់ម្ចាស់យានយន្តឡើយ ហើយរថយន្តនេះមិនទាន់បានបង់ពន្ធផ្លូវសម្រាប់ឆ្នាំ ២០១៧ ឡើយ។
- **តម្លៃដែលប៉ាន់ប្រមាណសម្រាប់ទីផ្សារ**៖ រថយន្តនេះ អាចត្រូវលក់លើទីផ្សារបានក្នុងតម្លៃប្រមាណ ៣៥.០០០ (បីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក។
- **តម្លៃដែលប៉ាន់ប្រមាណសម្រាប់ការលក់ដោយបង្ខំ**៖ រថយន្តនេះ អាចត្រូវលក់លើទីផ្សារបានក្នុងតម្លៃប្រមាណ ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក។

**២.- រថយន្តម៉ាក Lexus RX 300 ដែលមានផ្លាកលេខ 2XX-2213 ផលិតនៅឆ្នាំ២០០២**

- **ស្ថានភាពខាងក្រៅនៃរថយន្ត**៖ ព៌ណ៌ឡានទាំងមូលស្ថិតនៅក្នុងសភាពល្អ, សំបកកង់រថយន្តនៅអាចប្រើបានជាធម្មតា, ចំណែកឯគ្រឿងខាងក្នុងរថយន្តដូចជា ម៉ាញ៉េរថយន្ត, ពូកឡាន ជាអាទិ៍ ស្ថិតនៅក្នុងសភាពល្អអាចប្រើប្រាស់បានដោយពុំបាច់កែច្នៃអ្វីឡើយ ។ ជារួមរថយន្តនេះស្ថិតនៅក្នុងសភាពល្អ ដែលប្រើប្រាស់បានជាធម្មតា។
- **ស្ថានភាពគ្រឿងម៉ាស៊ីននៃរថយន្ត**៖ ម៉ាស៊ីនត្រជាក់រថយន្តនេះមិនដំណើរឡើយ ដែលត្រូវឲ្យផ្លាស់ប្តូរដាក់ថ្មី។ ក្រៅនេះទៀត គ្រឿងម៉ាស៊ីនរថយន្តនេះមិនមានខូចខាត ឬត្រូវជួសជុលអ្វីឡើយ ។
- **ឯកសារពាក់ព័ន្ធនឹងរថយន្ត**៖ រថយន្តនេះមានឯកសារច្បាប់ដើមនៃប័ណ្ណសំគាល់ម្ចាស់យានយន្តឡើយ ហើយរថយន្តនេះមិនទាន់បានបង់ពន្ធផ្លូវសម្រាប់ឆ្នាំ ២០១៨ ឡើយ។
- **តម្លៃដែលប៉ាន់ប្រមាណសម្រាប់ទីផ្សារ**៖ រថយន្តនេះ អាចត្រូវលក់លើទីផ្សារបានក្នុងតម្លៃប្រមាណ ៩.០០០ (ប្រាំបួនពាន់) ដុល្លារអាមេរិក។
- **តម្លៃដែលប៉ាន់ប្រមាណសម្រាប់ការលក់ដោយបង្ខំ**៖ រថយន្តនេះ អាចត្រូវលក់លើទីផ្សារបានក្នុងតម្លៃប្រមាណ ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកអាជ្ញាសាលា** មេត្តាពិនិត្យ និងប្រាបជាវបាយការណ៍ដោយក្ដីអនុគ្រោះ។

សូម **លោកអាជ្ញាសាលា** មេត្តាទទួលនូវការគោរពអំពីខ្ញុំបាទ។

ថ្ងៃច័ន្ទ ១៣កើត ខែបឋមាសាធ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨

**អ្នកវាយតម្លៃ**

**រស់ សុភក្រ**

ឧបសម្ព័ន្ធទី១១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
ចូល
លេខ៖ ០៣០
ថ្ងៃខែឆ្នាំ៖ ២៥ ឧសភា ២០១៨
ម៉ោង៖ ១០ : ៣៥ នាទីព្រឹក

**របាយការណ៍ស្តីពីលទ្ធផលនៃការវាយតម្លៃ**

ខ្ញុំបាទឈ្មោះ **លី បូរី** ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ មានមុខរបរជាអ្នកគ្រឿងសង្ហារឹម មានអាសយដ្ឋានផ្ទះលេខ ៤៤៤ ផ្លូវលេខ ៣៣៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

**សូមគោរពជូន**

**លោក ចៅក្រម តេជៈ អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ សុំរាយការណ៍អំពីលទ្ធផលនៃការវាយតម្លៃលើសាឡុងឈើឈុតធំ ចំនួន ០១ឈុត ។

**យោង** ៖ -សំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ ។

-សេចក្តីសម្រេចស្តីពីការជ្រើសតាំងអ្នកវាយតម្លៃនិងបង្គាប់ឱ្យវាយតម្លៃចលនវត្ថុ លេខ ១១១ សមអ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ របស់អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **លោកអាជ្ញាសាលា** ឱ្យបានជ្រាបថា៖ បន្ទាប់ពីបានពិនិត្យយ៉ាងល្អិតល្អន់លើសាឡុងឈើឈុតធំ ចំនួន ០១ ឈុត ខ្ញុំបាទអាចបញ្ជាក់បានថា សាឡុងឈើនេះត្រូវធ្វើឡើងដោយឈើនាងនួន ដែលជាប្រភេទឈើប្រណិត ដែលអាចលក់នៅលើទីផ្សារបានក្នុងតម្លៃ ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ហើយបើដាក់លក់ដោយបង្ខំវិញ សាឡុងនេះអាចដាក់លក់ក្នុងតម្លៃអប្បបរមា ចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លារអាមេរិក។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកអាជ្ញាសាលា** មេត្តាពិនិត្យ និងប្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ។

សូម **លោកអាជ្ញាសាលា** មេត្តាទទួលនូវការគោរពអំពីខ្ញុំបាទ។

ថ្ងៃច័ន្ទ ១៣កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨
**អ្នកវាយតម្លៃ**

**លី បូរី**

ឧបសម្ព័ន្ធទី១២

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

ចូល | លេខ៖ ០៣១ | ថ្ងៃខែឆ្នាំ៖ ២៥.ឧសភា.២០១៨ | ម៉ោង ១០ : ៣៩ នាទីព្រឹក

**របាយការណ៍ស្តីពីលទ្ធផលនៃការវាយតម្លៃចលនវត្ថុ**

ខ្ញុំបាទឈ្មោះ **មាស ពន្លឺ** ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ មានមុខរបរជាអ្នកលក់គ្រឿងអលង្ការ មានអាសយដ្ឋានផ្ទះលេខ ៥៥៥ ផ្លូវលេខ ៤៤៤ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**សូមគោរពជូន**

**លោក ជ័យ តេជៈ អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ សំណើសុំរបាយការណ៍អំពីលទ្ធផលនៃការវាយតម្លៃលើខ្សែក (លោហៈធាតុព័ណ៌មាស) ចំនួន ០១ ខ្សែ និងនាឡិកាដៃម៉ាក Rolex ចំនួន ០១ ខ្សែ ។

**យោង** ៖ -សំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨

-សេចក្តីសម្រេចស្តីពីការជ្រើសតាំងអ្នកវាយតម្លៃនិងបង្គាប់ឲ្យវាយតម្លៃចលនវត្ថុ លេខ ១១១ សមអ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ របស់អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **លោកអាជ្ញាសាលា** ឲ្យបានជ្រាបថា៖ បន្ទាប់ពីបានពិនិត្យយ៉ាងល្អិតល្អន់លើខ្សែក (លោហៈធាតុព័ណ៌មាស) ចំនួន ០១ ខ្សែ និងនាឡិកាដៃម៉ាក Rolex ចំនួន ០១ ខ្សែ រួចមក ខ្ញុំបាទអាចបញ្ជាក់បានដូចតទៅ៖

-ចំពោះខ្សែក (លោហៈធាតុព័ណ៌មាស) ចំនួន ០១ ខ្សែ៖ ខ្សែ ក នេះ គឺជាខ្សែ ក មាសសុទ្ធ ដែលមានទម្ងន់ ១ ដំឡឹង ហើយអាចលក់លើទីផ្សារបានក្នុងតម្លៃ ១.០០០ (មួយពាន់) ដុល្លារអាមេរិក ហើយបើដាក់លក់ឡាយឡុងដោយបង្ខំ អាចលក់បានក្នុងតម្លៃ ៧០០ (ប្រាំពីររយ ដុល្លារអាមេរិក) ។

-ចំពោះនាឡិកាដៃម៉ាក Rolex ចំនួន ០១ ខ្សែ៖ នាឡិកានេះ ពុំមែនជាផលិតដើមម៉ាក Rolex ទេ ដែលហេតុដូចនេះនាឡិកានេះមិនតម្លៃលក់លើទីផ្សារឡើយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកអគ្គចៅក្រម** មេត្តាពិនិត្យ និង ប្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ។

សូម **លោកអគ្គចៅក្រម** មេត្តាទទួលនូវការគោរពអំពីខ្ញុំបាទ។

ថ្ងៃច័ន្ទ ១៣កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨

**អ្នកវាយតម្លៃ**

**រស់ សុភក្រ្ត**

ឧបសម្ព័ន្ធទី១៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ៖ ១១២ សមអ **សេចក្តីសម្រេចស្តីពីលុបចោលការរឹបអូសចលនវត្ថុ**

**យើង ជ័យ តេជៈ អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ**

- បានឃើញ មាត្រា៣៩៣ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញ សំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨
- បានឃើញ កំណត់ហេតុស្តីពីការរឹបអូសចលនវត្ថុ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០១៨
- បានឃើញ សេចក្តីសម្រេចស្តីពីការជ្រើសតាំងអ្នកវាយតម្លៃនិងបង្គាប់ឲ្យវាយតម្លៃ ចលនវត្ថុលេខ ១១១ សមអ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ របស់អាជ្ញាសាលា សាលាដំបូងរាជធានីភ្នំពេញ
- បានឃើញ របាយការណ៍ស្តីពីលទ្ធផលវាយតម្លៃចលនវត្ថុ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០១៨ របស់អ្នកវាយតម្លៃឈ្មោះ **មាស ពន្លឺ**។

**សំអាងហេតុ**

១.- នាឡិកាដៃម៉ាក Rolex ចំនួន ០១ ខ្សែ ត្រូវបានអាជ្ញាសាលារឹបអូសដើម្បីប្តូរជាប្រាក់មកសិទ្ធិលើបំណុលចំនួន ២០,០០០USD តាមអំណាចសាលក្រមរដ្ឋប្បវេណីលេខ ៩៧ “ក” ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដូចមានបញ្ជាក់នៅក្នុងកំណត់ហេតុស្តីពីការរឹបអូសចលនវត្ថុ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨។ នាឡិកានេះត្រូវបានវាយតម្លៃដោយលោក **មាស ពន្លឺ** តាមសេចក្តីសម្រេចស្តីពីការជ្រើសតាំងអ្នកវាយតម្លៃនិងបង្គាប់ឲ្យវាយតម្លៃចលនវត្ថុលេខ ១១១ សមអ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ របស់អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ។

២.-តាមរបាយការណ៍ស្តីពីលទ្ធផលនៃការវាយតម្លៃចលនវត្ថុ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០១៨ របស់អ្នកវាយតម្លៃឈ្មោះ **មាស ពន្លឺ** បញ្ជាក់ថា នាឡិកាដៃម៉ាក Rolex ចំនួន ០១ ខ្សែ ពុំមែនជាផលិតដើមម៉ាក Rolex ទេ ដែលហេតុដូចនេះនាឡិកានេះមិនតម្លៃលក់លើទីផ្សារឡើយ។ ករណីនេះអាជ្ញាសាលាប៉ាន់ប្រមាណឃើញថា នាឡិកានេះមិនអាចលក់បានឡើយ គប្បីលុបចោលនូវការរឹបអូសលើនាឡិកានេះតាមបញ្ញត្តិនៃមាត្រា ៣៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**សេចក្តីសម្រេចបញ្ចប់**

១.- លុបចោលការរឹបអូសនាឡិកាដៃម៉ាក Rolex ចំនួន ០១ ខ្សែ ដែលត្រូវបានរឹបអូសដូចមានបញ្ជាក់នៅក្នុងកំណត់ហេតុស្តីពីការរឹបអូសចលនវត្ថុ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨ របស់អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ។

២.- ប្រគល់នាឡិកាដៃម៉ាក Rolex ចំនួន ០១ ខ្សែ ទៅឲ្យកូនបំណុលនៃការអនុវត្តឈ្មោះ ពុំ មេសា វិញ។

ថ្ងៃព្រហស្បតិ៍ ១រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨

**អាជ្ញាសាលា**

**ជ័យ តេជៈ**

ឧបសម្ព័ន្ធទី១៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ៖.....១១៣ ..... សមអ
ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨

**សេចក្តីសម្រេច**

**កំណត់តម្លៃលក់ចលនទ្រព្យមហាបូរមា**

យើង **ជ័យ តេជ:** អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ មាត្រា៣៩៥ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញ សំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨
- បានឃើញ កំណត់ហេតុស្តីពីការរឹបអូសចលនវត្ថុ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨
- បានឃើញ សេចក្តីសម្រេចស្តីពីការជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឲ្យវាយតម្លៃចលនវត្ថុ លេខ ១១១ សមអ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ របស់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ
- បានឃើញ របាយការណ៍ស្តីពីលទ្ធផលវាយតម្លៃរថយន្ត ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ របស់អ្នកវាយតម្លៃឈ្មោះ **វស់ សុភក្រ**។
- បានឃើញ របាយការណ៍ស្តីពីលទ្ធផលវាយតម្លៃ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ របស់អ្នកវាយតម្លៃឈ្មោះ **លី បូរី**។
- បានឃើញ របាយការណ៍ស្តីពីលទ្ធផលវាយតម្លៃ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ របស់អ្នកវាយតម្លៃឈ្មោះ **មាស ពន្លឺ**។

**សំអាងហេតុ**

១.- តាមរបាយការណ៍ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ របស់អ្នកវាយតម្លៃឈ្មោះ **វស់ សុភក្រ** ដែលបានផ្តល់មកអាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ដោយបានបញ្ជាក់ថា តម្លៃដែលប៉ាន់ប្រមាណសម្រាប់ការលក់ដោយបង្ខំ លើរថយន្តម៉ាក Lexus RX 350 ដែលមានផ្លាកលេខ

2XX-2244 មានតម្លៃប្រមាណ ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក និង លើរថយន្តម៉ាក Lexus RX 300 មានផ្លាកលេខ 2XX-2213 មានតម្លៃប្រមាណ ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក។

២.- តាមរបាយការណ៍ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ របស់អ្នកវាយតម្លៃឈ្មោះ **លី បូរី** ដែលបានផ្តល់មកអាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ដោយបានបញ្ជាក់ថា សាឡុងឈើឈុតធំ ចំនួន ០១ ឈុត ត្រូវធ្វើឡើងដោយឈើនាងនួន ជាប្រភេទឈើប្រណិត ដែលអាចលក់នៅលើទីផ្សារបានក្នុងតម្លៃ ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ហើយបើដាក់លក់ដោយបង្ខំវិញ សាឡុងនេះអាចដាក់លក់ក្នុងតម្លៃអប្បបរមា ចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លារអាមេរិក។

៣.- តាមរបាយការណ៍ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ របស់អ្នកវាយតម្លៃឈ្មោះ **មាស ពន្លឺ** ដែលបានផ្តល់មកអាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ដោយបានបញ្ជាក់ថា ខ្សែក (លោហៈធាតុព័ណ៌មាស) ចំនួន ០១ខ្សែ៖ ខ្សែ ក នេះ គឺជាខ្សែ ក មាសសុទ្ធ ដែលមានទម្ងន់ ១ដំឡឹង ហើយអាចលក់លើទីផ្សារបានក្នុងតម្លៃ ១.០០០ (មួយពាន់) ដុល្លារអាមេរិក ហើយបើដាក់លក់ឡាយឡុងដោយបង្ខំ អាចលក់បានក្នុងតម្លៃ ៧០០ (ប្រាំពីររយ) ដុល្លារអាមេរិក។

**ហេតុដូច្នេះសម្រេច**

កំណត់នូវតម្លៃលក់អប្បបរមានូវចលនវត្ថុដូចខាងក្រោម៖

១.- ចលនវត្ថុជារថយន្តម៉ាក Lexus RX 350 មានផ្លាកលេខ 2XX-2244 ត្រូវដាក់លក់ដោយបង្ខំក្នុងតម្លៃលក់អប្បបរមាចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក ។

២.- ចលនវត្ថុជារថយន្តម៉ាក Lexus RX 300 មានផ្លាកលេខ 2XX-2213 ត្រូវដាក់លក់ដោយបង្ខំក្នុងតម្លៃលក់អប្បបរមាចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក។

៣.- ចលចនវត្ថុជាសាឡុងឈើឈុតធំ ចំនួន ០១ ឈុត ត្រូវដាក់លក់ដោយបង្ខំក្នុងតម្លៃលក់អប្បបរមា ចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លារអាមេរិក។

៤.- ចលនវត្ថុជាខ្សែ ក មាសសុទ្ធ មានទម្ងន់ ១ ដំឡឹង ត្រូវដាក់លក់ដោយបង្ខំក្នុងតម្លៃលក់អប្បបរមាចំនួន ៧០០ (ប្រាំពីររយ) ដុល្លារអាមេរិក ។

ថ្ងៃព្រហស្បត្តិ៍ ១រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨

**អាជ្ញាសាលា**

**ជ័យ តេជះ**

ឧបសម្ព័ន្ធទី១៥

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ៖.....១១៧.....សមអ

ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨

**សេចក្ដីជូនដំណឹងជាសាធារណៈ**

**អំពីការលក់ឡាយឡុងចលនវត្ថុ**

យើង **ជ័យ តេជ:** អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ មាត្រា៣៩៥ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញ សំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨
- បានឃើញ កំណត់ហេតុស្ដីពីការរឹបអូសចលនវត្ថុ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០១៨
- បានឃើញ សេចក្ដីសម្រេចកំណត់តម្លៃលក់អប្បបរមា លេខ ១១៣ សអម ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៨
- បានឃើញ របាយការណ៍ស្ដីពីលទ្ធផលវាយតម្លៃរថយន្ត ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០១៨ របស់អ្នកវាយតម្លៃឈ្មោះ **រស់ សុភក្រ**។
- បានឃើញ របាយការណ៍ស្ដីពីលទ្ធផលវាយតម្លៃ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ របស់អ្នកវាយតម្លៃឈ្មោះ **លី បូរី**។
- បានឃើញ របាយការណ៍ស្ដីពីលទ្ធផលវាយតម្លៃ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ របស់អ្នកវាយតម្លៃឈ្មោះ **មាស ពន្លឺ**។

សូមជូនដំណឹងជាសាធារណៈអំពីការលក់ឡាយឡុងចលនវត្ថុ ដូចខាងក្រោម៖

**១.- ព័ត៌មានអំពីចលនវត្ថុដែលត្រូវដាក់លក់ដោយបង្ខំ**

ចលនវត្ថុដែលត្រូវបានដាក់លក់ដោយបង្ខំ រួមមាន៖

ក.- **ចំពោះរថយន្តម៉ាក Lexus RX 350 មានផ្លាកលេខ 2XX-2244 ផលិតនៅឆ្នាំ ២០១០**

- **ស្ថានភាពខាងក្រៅនៃរថយន្ត៖** ព័ណ៌ឡានទាំងមូលស្ថិតនៅក្នុងសភាពល្អ ប៉ុន្តែកាងខាងមុខរថយន្តតម្រូវឲ្យមានការបាញ់ថ្នាំជាថ្មី, សំបកកង់រថយន្តនៅអាចប្រើបានជាធម្មតា, ចំណែកឯគ្រឿងខាងក្នុងរថយន្តដូចជា ម៉ាញ៉េរថយន្ត, ពូកឡានជាអាទិ៍ ស្ថិតនៅក្នុងសភាពល្អអាចប្រើប្រាស់បានដោយពុំបាច់កែច្នៃអ្វីឡើយ ។ ជារួមរថយន្តនេះស្ថិតនៅក្នុងសភាពល្អ ដែលប្រើប្រាស់បានជាធម្មតា។
- **ស្ថានភាពគ្រឿងម៉ាស៊ីននៃរថយន្ត៖** គ្រឿងម៉ាស៊ីនរថយន្តនេះមិនមានខូចខាត ឬត្រូវជួសជុលអ្វីឡើយ ពោលគឺស្ថិតនៅក្នុងសភាពល្អ។
- **ឯកសារពាក់ព័ន្ធនឹងរថយន្ត៖** រថយន្តនេះមិនមានឯកសារច្បាប់ដើមនៃប័ណ្ណសំគាល់ម្ចាស់យានយន្តឡើយ ហើយរថយន្តនេះមិនទាន់បានបង់ពន្ធផ្លូវសម្រាប់ឆ្នាំ ២០១៧ ឡើយ។
- តម្លៃលក់អប្បបរមា៖ ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក។

**ខ.- ចំពោះរថយន្តម៉ាក Lexus RX 300 ផ្លាកលេខ 2XX-2213 ផលិតនៅឆ្នាំ២០០២**

- **ស្ថានភាពខាងក្រៅនៃរថយន្ត៖** ព័ណ៌ឡានទាំងមូលស្ថិតនៅក្នុងសភាពល្អ, សំបកកង់រថយន្តនៅអាចប្រើបានជាធម្មតា, ចំណែកឯគ្រឿងខាងក្នុងរថយន្តដូចជា ម៉ាញ៉េរថយន្ត, ពូកឡាន ជាអាទិ៍ ស្ថិតនៅក្នុងសភាពល្អអាចប្រើប្រាស់បានដោយពុំបាច់កែច្នៃអ្វីឡើយ។ ជារួមរថយន្តនេះស្ថិតនៅក្នុងសភាពល្អ ដែលប្រើប្រាស់បានជាធម្មតា។
- **ស្ថានភាពគ្រឿងម៉ាស៊ីននៃរថយន្ត** ៖ ម៉ាស៊ីនត្រជាក់រថយន្តនេះមិនដំណើរឡើយ ដែលត្រូវឲ្យផ្លាស់ប្តូរដាក់ថ្មី។ ក្រៅនេះទៀត គ្រឿងម៉ាស៊ីនរថយន្តនេះមិនមានខូចខាត ឬត្រូវជួសជុលអ្វីឡើយ ។
- **ឯកសារពាក់ព័ន្ធនឹងរថយន្ត៖** រថយន្តនេះមានឯកសារច្បាប់ដើមនៃប័ណ្ណសំគាល់ម្ចាស់យានយន្តឡើយ ហើយ រថយន្តនេះមិនទាន់បានបង់ពន្ធផ្លូវសម្រាប់ឆ្នាំ ២០១៨ ឡើយ។
- តម្លៃលក់អប្បបរមា៖ ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក។

**គ.- ចំពោះសាឡុងឈើឈុតធំ**

- សាឡុងឈើឈុតធំ ចំនួន ០១ឈុត ត្រូវធ្វើឡើងដោយឈើនាងនួន ជាប្រភេទឈើប្រណិត ។
- តម្លៃលក់អប្បបរមា៖ ៨.០០០ (ប្រាំបីពាន់) ដុល្លារអាមេរិក។

**ឃ.- ចំពោះខ្សែក (លោហៈធាតុព័ណ៌មាស) ចំនួន ០១ ខ្សែ**

- ខ្សែ ក នេះ គឺជាខ្សែ ក មាសសុទ្ធ ដែលមានទម្ងន់ ១ ដំឡឹង ។
- តម្លៃលក់អប្បបរមា៖ ៧០០ (ប្រាំពីររយ) ដុល្លារអាមេរិក។

## ២.- តម្លៃលក់អប្បបរមា និងចំនួនទឹកប្រាក់ធានាលើសំណើទិញ

| ល.រ | ចលនវត្ថុ | តម្លៃលក់អប្បបរមា | ប្រាក់ធានាលើសំណើទិញ |
|---|---|---|---|
| ១ | Lexus RX 350 | ៣០.០០០ $ | ៣.០០០$ |
| ២ | Lexus RX 330 | ៧.០០០$ | ៧០០$ |
| ៣ | សាឡុងឈើ | ៨.០០០$ | ៨០០$ |
| ៤ | ខ្សែ ក មាស | ៧០០$ | ៧០$ |
| សរុប | | ៤៥.៧០០$ | ៤.៥៧០$ |

## ៣.- វិធីលក់ដោយបង្ខំនូវចលនវត្ថុ

ចលនវត្ថុខាងលើ ត្រូវបានដាក់លក់ដោយបង្ខំ តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ តាមមាត្រា ៣៩៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ៤.- កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងពាក់ព័ន្ធនឹងការលក់ដោយបង្ខំ

**ក.- កាលបរិច្ឆេទនៃការដាក់ពាក្យសុំចូលរួមដេញថ្លៃ**

- ចាប់ទទួលពាក្យសុំចូលរួមដេញថ្លៃ ចាប់ពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ ដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ ត្រឹមវេលាម៉ោង ១១ : ០០ នាទីព្រឹក។

**ខ.- កាលបរិច្ឆេទ និង ទីកន្លែងនៃការលក់ឡាយឡុង**

- ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង០៩:០០ នាទីព្រឹក បន្ទប់អាជ្ញាសាលា។

## ៥.- លក្ខខណ្ឌដើម្បីចូលរួមដេញថ្លៃ

បុគ្គលដែលមានបំណងចូលរួមដេញថ្លៃទិញយកចលនវត្ថុខាងលើ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវដាក់ពាក្យសុំចូលរួមដេញថ្លៃតាមការកំណត់ក្នុងចំណុចទី៣ (ក) ខាងលើ។

- ពាក្យសុំត្រូវភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណថតចម្លងដែលបញ្ជាក់ត្រឹមត្រូវតាមច្បាប់ ឬ ឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀត។
- ត្រូវបង់ប្រាក់ធានាលើសំណើទិញ ចំនួន មួយភាគដប់ នៃតម្លៃលក់អប្បបរមា។

**៦.- ព័ត៌មានចាំបាច់ផ្សេងទៀតជុំវិញការលក់ដោយបង្ខំ**

- បុគ្គលដែលបានដាក់ពាក្យសុំចូលរួមដេញថ្លៃរួចហើយ ត្រូវមកបង្ហាញខ្លួនតាមកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃការដេញថ្លៃដូចដែលបានកំណត់ក្នុងចំណុចទី៣ ខាងលើ។
- អតិថិជន មិនអាចធ្វើការដេញថ្លៃនៅក្រោមតម្លៃលក់អប្បបរមាបានឡើយ។
- ក្នុងករណីអ្នកធ្វើសំណើទិញក្នុងតម្លៃអតិបរមា មានគ្នាច្រើននាក់ លើតម្លៃដូចគ្នា អាជ្ញាសាលាមានសិទ្ធិឱ្យអ្នកដែលបានធ្វើសំណើទិញក្នុងតម្លៃអតិបរមាទាំងនោះ ធ្វើការដេញថ្លៃម្តងទៀត ដោយមិនអនុញ្ញាតឲ្យដេញថ្លៃទាបជាងតម្លៃដែលខ្លួនបានដេញមុនឡើយ ឬ អាជ្ញាសាលាអាចឲ្យអ្នកដែលបានធ្វើសំណើទិញក្នុងតម្លៃអតិបរមានោះធ្វើការចាប់ឆ្នោត។
- អ្នកដែលបានដេញថ្លៃបានហើយ បុគ្គលនោះត្រូវបង់ប្រាក់បង្គ្រប់ថ្លៃលក់ភ្លាមៗ ប៉ុន្តែក្នុងករណីដែលបុគ្គលនោះមិនបានបង់ប្រាក់ភ្លាមៗទេ អាជ្ញាសាលាអាចលុបចោលការលក់នោះ ហើយត្រូវកំណត់កាលបរិច្ឆេទនៃការដេញថ្លៃម្តងទៀត ដោយមិនអនុញ្ញាតឲ្យបុគ្គលដែលបានដេញថ្លៃបាននោះ ចូលរួមរួមដេញថ្លៃម្តងទៀតឡើយ ចំណែកឯប្រាក់ធានាលើសំណើទិញដែលបានបង់រួច ត្រូវទុកជាប្រាក់សម្រាប់ចែកចំណែក។
- នៅកាលបរិច្ឆេទនៃការលក់ឡាយឡុង បុគ្គលដែលមានសិទ្ធិចូលរួមដេញថ្លៃ ត្រូវរក្សាភាពស្ងៀមស្ងាត់ កុំបង្កជាសម្លេងរំខាន ដល់អ្នកដទៃក្នុងការធ្វើសំណើទិញ ឬ ឃុបឃិតគ្នាដើម្បីបញ្ចុះតម្លៃលក់ដោយមិនត្រឹមត្រូវ។

អាស្រ័យហេតុដូចនេះ សូម សាធារណៈជន ទាំងអស់ជ្រាបជាព័ត៌មាន។

ថ្ងៃច័ន្ទ ៥រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨

**អាជ្ញាសាលា**

**ឧបសម្ព័ន្ធទី១៦**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

| **សាលាដំបូងរាជធានីភ្នំពេញ** | |
|---|---|
| **ចូល** | លេខ៖ ......០៣៧...... |
| | ថ្ងៃខែឆ្នាំ៖០៦ មិថុនា ២០១៨ |
| | ម៉ោង៖០៩ : ៤៥ នាទីព្រឹក |

**ពាក្យសុំចូលរួមដេញថ្លៃ**

ខ្ញុំបាទឈ្មោះ **ទី កក្កដា** អាយុ ២៧ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០៦១៣៨៨000 មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ X2 ផ្លូវលេខ T555 ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

**សូមគោរពជូន**

**លោក ជ័យ តេជៈ អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ សំណើសុំចូលរួមដេញថ្លៃទិញចលនវត្ថុ ដែលនឹងត្រូវលក់ឡាយឡុងដោយស្រោមសំបុត្រដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង០៩:00 នាទីព្រឹក ខាងមុខនេះ ។

**យោង** ៖ សេចក្តីជូនដំណឹងជាសាធារណៈលេខ ១១៧ សមអ ចុះថ្ងៃទី០៤.០៦.២០១៨ របស់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ស្តីពីការលក់ឡាយឡុងចលនវត្ថុ។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **លោកអាជ្ញាសាលា** ឱ្យជ្រាបថា៖ បន្ទាប់ពីខ្ញុំបាទបានទទួលព័ត៌មានអំពីការលក់ឡាយឡុងចលនវត្ថុដូចមាន ក្នុងសេចក្តីជូនដំណឹងជាសាធារណៈ លេខ ១១៧ សមអ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ របស់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ខ្ញុំបាទមានបំណងទិញយកចលនវត្ថុ ដែលនឹងត្រូវលក់ឡាយឡុងដោយស្រោមសំបុត្រ នឹងប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង០៩និង00 នាទីព្រឹក ខាងមុខនេះ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកអាជ្ញាសាលា** មេត្តាពិនិត្យ និងអនុញ្ញាតឱ្យខ្ញុំបាទ បានចូលរួមដេញថ្លៃនៅកាលបរិច្ឆេទខាងលើដោយក្តីអនុគ្រោះ។

សូម **លោកអាជ្ញាសាលា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៨

**អ្នកដាក់ពាក្យសុំ**

**ឧបសម្ព័ន្ធទី១៧**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

# កំណត់ហេតុទទួលប្រាក់ធានាលើសំណើទិញ

យើង **ជ័យ តេជះ** អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក **សុខ ខចុល** ជាអ្នកធ្វើកំណត់ហេតុ

**យោង** ៖ - សេចក្តីជូនដំណឹងជាសាធារណៈលេខ ១១៧ សមអ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ របស់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ស្តីពីការលក់ឡាយឡុងចលនវត្ថុ។

- ពាក្យសុំចូលរួមដេញថ្លៃ ចុះថ្ងៃទី០៥ខែមិថុនា ឆ្នាំ២០១៨ របស់ឈ្មោះ ទី កក្កដា។

នាថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែមិថុនា ឆ្នាំ ២០១៨ វេលាម៉ោង ដប់បួន និងសាមសិបនាទី រសៀល នៅបន្ទប់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ជាន់ទី២

បានទទួលប្រាក់ចំនួន ៤.៥៧០ (បួនប្រាំរយចិតសិប) ដុល្លារអាមេរិក ដែលជាប្រាក់ធានាលើសំណើចលនវត្ថុ តាមសេចក្តីជូនដំណឹងជាសាធារណៈលេខ ១១៧ សមអ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ ២០១៨ របស់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ស្តីពីការលក់ឡាយឡុងចលនវត្ថុ

ពីឈ្មោះអ្នកទិញឈ្មោះ **ទី កក្កដា** អាយុ ២៧ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០៦១៣៨៨០០០ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ X2 ផ្លូវលេខ T555 ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

បញ្ចប់កំណត់ហេតុនៅវេលាម៉ោង ដប់បួន និងហាសិបនាទី រសៀល នាថ្ងៃខែឆ្នាំដដែល ដោយបានអានឱ្យអ្នកចូលរួមទាំងអស់បានស្តាប់ ព្រមទាំងឯកភាពផ្តិតមេដៃស្តាំទុកជាភស្តុតាង។

| **អាជ្ញាសាលា** | **អ្នកប្រគល់ប្រាក់** | **អ្នកធ្វើកំណត់ហេតុ** |
|---|---|---|
| **ជ័យ តេជះ** | **ទី កក្កដា** | **សុខ ខចុល** |

ឧបសម្ព័ន្ធទី១៨

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

# កំណត់ហេតុលក់ឡាយឡុងដោយស្រោមសំបុត្រ

យើង **ជ័យ តេជៈ** អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក **សុខ ខចុល** ជាអ្នកធ្វើកំណត់ហេតុ

បានដឹកនាំនីតិវិធីលក់ឡាយឡុងចលនវត្ថុ តាមមាត្រា ៣៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី មានដំណើរការដូចតទៅ៖

**ក.- សញ្ញាណនៃរឿងក្តី**

- សំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ ដែលមានម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ចាន់ រក្សា និង កូនបំណុលនៃការអនុវត្តឈ្មោះ ពុំ មេសា ដែលមានកម្មវត្ថុ៖ លក់ដោយបង្ខំនូវចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត។

**ខ.- សញ្ញាណនៃចលនវត្ថុ**

ចលនវត្ថុដែលត្រូវដាក់លក់ដោយបង្ខំរួមមាន៖

- រថយន្តម៉ាក Lexus RX 350 មានផ្លាកលេខ 2XX-2244 ត្រូវដាក់លក់ដោយបង្ខំក្នុងតម្លៃលក់អប្បបរមាចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក ។
- រថយន្តម៉ាក Lexus RX 300 មានផ្លាកលេខ 2XX-2213 ត្រូវដាក់លក់ដោយបង្ខំក្នុងតម្លៃលក់អប្បបរមាចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក។
- សាឡុងឈើឈុតធំ ចំនួន ០១ ឈុត ត្រូវដាក់លក់ដោយបង្ខំក្នុងតម្លៃលក់អប្បបរមា ចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លារអាមេរិក។
- ខ្សែ ក មាសសុទ្ធ មានទម្ងន់ ១ ដំឡឹង ត្រូវដាក់លក់ដោយបង្ខំក្នុងតម្លៃលក់អប្បបរមាចំនួន ៧០០ (ប្រាំពីររយ) ដុល្លារអាមេរិក ។

**គ.- កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ**

- កាលបរិច្ឆេទ និងពេលវេលា ៖ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ៩:00 នាទីព្រឹក
- ទីកន្លែងលក់ ៖ បន្ទប់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ

**ឃ.- ខ្លឹមសារនៃសកម្មភាពដែលបានចាត់ចែង**

នៅកាលបរិច្ឆេទ និងពេលវេលានៃការលក់ឡាយឡុង យើងឃើញមានវត្តមានឈ្មោះ **ទី កក្កដា** អាយុ ២៧ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០៦១៣៨៨000 មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ X2 ផ្លូវលេខ T555 ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ និង ឈ្មោះ **សុខ បូរី** អាយុ ២៩ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០៦១000000 មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ T2 ផ្លូវលេខ X555 ភូមិ១៣ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលបានដាក់ពាក្យសុំចូលរួមដេញថ្លៃទិញចលនវត្ថុខាងលើ។

បន្ទាប់មកយើងបានធ្វើការផ្ទៀងផ្ទាត់លើពាក្យសុំចូលរួមដេញថ្លៃ ឯកសារពាក់ព័ន្ធ និងវត្តមានរបស់អ្នកចូលរួមទាំងអស់ គឺពិនិត្យឃើញថា អ្នកចូលរួមដេញថ្លៃឈ្មោះ **ទី កក្កដា** និងឈ្មោះ **សុខ បូរី** មានលក្ខណៈសម្បត្តិតាមច្បាប់គ្រប់គ្រាន់ដែលមានសិទ្ធិធ្វើសំណើទិញអចលនវត្ថុខាងលើនេះបាន តាមបញ្ញត្តិនៃមាត្រា ៣៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

បន្ទាប់មកយើងបាន ពន្យល់ពីល័ក្ខខ័ណ្ឌផ្សេងៗនៃការលក់ឡាយឡុង ជូនដល់អ្នកចូលរួមដេញថ្លៃឈ្មោះ **ទី កក្កដា** និងឈ្មោះ **សុខ បូរី** រួចហើយ យើងបានប្រគល់ស្រោមសំបុត្រជូនដល់ពួកគាត់ដើម្បីធ្វើសំណើទិញអចលនវត្ថុខាងលើ។

បន្ទាប់ពីទទួលបានស្រោមសំបុត្របិទជិតរួច យើងបានបើកស្រោមសំបុត្រហើយពិនិត្យឃើញថា៖

| ចលនវត្ថុ | តម្លៃលក់អប្បបរមា | សំណើទិញរបស់ឈ្មោះ ទី កក្កដា | សំណើទិញរបស់ឈ្មោះ សុខ បូរី |
|---|---|---|---|
| Lexus RX 350 | ៣០.000 $ | ៣១.000$ | ៣២.000$ |
| Lexus RX 330 | ៧.000$ | ១០.000$ | ៨៥.00$ |
| សាឡុងឈើ | ៨.000$ | ៨.១00$ | ៩.000$ |
| ខ្សែ ក មាស | ៧00$ | ៧៥0$ | ៧00$ |

**ហេតុដូច្នេះ** ជាលទ្ធផល យើងសម្រេចកំណត់យក៖

- ឈ្មោះ **ទី កក្កដា** អាយុ ២៧ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០៦១៣៨៨០០០ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ X2 ផ្លូវលេខ T555 ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ គឺជាអ្នកដេញថ្លៃបានលើចលនវត្ថុដែលបានដាក់លក់ឡាយឡុង រួមមាន រថយន្តម៉ាក Lexus RX 300 មានផ្លាកលេខ 2XX-2213 ក្នុងតម្លៃអតិបរមាចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក និង ខ្សែ ក មាសសុទ្ធ មានទម្ងន់ ១ ដំឡឹង ក្នុងតម្លៃអតិបរមាចំនួន ៧៥០ (ប្រាំពីររយហាសិប) ដុល្លារអាមេរិក ។

- ឈ្មោះ **សុខ បូរី** អាយុ ២៩ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០៦១០០០០០០ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ T2 ផ្លូវលេខ X555 ភូមិ ១៣ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ គឺជាអ្នកដេញថ្លៃបានលើចលនវត្ថុដែលបានដាក់លក់ឡាយឡុង រួមមាន៖ រថយន្តម៉ាក Lexus RX 350 មានផ្លាកលេខ 2XX-2244 ក្នុងតម្លៃអតិបរមាចំនួន ៣២.០០០ (បីម៉ឺនពីរពាន់) ដុល្លារអាមេរិក និង សាឡុងឈើឈុតធំ ចំនួន ០១ ឈុត ក្នុងតម្លៃលក់អតិបរមា ចំនួន ៩.០០០ (ប្រាំបួនពាន់) ដុល្លារអាមេរិក។

**ខ.- កាលបរិច្ឆេទនៃការធ្វើ និង ការចាត់ចែងកំណត់ហេតុ**

កំណត់ហេតុនេះត្រូវបានធ្វើឡើងនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ៩ និង០០ នាទីព្រឹក និងបញ្ចប់ នៅវេលាម៉ោង ៩ និង ៣០ នាទី នាថ្ងៃខែឆ្នាំដដែល ហើយយើងបានអានកំណត់ហេតុនេះឲ្យអ្នកចូលរួមបានស្តាប់។

| **អាជ្ញាសាលា** | **អ្នកចូលរួមដេញថ្លៃ** |
|---|---|
| **ជ័យ តេជ:** | ទី កក្កដា      សុខ បូរី |

**ឧបសម្ព័ន្ធទី១៩**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

# កំណត់ហេតុប្រគល់ទទួលប្រាក់បង្គ្រប់ថ្លៃលក់

យើង **ជ័យ តេជៈ** អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក **សុខ ខមុល** ជាអ្នកធ្វើកំណត់ហេតុ

**យោង** ៖ - កំណត់ហេតុលក់ឡាយឡុងដោយស្រោមសំបុត្រ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨

- កំណត់ហេតុទទួលប្រាក់ធានាលើសំណើទិញចលនវត្ថុ ចុះថ្ងៃទី០៦.០៦.២០១៨ ដែលបានទទួលប្រាក់ធានាលើសំណើទិញចំនួន ៤.៥៧០ $ ពីឈ្មោះ ទី កក្កដា។

នាថ្ងៃសុក្រ ៣កើត ខែបឋមសាធ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ប្រាំបួន និងសាមសិបនាទី នៅបន្ទប់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ

បានទទួលប្រាក់ចំនួន ៦.១៨០ (ប្រាំមួយពាន់មួយរយប៉ែតសិប) ដុល្លារអាមេរិក ដែលជាប្រាក់បង្គ្រប់ថ្លៃលក់ចលនវត្ថុដែលដាក់លក់ឡាយឡុង រួមមាន រថយន្តម៉ាក Lexus RX 300 មានផ្លាកលេខ 2XX-2213 និង ខ្សែ ក មាសសុទ្ធ មានទម្ងន់ ១ ដំឡឹង តាមកំណត់ហេតុលក់ឡាយឡុងដោយស្រោមសំបុត្រ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨

ពីអ្នកទិញឈ្មោះ **ទី កក្កដា** អាយុ ២៧ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០៦១៣៨៨០០០ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ X2 ផ្លូវលេខ T555 ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

បញ្ចប់កំណត់ហេតុនៅវេលាម៉ោង ប្រាំបួន និងហាសិបនាទី នាថ្ងៃខែឆ្នាំដដែល ដោយបានអានឱ្យអ្នកចូលរួមទាំងអស់បានស្តាប់ ព្រមទាំងឯកភាពផ្តិតមេដៃស្នាំទុកជាភស្តុតាង។

| អាជ្ញាសាលា | អ្នកប្រគល់ប្រាក់ | អ្នកធ្វើកំណត់ហេតុ |
|---|---|---|
| ជ័យ តេជៈ | ទី កក្កដា | សុខ ខមុល |

ឧបសម្ព័ន្ធទី២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

# កំណត់ហេតុប្រគល់ទទួលប្រាក់បង្គ្រប់ថ្លៃលក់

យើង **ជ័យ តេជៈ** អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ
អមដោយលោក **សុខ ខប៊ុល** ជាអ្នកធ្វើកំណត់ហេតុ

**យោង** ៖ - កំណត់ហេតុលក់ឡាយឡុងដោយស្រោមសំបុត្រ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨
- កំណត់ហេតុទទួលប្រាក់ធានាលើសំណើទិញចលនវត្ថុ ចុះថ្ងៃទី០៦.០៦.២០១៨

នាថ្ងៃសុក្រ ៣កើត ខែបឋមសាធ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ប្រាំបួន និងសាមសិបនាទី នៅបន្ទប់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ

បានទទួលប្រាក់ចំនួន ៣៦.៤៣០ (បីម៉ឺនប្រាំមួយពាន់បួនរយសាមសិប) ដុល្លារអាមេរិក ដែលជាប្រាក់បង្គ្រប់ថ្លៃលក់ចលនវត្ថុដែលដាក់លក់ឡាយឡុង រួមមាន រថយន្តម៉ាក Lexus RX 350 មានផ្លាកលេខ 2XX-2244 និង សាឡុងឈើឈុតធំ ចំនួន ០១ ឈុត តាមកំណត់ហេតុលក់ឡាយឡុងដោយស្រោមសំបុត្រ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨

ពីឈ្មោះ **សុខ បូរី** អាយុ ២៩ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០៦1000000 មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ T2 ផ្លូវលេខ X555 ភូមិ១៣ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

បញ្ចប់កំណត់ហេតុនៅវេលាម៉ោង ប្រាំបួន និងហាសិបនាទី នាថ្ងៃខែឆ្នាំដដែល ដោយបានអានឲ្យអ្នកចូលរួមទាំងអស់បានស្តាប់ ព្រមទាំងឯកភាពផ្តិតមេដៃស្តាំទុកជាភស្តុតាង។

| **អាជ្ញាសាលា** | **អ្នកប្រគល់ប្រាក់** | **អ្នកធ្វើកំណត់ហេតុ** |
|---|---|---|
| **ជ័យ តេជៈ** | សុខ បូរី | **សុខ ខប៊ុល** |

ឧបសម្ព័ន្ធទី២១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# កំណត់ហេតុប្រគល់ទទួលចលនវត្ថុ

យើង **ជ័យ តេជៈ** អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក **សុខ ខេមរុល** ជាអ្នកធ្វើកំណត់ហេតុ

**យោង** ៖ - កំណត់ហេតុលក់ឡាយឡុងដោយស្រោមសំបុត្រ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨

- កំណត់ហេតុទទួលប្រាក់ធានាលើសំណើទិញចលនវត្ថុ ចុះថ្ងៃទី០៦.០៦.២០១៨ ដែលបានទទួលប្រាក់ធានាលើសំណើទិញចំនួន ៤.៥៧០ $ ពីឈ្មោះ ទី កក្កដា
- កំណត់ហេតុទទួលប្រាក់បង្គ្រប់ថ្លៃលក់ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ដែលបានទទួលប្រាក់បង្គ្រប់ថ្លៃលក់ចលនវត្ថុ ចំនួន ៦.១៨០ $ ពីឈ្មោះ ទី កក្កដា។

នាថ្ងៃសុក្រ ៣កើត ខែបឋមសាឍ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ៨ប់ និង៨ប់នាទី នៅបន្ទប់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ជាន់ទី២

ប្រគល់រថយន្តម៉ាក Lexus RX 300 មានផ្លាកលេខ 2XX-2213 និង ខ្សែ ក មាសសុទ្ធ មានទម្ងន់ ១ ដំឡឹង ទៅឱ្យអ្នកទិញឈ្មោះ **ទី កក្កដា** អាយុ ២៧ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០៦១៣៨៨000 មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ X2 ផ្លូវលេខ T555 ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលជាអ្នកដេញថ្លៃបាន។

បញ្ចប់កំណត់ហេតុនៅវេលាម៉ោង ៨ប់ និងសាមសិបនាទី នាថ្ងៃខែឆ្នាំដដែល ដោយបានអានឱ្យអ្នកចូលរួមទាំងអស់បានស្តាប់ ព្រមទាំងឯកភាពផ្តិតមេដៃស្នាំទុកជាភស្តុតាង។

| អាជ្ញាសាលា | អ្នកទទួល | អ្នកធ្វើកំណត់ហេតុ |
|---|---|---|
| ជ័យ តេជៈ | ទី កក្កដា | សុខ ខេមរុល |

ឧបសម្ព័ន្ធទី២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# កំណត់ហេតុប្រគល់ទទួលចលនវត្ថុ

យើង **ជ័យ តេជះ** អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក **សុខ ខបុល** ជាអ្នកធ្វើកំណត់ហេតុ

**យោង** ៖ - កំណត់ហេតុលក់ឡាយឡុងដោយស្រោមសំបុត្រ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨

- កំណត់ហេតុទទួលប្រាក់ធានាលើសំណើទិញចលនវត្ថុ ចុះថ្ងៃទី ០៦.០៦.២០១៨ ដែលបានទទួលប្រាក់ធានាលើសំណើទិញចំនួន ៤.៥៧០ $ ពីឈ្មោះ ទី កក្កដា
- កំណត់ហេតុទទួលប្រាក់បង្គ្រប់ថ្លៃលក់ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ដែលបានទទួលប្រាក់បង្គ្រប់ថ្លៃលក់ចលនវត្ថុ ចំនួន ៣៦.៤៣០ $ ពីឈ្មោះ សុខ បូរី។

នាថ្ងៃសុក្រ ៣កើត ខែបឋមសាឍ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ដប់ និងសាមសិបនាទី នៅបន្ទប់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ជាន់ទី២

ប្រគល់រថយន្តម៉ាក Lexus RX 350 មានផ្លាកលេខ 2XX-2244 និង សាឡុងឈើឈុតធំ ចំនួន ០១ ឈុតទៅឱ្យឈ្មោះ **សុខ បូរី** អាយុ ២៩ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០៦១000000 មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ T2 ផ្លូវលេខ X555 ភូមិ ១៣ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលជាអ្នកដេញថ្លៃបាន។

បញ្ចប់កំណត់ហេតុនៅវេលាម៉ោង ដប់ និងហាសិបនាទី នាថ្ងៃខែឆ្នាំដដែល ដោយបានអានឱ្យអ្នកចូលរួមទាំងអស់បានស្តាប់ ព្រមទាំងឯកភាពផ្តិតមេដៃស្តាំទុកជាភស្តុតាង។

| អាជ្ញាសាលា | អ្នកទទួល | អ្នកធ្វើកំណត់ហេតុ |
|---|---|---|
| **ជ័យ តេជះ** | សុខ បូរី | **សុខ ខបុល** |

ឧបសម្ព័ន្ធទី២៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ៖.....១២០.....សមអ

ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨

# លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិ

## យើង ជ័យ តេជៈ អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ មាត្រា៣៩៥ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញ សំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨
- បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ៩៧ “ក” ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ
- បានឃើញ លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមរដ្ឋប្បវេណី លេខ ៩៨ “ក” វវ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ
- បានឃើញ រូបមន្តអនុវត្ត លេខ ៩៩ “ក” វវ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ
- បានឃើញ កំណត់ហេតុស្តីពីការរឹបអូសចលនវត្ថុ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០១៨
- បានឃើញ លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូសរថយន្តលេខ ១០៦ លខ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ របស់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ កំណត់ហេតុលក់ឡាយឡុងដោយស្រោមសំបុត្រ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០១៨

- បានឃើញ កំណត់ហេតុទទួលប្រាក់ធានាលើសំណើទិញចលនវត្ថុ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ដែលបានទទួលប្រាក់ធានាលើសំណើទិញចំនួន ៤.៥៧០ $ ពីឈ្មោះ ទី កក្កដា។
- បានឃើញ កំណត់ហេតុទទួលប្រាក់បង្គ្រប់ថ្លៃលក់ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ដែលបានទទួលប្រាក់បង្គ្រប់ថ្លៃលក់ចលនវត្ថុ ចំនួន ៦.១៨០ $ ពីឈ្មោះ ទី កក្កដា។
- បានឃើញ កំណត់ហេតុប្រគល់ទទួលរថយន្ត ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ។

**សំអាងហេតុ**

១.- រថយន្តម៉ាក Lexus RX 300 មានផ្លាកលេខ 2XX-2213 ត្រូវបានអាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញធ្វើរឹបអូស ដូចមានកំណត់ហេតុស្តីពីការរឹបអូសចលនវត្ថុ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១៨ ដើម្បីលក់ឡាយឡុងប្តូរជាប្រាក់ យកមកសងបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ចាន់ រក្សា តាមសាលក្រមរដ្ឋប្បវេណីលេខ ៩៧ “ក” ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ នៅក្នុងសំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ ហើយការរឹបអូសរថយន្តនេះត្រូវបានចុះបញ្ជីផ្អកផ្តាក់រឹបអូសរួចហើយ តាមលិខិតផ្អកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសរថយន្តលេខ ១០៦ លខ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ របស់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ។

២.- តាមកំណត់ហេតុលក់ឡាយឡុងដោយស្រោមសំបុត្រ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ របស់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ បញ្ជាក់ថា រថយន្តម៉ាក Lexus RX 300 មានផ្លាកលេខ 2XX-2213 ចំនួន ០១ គ្រឿង ត្រូវបានដាក់លក់ដោយបង្ខំ ដោយមានឈ្មោះ **ទី កក្កដា** អាយុ ២៧ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០៦១៣៨៨០០០ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ X2 ផ្លូវលេខ T555 ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ គឺជាអ្នកដេញថ្លៃបានលើរថយន្តនេះ ក្នុងតម្លៃអតិបរមា ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក។

៣.- តាមកំណត់ហេតុទទួលប្រាក់ធានាលើសំណើទិញចលនវត្ថុ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ និង កំណត់ហេតុទទួលប្រាក់បង្គ្រប់ថ្លៃលក់ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ បញ្ជាក់ថា ឈ្មោះ ទី កក្កដា បានបង់ប្រាក់ថ្លៃលក់ទិញរថយន្តនេះ គ្រប់ចំនួន រួចរាល់។ គប្បីអនុញ្ញាតឱ្យឈ្មោះ ទី កក្កដា ធ្វើលទ្ធកម្មសិទ្ធិលើរថយន្តខាងនេះ។

**សេចក្តីសម្រេចបញ្ចប់**

១.- លុបចោលការរឹបអូសលើរថយន្តម៉ាក Lexus RX 300 មានផ្លាកលេខ 2XX-2213 តាមលិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូសរថយន្តលេខ ១០៦ លខ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០១៨ របស់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ។

២.- បង្គាប់ឲ្យចុះបញ្ជីផ្ទុកផ្តាក់ផ្ទេរកម្មសិទ្ធិលើរថយន្តម៉ាក Lexus RX 300 មានផ្លាកលេខ 2XX-2213 ពីឈ្មោះ **ពុំ មេសា** ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មានលំនៅឋានផ្ទះលេខ ២១ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ទៅឲ្យឈ្មោះ **ទី កក្កដា** ភេទប្រុស អាយុ ២៧ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ០៦១៣៨៨០០០ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ X2 ផ្លូវលេខ T555 ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

ថ្ងៃច័ន្ទ ៦កើត ខែបឋមសាឍ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨

**អាជ្ញាសាលា**

**ជ័យ តេជះ**

ឧបសម្ព័ន្ធទី២៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ៖.....១២១.....សមអ

ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨

## លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិ

### យើង ជ័យ តេជៈ អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ មាត្រា៣៩៥ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញ សំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨
- បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ៩៧ "ក" ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ
- បានឃើញ លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមរដ្ឋប្បវេណី លេខ ៩៨ "ក" វវ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ
- បានឃើញ រូបមន្តអនុវត្ត លេខ ៩៩ "ក" វវ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ
- បានឃើញ កំណត់ហេតុស្តីពីការរឹបអូសចលនវត្ថុ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០១៨
- បានឃើញ លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូសរថយន្តលេខ ១០៦ លខ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ របស់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ កំណត់ហេតុលក់ឡាយឡុងដោយស្រោមសំបុត្រ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០១៨

- បានឃើញ កំណត់ហេតុទទួលប្រាក់ធានាលើសំណើទិញចលនវត្ថុ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ដែលបានទទួលប្រាក់ធានាលើសំណើទិញចំនួន ៤.៥៧០ $ ពីឈ្មោះ សុខ បូរី។
- បានឃើញ កំណត់ហេតុទទួលប្រាក់បង្គ្រប់ថ្លៃលក់ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ដែលបានទទួលប្រាក់បង្គ្រប់ថ្លៃលក់ចលនវត្ថុ ចំនួន ៣៦.៤៣០ $ ពីឈ្មោះ សុខ បូរី។
- បានឃើញ កំណត់ហេតុប្រគល់ទទួលរថយន្ត ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ។

## សំអាងហេតុ

១.- រថយន្តម៉ាក Lexus RX 350 មានផ្លាកលេខ 2XX-2244 ត្រូវបានអាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញធ្វើរឹបអូស ដូចមានកំណត់ហេតុស្តីពីការរឹបអូសចលនវត្ថុ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨ ដើម្បីលក់ឡាយឡុងប្តូរជាប្រាក់ យកមកសងបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ចាន់ រក្សា តាមសាលក្រមរដ្ឋប្បវេណីលេខ ៩៧ "ក" ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ នៅក្នុងសំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ ហើយការរឹបអូសរថយន្តនេះត្រូវបានចុះបញ្ជីផ្ទុកផ្តាក់រឹបអូសរួចហើយ តាមលិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូសរថយន្តលេខ ១០៦ លខ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ របស់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ។

២.- តាមកំណត់ហេតុលក់ឡាយឡុងដោយស្រោមសំបុត្រ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ របស់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ បញ្ជាក់ថា រថយន្តម៉ាក Lexus RX 350 មានផ្លាកលេខ 2XX-2244 ចំនួន ០១ គ្រឿង ត្រូវបានដាក់លក់ដោយបង្ខំ ដោយមានឈ្មោះ **សុខ បូរី** អាយុ ២៩ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០៦1000000 មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ T2 ផ្លូវលេខ X555 ភូមិ១៣ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ គឺជាអ្នកដេញថ្លៃបានលើរថយន្តនេះ ក្នុងតម្លៃអតិបរមា ៣២.០០០ (បីម៉ឺនពីរពាន់) ដុល្លារអាមេរិក។

៣.- តាមកំណត់ហេតុទទួលប្រាក់ធានាលើសំណើទិញចលនវត្ថុ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ និង កំណត់ហេតុទទួលប្រាក់បង្គ្រប់ថ្លៃលក់ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ បញ្ជាក់ថា ឈ្មោះ សុខ បូរី បានបង់ប្រាក់ថ្លៃលក់ទិញរថយន្តនេះ គ្រប់ចំនួន រួចរាល់។ គប្បីអនុញ្ញាតឲ្យឈ្មោះ សុខ បូរី ធ្វើលទ្ធកម្មសិទ្ធិលើរថយន្តខាងនេះ។

**សេចក្ដីសម្រេចបញ្ចប់**

១.- លុបចោលការរឹបអូសលើរថយន្តម៉ាក Lexus RX 350 មានផ្លាកលេខ 2XX-2244 តាមលិខិតផ្ទុកផ្ដាក់ឲ្យចុះបញ្ជីអំពីការរឹបអូសរថយន្តលេខ ១០៦ លខ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០១៨ របស់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ។

២.- បង្គាប់ឲ្យចុះបញ្ជីផ្ទុកផ្ដាក់ផ្ទេរកម្មសិទ្ធិលើរថយន្តម៉ាក Lexus RX 300 មានផ្លាកលេខ 2XX-2213 ពីឈ្មោះ **ពុំ មេសា** ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មានលំនៅឋានផ្ទះលេខ ២១ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ទៅឲ្យឈ្មោះ **សុខ បូរី** អាយុ ២៩ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០៦១០០០០០០ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ T2 ផ្លូវលេខ X555 ភូមិ១៣ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ថ្ងៃច័ន្ទ ៦កើត ខែបឋមសាធ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨

**អាជ្ញាសាលា**

**ជ័យ តេជៈ**

ឧបសម្ព័ន្ធទី២៥

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

# ដីកាកោះ

យើង **ជ័យ តេជៈ** អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ

**អញ្ជើញ** ៖ ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ **ចាន់ រក្សា** ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មានលំនៅឋានផ្ទះលេខ ២០ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ឲ្យចូលមកកាន់ **សាលាដំបូងរាជធានីភ្នំពេញ** នៅបន្ទប់អាជ្ញាសាលា ជាន់ទី២ នៅថ្ងៃច័ន្ទ ១២កើត ខែបឋមសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងទី២៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ៩:០០ នាទីព្រឹក។

ដើម្បីចូលរួម នៅក្នុង **នីតិវិធីចែកចំណែក** ក្នុងសំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

សាមីខ្លួនត្រូវអញ្ជើញមកតាមដីកាកោះនេះ ឲ្យបានទាន់ពេលវេលា តាមកាលបរិច្ឆេទដូចបានកំណត់ខាងលើ និងយកឯកសារផ្សេងៗដែលទាក់ទិននឹងរឿងខាងលើមកជាមួយផងប្រសិនបើមាន។

ថ្ងៃច័ន្ទ ៦កើត ខែបឋមសាឍ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨

**អាជ្ញាសាលា**

**ជ័យ តេជៈ**

ឧបសម្ព័ន្ធទី២៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# ដីកាកោះ

យើង **ជ័យ តេជៈ** អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ

**អញ្ជើញ** ៖ កូនបំណុលនៃការអនុវត្តឈ្មោះ **ពុំ មេសា** ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មានលំនៅឋានផ្ទះលេខ ២១ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ឱ្យចូលមកកាន់ **សាលាដំបូងរាជធានីភ្នំពេញ** នៅបន្ទប់អាជ្ញាសាលា ជាន់ទី២ នៅថ្ងៃច័ន្ទ ១២កើត ខែបឋមសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងទី២៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ៩:00 នាទីព្រឹក។

ដើម្បីចូលរួម នៅក្នុង **នីតិវិធីចែកចំណែក** ក្នុងសំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

សាមីខ្លួនត្រូវអញ្ជើញមកតាមដីកាកោះនេះ ឱ្យបានទាន់ពេលវេលា តាមកាលបរិច្ឆេទដូចបានកំណត់ខាងលើ និងយកឯកសារផ្សេងៗដែលទាក់ទិននឹងរឿងខាងលើមកជាមួយផងប្រសិនបើមាន។

ថ្ងៃច័ន្ទ ៦កើត ខែបឋមសាឍ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨

**អាជ្ញាសាលា**

**ជ័យ តេជៈ**

**ឧបសម្ព័ន្ធទី២៧**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**
**ចូល** លេខ៖ ០៦២
ថ្ងៃខែឆ្នាំ៖ ១៩ មិថុនា ២០១៨
ម៉ោង៖ ១០ : ៣០ នាទីព្រឹក

## លិខិតគណនាសិទ្ធិលើបំណុល

ខ្ញុំបាទឈ្មោះ **ចាន់ រក្សា** ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះលេខ ២០ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**សូមគោរពជូន**

**លោក ជ័យ តេជៈ អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ ស្ដីពីការគណនាសិទ្ធិលើបំណុលនៅក្នុងសំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង** ៖ - មាត្រា ៣៩៩ និងមាត្រាពាក់ព័ន្ធផ្សេងទៀតនៃក្រមនីតិវិធីរដ្ឋប្បវេណី

- ដីកាកោះ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨ ។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទសូមគោរពនិងជម្រាបជូន **លោកអាជ្ញាសាលា** មេត្តាជ្រាបថា ដើម្បីជាមូលដ្ឋានដល់លោកអាជ្ញាសាលាដឹកនាំនីតិវិធីចែកចែកនៅក្នុងសំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលនឹងប្រព្រឹត្តទៅនៅ **បន្ទប់អាជ្ញាសាលា** ជាន់ទី២ នៅថ្ងៃច័ន្ទ ១២កើត ខែបឋមសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងទី២៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ៩:០០ នាទីព្រឹក ខាងមុខនេះ ខ្ញុំបាទសូមធ្វើការគណនានូវសិទ្ធិបំណុលដែលខ្ញុំបាទមានលើកូនបំណុលនៃការអនុវត្តឈ្មោះ ពុំ មេសា សរុបទាំងអស់មានចំនួន ៤៣.០០១,២៥ ដុល្លារអាមេរិក ដូចតទៅ៖

ក.- សិទ្ធិលើបំណុលដែលកើតមានតាមរយៈ សាលក្រមរដ្ឋប្បវេណីលេខ ៩៧ “ក” ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ៤២.៥០០ ដុល្លារអាមេរិក រួមមាន៖

- ប្រាក់ដើម ៖ ៤០.០០០ ដុល្លារអាមេរិក
- ប្រាក់សំណងការខូចខាត ៖ ៨.០០០.០០០ រៀល ឬ ២.០០០ ដុល្លារ
- ប្រាក់ប្រដាប់ក្ដីសរុប ៖ ២.០០០.០០០ រៀល ឬ ៥០០ ដុល្លារ

ខ.- សោហ៊ុយអនុវត្តដែលបានចំណាយនៅក្នុងសំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ សរុប មានចំនួន ៤.២០៥.០០០ រៀល ឬ ១.៥០១,២៥ ដុល្លារអាមេរិក ក្នុងនោះរួមមាន៖

- ពន្ធដាក់ពាក្យសុំ ៖ ៥.០០០ រៀល
- សោហ៊ុយថែរក្សាវត្ថុរឹបអូស ៖១.២០០.០០០ រៀល ឬ ៣០០ ដុល្លារ
- សោហ៊ុយលើអ្នកវាយតម្លៃ ៖២.០០០.០០០ រៀល ឬ៥០០ ដុល្លារ
- សោហ៊ុយក្រៅពីពន្ធដាក់ពាក្យ ៖ ១.០០០.០០០ រៀល ឬ ២៥០ ដុល្លារ

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកអាជ្ញាសាលា** មេត្តាពិនិត្យ និងសម្រេច ដោយក្តីអនុគ្រោះ។

សូម **លោកអាជ្ញាសាលា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃអង្គារ ៧កើត ខែបឋមសាធ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨

**ម្ចាស់បំណុលនៃការអនុវត្ត**

**ចាន់ រក្សា**

ឧបសម្ព័ន្ធទី២៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# កំណត់ហេតុចែកចំណែក

យើង **ជ័យ តេជះ** អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក **សុខ ខេមុល** ជាអ្នកធ្វើកំណត់ហេតុ

បានដឹកនាំនីតិវិធីចែកចំណែក តាមមាត្រា ៣៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី មានដំណើរការដូចតទៅ៖

## ក.- សញ្ញាណនៃរឿងក្តី

សំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ ដែលមានម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ចាន់ វក្សា និង កូនបំណុលនៃការអនុវត្តឈ្មោះ ពុំ មេសា ដែលមានកម្មវត្ថុ៖ លក់ដោយបង្ខំនូវចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត។

## ខ.- ប្រាក់សម្រាប់ចែកចំណែក

ប្រាក់សម្រាប់ចែកចំណែកនៅក្នុងសំណុំរឿងនេះ គឺជាប្រាក់ដែលបានមកពីលក់ឡាយឡុងចលនវត្ថុដោយបង្ខំ មានចំនួនសរុប គឺ ៦១.៧៥០ (ប្រាំមួយម៉ឺនមួយពាន់ប្រាំពីររយហាសិប) ដុល្លារអាមេរិក ដែលក្នុង រួមមាន៖

- រឹបអូសប្រាក់នៅក្នុងទូដែក ៖ ១០.០០០ $
- ថ្លៃលក់រថយន្តម៉ាក Lexus RX 350 (ផ្លាកលេខ 2XX-2244) ៖ ៣២.០០០$
- ថ្លៃលក់រថយន្តម៉ាក Lexus RX 300 (ផ្លាកលេខ 2XX-2213) ៖ ១០.០០០$
- ថ្លៃលក់សាឡុងឈើឈុតធំ ចំនួន ០១ ឈុត ៖ ៩.០០០$
- ថ្លៃលក់ខ្សែ ក មាសសុទ្ធ មានទម្ងន់ ១ ដំឡឹង ៖ ៧៥០ $

## គ.- កាលបរិច្ឆេទ ពេលវេលា ទីកន្លែង និងសមាសភាពចូលរួម

- កាលបរិច្ឆេទ និងពេលវេលា ៖ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ៩:00 នាទីព្រឹក

- ទីកន្លែងលក់ ៖ បន្ទប់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ
- សមាសភាពចូលរួម ៖

១.- លោក ចាន់ វក្សា ត្រូវជាម្ចាស់បំណុលនៃការអនុវត្ត

២.- លោក ពុំ មេសា ត្រូវជាកូនបំណុលនៃការអនុវត្ត

**ឃ.- ខ្លឹមសារនៃសកម្មភាពដែលបានចាត់ចែង**

នៅកាលបរិច្ឆេទ និងពេលវេលានៃការចែកចំណែក យើងឃើញមានវត្តមានម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ចាន់ វក្សា និង កូនបំណុលនៃការអនុវត្តឈ្មោះ ពុំ មេសា ចូលរួមនៅក្នុងនីតិវិធីចែកចំណែកក្នុងសំណុំរឿងអនុវត្តខាងលើ ។

បន្ទាប់មកយើងបានធ្វើការពន្យល់ដល់ភាគីទាំងពីរ អំពីដំណើរការនៃនីតិវិធីអនុវត្តនេះតាំងពីការចាប់ផ្តើមនីតិវិធីអនុវត្តដោយបង្ខំ រហូតដល់ នីតិវិធីចែកចំណែកនេះ ហើយយើងបានផ្តល់សិទ្ធិឲ្យភាគីទាំងពីរធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់នៅក្នុងនីតិវិធីចែកចំណែកនេះ ដូចខាងតទៅ៖

ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ចាន់ វក្សា បានធ្វើសេចក្តីថ្លែងការណ៍ថា សិទ្ធិលើបំណុលដែលខ្លួនមានលើកូនបំណុលនៃការអនុវត្តឈ្មោះ ពុំ មេសា តាមរយៈសាលក្រមរដ្ឋប្បវេណីលេខ ៩៧ “ក” ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ និងសោហ៊ុយអនុវត្តដែលបានចំណាយនៅក្នុងសំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ គឺមានចំនួន សរុបទាំងអស់ចំនួន ៤៣.០០១,២៥ ដុល្លារអាមេរិក ។ ចំពោះការបរិយាយលំអិតអំពីការគណនាសិទ្ធិលើបំណុលនេះ គឺខ្លួនបានបញ្ជាក់នៅក្នុង លិខិតគណនាសិទ្ធិលើបំណុល ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ ហើយលិខិតនេះត្រូវដាក់ជូនក្នុងសំណុំរឿងនេះរួចហើយ។ ម្ចាស់បំណុលនៃការអនុវត្ត សូមសំណូមពរឲ្យលោកអាជ្ញាសាលា ផ្តល់នូវប្រាក់ចំណែកឲ្យមកខ្លួនតាមការគណនានេះ។

កូនបំណុលនៃការអនុវត្តឈ្មោះ ពុំ មេសា បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនទទួលស្គាល់នូវការគណនាសិទ្ធិលើបំណុលដែលម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ចាន់ វក្សា មានលើខ្លួនសរុបចំនួន ៤៣.០០១,២៥ ដុល្លារអាមេរិក ។ ប៉ុន្តែខ្លួនសូមសំណូមឲ្យម្ចាស់បំណុលនៃការអនុវត្ត ទទួលប្រាក់ចំណែកតែចំនួន ៤០.០០០ ដុល្លារអាមេរិក បានហើយ ព្រោះប្រាក់ចំណែកដែលនោះសេសសល់គឺខ្លួនអាចយកទៅប្រកបរបរចិញ្ចឹមជីវិត និង ព្យាបាលជម្ងឺដែលខ្លួនមាន។

ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ចាន់ រក្សា បានអះអាងថាខ្លួនបដិសេធនូវសំណូមពររបស់កូនបំណុលនៃការអនុវត្តឈ្មោះ ពុំ មេសា ខាងលើ ពីព្រោះថាខ្លួនបានចំណាយពេលវេលា និង ប្រាក់ជាច្រើនទម្រាំបានដល់ដំណាក់កាលនៃការចែកចំណែកនេះ។

បន្ទាប់ពីស្តាប់នូវសេចក្តីថ្លែងការណ៍របស់ភាគីទាំងពីរ និង ឯកសារពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះ យើងសម្រេចថា ប្រាក់ដែលបានមកពីការលក់ចលនវត្ថុដោយបង្ខំ មានចំនួនសរុប ៦១.៧៥០ (ប្រាំមួយម៉ឺនមួយពាន់ប្រាំពីររយហាសិប) ដុល្លារអាមេរិក ត្រូវធ្វើការចែកចំណែក តាមបញ្ញត្តិនៃមាត្រា ៣៩៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺ ប្រាក់ចំនួន ៤៣.០០១,២៥ ដុល្លារអាមេរិក ត្រូវចែកចំណែកឲ្យទៅម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ចាន់ រក្សា ហើយប្រាក់ដែលនៅសល់មានចំនួន ១៨.៧៤៨,៧៥ ដុល្លារអាមេរិក ត្រូវប្រគល់ឲ្យកូនបំណុលនៃការអនុវត្តឈ្មោះ ពុំ មេសា។

**ខ.- កាលបរិច្ឆេទនៃការធ្វើ និង ការចាត់ចែងកំណត់ហេតុ**

កំណត់ហេតុនេះត្រូវបានធ្វើឡើងនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ៩ និង០០ នាទីព្រឹក និងបញ្ចប់ នៅវេលាម៉ោង ៩ និង ៣០ នាទី នាថ្ងៃខែឆ្នាំដដែល ហើយយើងបានអានកំណត់ហេតុនេះឲ្យអ្នកចូលរួមបានស្តាប់។

| **អាជ្ញាសាលា** | សមាសភាពចូលរួម | | **អ្នកធ្វើកំណត់ហេតុ** |
|---|---|---|---|
| **ជ័យ តេជះ** | ចាន់ រក្សា<br>(ម្ចាស់បំណុលនៃការអនុវត្ត) | ពុំ មេសា<br>(កូនបំណុលនៃការអនុវត្ត) | **សុខ ខបុល** |

ឧបសម្ព័ន្ធទី២៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

# កំណត់ហេតុប្រគល់ទទួលប្រាក់ចំណែក

យើង **ជ័យ តេជះ** អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក **សុខ ខេមរុល** ជាអ្នកធ្វើកំណត់ហេតុ

**យោង** ៖ - កំណត់ហេតុចែកចំណែក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨

នាថ្ងៃច័ន្ទ ១៣កើត ខែបឋមសាធ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ដប់ និងសូន្យនាទី នៅបន្ទប់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ជាន់ទី២

បានប្រគល់ប្រាក់ចំនួន ៤៣.០០១,២៥ (បួនម៉ឺនបីពាន់មួយក្បៀសម្ភៃប្រាំ) ដុល្លារអាមេរិក ដែលជាប្រាក់ចំណែក តាមកំណត់ហេតុហេតុចែកចំណែក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨

ទៅឲ្យឈ្មោះ **ចាន់ រក្សា** ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មានលំនៅឋានផ្ទះលេខ ២០ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ត្រូវជាម្ចាស់បំណុលនៃការអនុវត្ត នៅក្នុងសំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨។

បញ្ចប់កំណត់ហេតុនៅវេលាម៉ោង ដប់ និងម្ភៃនាទី នាថ្ងៃខែឆ្នាំដដែល ដោយបានអានឲ្យអ្នកចូលរួមទាំងអស់បានស្តាប់ ព្រមទាំងឯកភាពផ្តិតមេដៃស្តាំទុកជាភស្តុតាង។

| **អាជ្ញាសាលា** | **អ្នកទទួលប្រាក់** | **អ្នកធ្វើកំណត់ហេតុ** |
|---|---|---|
| **ជ័យ តេជះ** | ចាន់ រក្សា | **សុខ ខេមរុល** |

ឧបសម្ព័ន្ធទី៣០

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

## កំណត់ហេតុប្រគល់ទទួលប្រាក់ចំណែក

យើង **ជ័យ តេជះ** អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក **សុខ ខេមុល** ជាអ្នកធ្វើកំណត់ហេតុ

**យោង** ៖ - កំណត់ហេតុចែកចំណែក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨

នាថ្ងៃច័ន្ទ ១៣កើត ខែបឋមសាធ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ដប់ និងសូន្យនាទី នៅបន្ទប់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ជាន់ទី២

បានប្រគល់ប្រាក់ចំនួន ១៨.៧៤៨,៧៥ (មួយម៉ឺនប្រាំបីពាន់ប្រាំពីររយសែសិបប្រាំបីក្បៀសចិតសិបប្រាំ) ដុល្លារអាមេរិក ដែលជាប្រាក់សល់ពីពីការចែកចំណែកឲ្យម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ចាន់ រក្សា តាមកំណត់ហេតុហេតុចែកចំណែក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨

ទៅឲ្យឈ្មោះ **ពុំ មេសា** ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មានលំនៅឋានផ្ទះលេខ ២១ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ត្រូវជាកូនបំណុលនៃការអនុវត្ត នៅក្នុងសំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨។

បញ្ចប់កំណត់ហេតុនៅវេលាម៉ោង ដប់ និងម្ភៃនាទី នាថ្ងៃខែឆ្នាំដដែល ដោយបានអានឲ្យអ្នកចូលរួមទាំងអស់បានស្តាប់ ព្រមទាំងឯកភាពផ្តិតមេដៃស្នាំទុកជាភស្តុតាង។

| អាជ្ញាសាលា | អ្នកទទួលប្រាក់ | អ្នកធ្វើកំណត់ហេតុ |
|---|---|---|
| ជ័យ តេជះ | ពុំ មេសា | សុខ ខេមុល |

ឧបសម្ព័ន្ធទី៣១

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

# កំណត់ហេតុបញ្ចប់សំណុំរឿង

យើង **ជ័យ តេជៈ** អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក **សុខ ខេមុល** ជាអ្នកធ្វើកំណត់ហេតុ

នាថ្ងៃអង្គារ ១៤កើត ខែបឋមសាធ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ប្រាំបួន និងសូន្យនាទីព្រឹក នៅបន្ទប់អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ

បានពិនិត្យសំណុំរឿងអនុវត្តលេខ ៥៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ ដែលមានម្ចាស់បំណុលនៃការអនុវត្តឈ្មោះ **ចាន់ រក្សា** ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មានលំនៅឋានផ្ទះលេខ ២០ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ និងកូនបំណុលនៃការអនុវត្តឈ្មោះ **ពុំ មេសា** ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មានលំនៅឋានផ្ទះលេខ ២១ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ឃើញដូចតទៅៈ

១.- សំណុំរឿងអនុវត្តនេះត្រូវបង្កឡើងតាមពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៨ របស់ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ **ចាន់ រក្សា** ដើម្បីសុំរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្តឈ្មោះ **ពុំ មេសា** យកមកប្តូរជាប្រាក់សងសិទ្ធិលើបំណុលរបស់ខ្លួន តាមសាលក្រមរដ្ឋប្បវេណីលេខ ៩៧ "ក" ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

២.- ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុនេះ ត្រូវដាក់មកសាលាដំបូងរាជធានីភ្នំពេញ ដោយមានភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូតនៃសាលក្រមរដ្ឋប្បវេណីលេខ ៩៧ "ក" ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ, លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមរដ្ឋប្បវេណី លេខ ៩៨ "ក" វវ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ របស់

សាលាដំបូងរាជធានីភ្នំពេញ និងរូបមន្តអនុវត្ត លេខ ៩៩ "ក" រវ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបញ្ជាក់ថាពាក្យសុំនេះមានលក្ខណៈត្រឹមត្រូវស្របតាមបញ្ញត្តិនៃមាត្រា ៣៨៤ មាត្រា ៣៥០ មាត្រា ៣៥៤ និងមាត្រាពាក់ព័ន្ធផ្សេងទៀតនៃក្រមនីតិវិធីរដ្ឋប្បវេណី។ អាជ្ញាសាលាអាចដំណើរការនីតិវិធីរបស់ខ្លួនបាន។

៣.- នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៨ អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ បានស្នើសុំឲ្យអភិបាលនៃគណៈអភិបាលខណ្ឌទួលគោក ផ្តល់នូវកម្លាំងនគរបាលឲ្យចូលរួមអនុវត្តរឹបអូសចលនវត្ថុ ដើម្បីធានាការបំពេញមុខងាររបស់អាជ្ញាសាលា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨ នៅផ្ទះលេខ ២១ ផ្លូវលេខ ១០១ ភូមិ៨ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលជាលំនៅឋានផ្ទាល់របស់កូនបំណុលនៃការអនុវត្តឈ្មោះ **ពុំ មេសា** ។

៤.- នៅកាលបរិច្ឆេទនៃការចុះអនុវត្តរឹបអូសចលនវត្ថុ អាជ្ញាសាលា និង គណៈកម្មការចំរុះ បានសម្រេចរឹបអូស ប្រាក់សុទ្ធដែលមាននៅក្នុងទូដែកចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក និងរឹបអូសចលនវត្ថុដែលស្ថិតនៅទីតាំងអនុវត្ត រួមមាន រថយន្តម៉ាក Lexus RX 350 មានផ្លាកលេខ 2XX-2244 ចំនួន ០១ គ្រឿង, រថយន្តម៉ាក Lexus RX 300 មានផ្លាកលេខ 2XX-2213 ចំនួន ០១ គ្រឿង, ទូដែកចំនួន ០១, ខ្សែក(លោហៈធាតុព័ណ៌មាស) ចំនួន ០១ ខ្សែ, នាឡិកាដៃម៉ាក Rolex ចំនួន ០១ ខ្សែ មករក្សាទុកនៅឃ្លាំងសាលាដំបូងរាជធានីភ្នំពេញ ដូចមានបញ្ជាក់នៅក្នុងកំណត់ហេតុរឹបអូសចលនវត្ថុ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨។

៥.- នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ អាជ្ញាសាលាបានធ្វើលិខិតស្នើទៅកាន់មន្ទីរសាធារណៈការ និង ដឹកជញ្ជូនរាជធានីភ្នំពេញ ឲ្យចុះបញ្ជីរឹបអូសរថយន្តម៉ាក Lexus RX 350 មានផ្លាកលេខ 2XX-2244 ចំនួន ០១ គ្រឿង, រថយន្តម៉ាក Lexus RX 300 មានផ្លាកលេខ 2XX-2213 ចំនួន ០១ គ្រឿង។

៦.- ដោយមានការស្នើសុំពីម្ចាស់បំណុលនៃការអនុវត្ត អាជ្ញាសាលាសម្រេចៈ ១.- ជ្រើសតាំង និងបង្គាប់ឲ្យ លោក **រស់ សុភក្រ** ភេទប្រុស អាយុ ៣៤ឆ្នាំ ជនជាតិខ្មែរ មានមុខរបរជាម្ចាស់យានដ្ឋាន មានអាសយដ្ឋានផ្ទះលេខ ៣៣៣ ផ្លូវលេខ ២២២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ធ្វើជាអ្នកវាយតម្លៃលើរថយន្តម៉ាក Lexus RX 350 ផ្លាកលេខ 2XX-2244 ចំនួន ០១ គ្រឿង និង រថយន្តម៉ាក Lexus RX 300 ផ្លាកលេខ 2XX-2213 ចំនួន ០១គ្រឿង។ ២.- ជ្រើសតាំង និងបង្គាប់ឲ្យលោក **លី បូរី** ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ មានមុខរបរជាអ្នកគ្រឿងសង្ហា

រីម មានអាស័យដ្ឋានផ្ទះលេខ ៤៤៤ ផ្លូវលេខ ៣៣៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ធ្វើជាអ្នកវាយតម្លៃលើសាឡុងឈើឈុតធំ ចំនួន ០១ ឈុត។ ៣.- ជ្រើសតាំង និងបង្គាប់ឲ្យលោក **មាស ពន្លឺ** ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ មានមុខរបរជាអ្នកលក់គ្រឿងអលង្ការ មានអាស័យដ្ឋានផ្ទះលេខ ៥៥៥ ផ្លូវលេខ ៤៤៤ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ធ្វើជាអ្នកវាយតម្លៃលើ ខ្សែក(លោហៈធាតុព័ណ៌មាស) ចំនួន ០១ខ្សែ និងនាឡិកាដៃម៉ាក Rolex ចំនួន ០១ខ្សែ។ ជាលទ្ធផល បន្ទាប់ពីទទួលបាននូវរបាយការណ៍ពីអ្នកវាយតម្លៃទាំងបីនាក់ខាងលើនេះ អាជ្ញាសាលាបានសម្រេច លុបចោលការរឹបអូសនាឡិកាម៉ាក Rolex ចំនួន ០១ខ្សែ ដោយមូលហេតុនាឡិកានេះមិនមែនជាផលិតដើម ហើយគ្មានតម្លៃលើទីផ្សារ តាមសេចក្តីសម្រេចលេខ ១១២ សមអ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ និង សម្រេចកំណត់តម្លៃលក់ចលនវត្ថុអប្បបរមា តាមសេចក្តីសម្រេចលេខ ១១៣ សមអ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ដូចខាងក្រោម៖

- រថយន្តម៉ាក Lexus RX 350 មានផ្លាកលេខ 2XX-2244 ត្រូវដាក់លក់ដោយបង្ខំក្នុងតម្លៃលក់អប្បបរមាចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក ។
- រថយន្តម៉ាក Lexus RX 300 មានផ្លាកលេខ 2XX-2213 ត្រូវដាក់លក់ដោយបង្ខំក្នុងតម្លៃលក់អប្បបរមាចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក។
- សាឡុងឈើឈុតធំ ចំនួន ០១ ឈុត ត្រូវដាក់លក់ដោយបង្ខំក្នុងតម្លៃលក់អប្បបរមា ចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លារអាមេរិក។
- ខ្សែ ក មាសសុទ្ធ មានទម្ងន់ ១ ដំឡឹង ត្រូវដាក់លក់ដោយបង្ខំក្នុងតម្លៃលក់អប្បបរមាចំនួន ៧០០ (ប្រាំពីររយ) ដុល្លារអាមេរិក ។

៧.- អាជ្ញាសាលាបានកំណត់យកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ៩:០០ នាទីព្រឹក គឺជាកាលបរិច្ឆេទនៃការលក់ឡាយឡុងនូវចលនវត្ថុដែលបានរឹបអូសនៅក្នុងសំណុំរឿងនេះ តាមសេចក្តីជូនដំណឹងជាសាធារណៈ លេខ ១១៧ សមអ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៨ ។ ជាលទ្ធផលមានបុគ្គលចំនួន ០២ នាក់ ដែលបានដាក់ពាក្យសុំចូលរួមដេញថ្លៃទិញយកចលនវត្ថុដែលបានដាក់លក់ដោយបង្ខំនេះ រួមមាន៖ ១.- ឈ្មោះ **ទី កក្កដា** អាយុ ២៧ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០៦១៣៨៨០០០ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ X2 ផ្លូវលេខ T555 ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ និង ឈ្មោះ **សុខ បូរី** អាយុ ២៩ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០៦១០០០០០០

មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ T2 ផ្លូវលេខ X555 ភូមិ១៣ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ បុគ្គលទាំងពីរនេះត្រូវបង់ប្រាក់ធានាលើសំណើទិញចលនវត្ថុចំនួន ១/១០ នៃតម្លៃលក់អប្បបរមា គឺមានចំនួន ៤.៥៧០ (បួនពាន់ប្រាំរយចិតសិប) ដុល្លារអាមេរិក ក្នុងម្នាក់។

៨.- នៅពេលបញ្ចប់ការលក់ឡាយឡុង ជាលទ្ធផល អាជ្ញាសាលាសម្រេចកំណត់យក ឈ្មោះ **ទី កក្កដា** គឺជាអ្នកដេញថ្លៃបានលើចលនវត្ថុដែលបានដាក់លក់ឡាយឡុង រួមមាន រថយន្តម៉ាក Lexus RX 300 មានផ្លាកលេខ 2XX-2213 ក្នុងតម្លៃអតិបរមាចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក និង ខ្សែ ក មាសសុទ្ធ មានទម្ងន់ ១ ដំឡឹង ក្នុងតម្លៃអតិបរមាចំនួន ៧៥០ (ប្រាំពីររយហាសិប) ដុល្លារអាមេរិក និងកំណត់យកឈ្មោះ **សុខ បូរី** គឺជាអ្នកដេញថ្លៃបានលើចលនវត្ថុដែលបានដាក់លក់ឡាយឡុង រួមមាន៖ រថយន្តម៉ាក Lexus RX 350 មានផ្លាកលេខ 2XX-2244 ក្នុងតម្លៃអតិបរមាចំនួន ៣២.០០០ (បីម៉ឺនពីរពាន់) ដុល្លារអាមេរិក និង សាឡុងឈើឈុតធំ ចំនួន ០១ ឈុត ក្នុងតម្លៃលក់អតិបរមា ចំនួន ៤.០០០ (ប្រាំបួនពាន់) ដុល្លារអាមេរិក។

៩.- បន្ទាប់ពីបានទទួលប្រាក់បង្គ្រប់ថ្លៃលក់ចលនវត្ថុ ចំនួន ៦.១៨០ (ប្រាំមួយពាន់មួយរយប៉ែតសិប) ដុល្លារអាមេរិក ពីឈ្មោះ ទី កក្កដា អាជ្ញាសាលាក៏សម្រេចប្រគល់ចលនវត្ថុរួមមាន រថយន្តម៉ាក Lexus RX 300 មានផ្លាកលេខ 2XX-2213 និង ខ្សែ ក មាសសុទ្ធ មានទម្ងន់ ១ ដំឡឹង ទៅឲ្យលោក ទី កក្កដា តាមកំណត់ហេតុប្រគល់ទទួលរថយន្ត ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០១៨ ។ អាជ្ញាសាលាក៏បានផ្ទុកផ្តាក់ទៅសាធារណៈការ និង ដឹកជញ្ជូនរាជធានីភ្នំពេញ ដើម្បីធ្វើនីតិវិធីផ្ទេរកម្មសិទ្ធិលើរថយន្តម៉ាក Lexus RX 330 ពីឈ្មោះ ពុំ មេសា ទៅឈ្មោះ ទី កក្កដា។

១០.- បន្ទាប់ពីបានទទួលប្រាក់បង្គ្រប់ថ្លៃលក់ចលនវត្ថុ ចំនួន ៣៦.៤៣០ (បីម៉ឺនប្រាំមួយពាន់បួនរយសាមសិប) ដុល្លារអាមេរិក ពីឈ្មោះ សុខ បូរី អាជ្ញាសាលាក៏សម្រេចប្រគល់ចលនវត្ថុរួមមាន រថយន្តម៉ាក ម៉ាក Lexus RX 350 មានផ្លាកលេខ 2XX-2244 ដុល្លារអាមេរិក និង សាឡុងឈើឈុតធំ ចំនួន ០១ ឈុត ទៅឲ្យលោក សុខ បូរី តាមកំណត់ហេតុប្រគល់ទទួលរថយន្ត ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ។ អាជ្ញាសាលាក៏បានផ្ទុកផ្តាក់ទៅសាធារណៈការ និង ដឹកជញ្ជូនរាជធានីភ្នំពេញ ដើម្បីធ្វើនីតិវិធីផ្ទេរកម្មសិទ្ធិលើរថយន្តម៉ាក Lexus RX 350 ពីឈ្មោះ ពុំ មេសា ទៅឈ្មោះ សុខ បូរី។

១១.- អាជ្ញាសាលាបានកំណត់យកថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ គឺជាកាលបរិច្ឆេទនៃការចែកចំណែកនៅក្នុងសំណុំរឿងអនុវត្តនេះ ដោយបានជូនដំណឹងដល់ម្ចាស់បំណុលនៃការអនុវត្ត

និង កូនបំណុលនៃការអនុវត្ត ឲ្យចូលរួមនៅកាលបរិច្ឆេទនេះ។ ជាលទ្ធផលអាជ្ញាសាលាសម្រេចថា ប្រាក់ដែលបានមកពីការលក់ចលនវត្ថុដោយបង្ខំ មានចំនួន សរុប ៦១.៧៥០ (ប្រាំមួយម៉ឺនមួយពាន់ប្រាំពីររយហាសិប) ដុល្លារអាមេរិក ត្រូវធ្វើការចែកចំណែក តាមបញ្ញត្តិនៃមាត្រា ៣៩៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺ ប្រាក់ចំនួន ៤៣.០០១,២៥ ដុល្លារអាមេរិក ត្រូវចែកចំណែកឲ្យទៅម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ចាន់ រក្សា ហើយប្រាក់ដែលនៅសល់មានចំនួន ១៨.៧៤៨,៧៥ ដុល្លារអាមេរិក ត្រូវប្រគល់ឲ្យកូនបំណុលនៃការអនុវត្តឈ្មោះ ពុំ មេសា។

**ហេតុដូចនេះ** អាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញសម្រេចបិតសំណុំរឿងអនុវត្តនេះត្រូវបង្កឡើងតាមពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៨ របស់ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ **ចាន់ រក្សា** ដើម្បីសុំរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្តឈ្មោះ **ពុំ មេសា** យកមកប្តូរជាប្រាក់សងសិទ្ធិលើបំណុលរបស់ខ្លួន តាមសាលក្រមរដ្ឋប្បវេណីលេខ ៩៧ "ក" ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដើម្បីបញ្ជូនទៅរក្សាទុកនៅក្នុងឃ្លាំងរក្សាសំណុំរឿងរបស់សាលាដំបូងរាជធានីភ្នំពេញ ចាប់ពីថ្ងៃនេះតទៅ។

បញ្ចប់កំណត់ហេតុនៅវេលាម៉ោងដប់ និងសាមនាទីព្រឹកនាថ្ងៃខែឆ្នាំដដែល។

| | |
|---|---|
| **អាជ្ញាសាលា** | **អ្នកធ្វើកំណត់ហេតុ** |
| **ជ័យ តេជៈ** | **សុខ ឧបុល** |

# សូមអរគុណ